**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញានៃម៉ាក និងសិទ្ធិអ្នកនិពន្ធនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **តាន់ ច័ន្ទឧស្សាហ៍**

កញ្ញា **ហេង ម៉ារ៉ាលីន**

សាស្ត្រាចារ្យណែនាំ

លោក **ឃឹម ឧត្តម**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញានៃម៉ាក និងសិទ្ធិអ្នកនិពន្ធនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **តាន់ ច័ន្ទឧស្សាហ៍**

កញ្ញា **ហេង ម៉ារ៉ាលីន**

សាស្ត្រាចារ្យណែនាំ

លោក **ឃឹម ឧត្តម**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **តាន់ ច័ន្ទឧស្សាហ៍** និង **ហេង ម៉ារ៉ាលីន** ជានិស្សិតផ្នែកនីតិសាស្ត្រ ឆ្នាំទី ៤ ជំនាន់ទី ១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

- លោកឪពុកនិងអ្នកម្តាយទាំងទ្វេរ ដែលបានផ្តល់កំណើតដល់រូបកូន ចិញ្ចឹមបីបាច់ថែរក្សាកូន ផ្តល់ដំបូន្មានប្រៀនប្រដៅ ក៏ដូចជាទំនុកបម្រុងកូនគ្រប់បែបយ៉ាងទាំងផ្នែកស្មារតី និងសម្ភារៈ តាំងពីចាប់កំណើតរហូតដល់បញ្ចប់ការសិក្សា។ គុណដ៏ធំធេងរបស់លោកទាំងទ្វេរគ្មានអ្វីប្រៀបផ្ទឹមបានឡើយ។
- លោកតា លោកយាយ លោកពូ អ្នកមីង និងបងប្អូនទាំងសងខាង ដែលតែងតែផ្តល់កម្លាំងចិត្ត ក៏ដូចជា មតិយោបល់ និងគំនិតល្អៗជាច្រើនដល់រូបយើងខ្ញុំ។
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានយកចិត្តទុកដាក់នៅក្នុងការបង្រៀន ណែនាំ លើកទឹកចិត្ត និងគាំទ្រវាល់សកម្មភាពសិក្សាទាំងឡាយ នៅក្នុងការសិក្សាអស់រយៈពេល៤ឆ្នាំកន្លងមកនេះឱ្យមានចំណេះដឹងក្នុងវិស័យច្បាប់ និងផ្តល់ដំបូន្មានល្អៗក្នុងសង្គមរស់នៅជាក់ស្តែង។
- លោកគ្រូ **ឃឹម ឧត្តម** ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការជួយដឹកនាំ និងផ្តល់យោបល់ ក៏ដូចជាកែសម្រួល ដើម្បីធ្វើឱ្យសារណាមួយនេះអាចលេចជារូបរាងឡើង។

ជាទីបញ្ចប់នេះ យើងខ្ញុំ សូមគោរពជូនពរដល់អ្នកមានគុណទាំងអស់ដែលរួមមាន៖ អ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាល័យ លោក លោកស្រីសាស្ត្រាចារ្យ ដែលបានរៀបរាប់ខាងលើនេះ សូមជួបតែសំណាងល្អ និងពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ជាបឋម យើងខ្ញុំសូមគោរព និងស្វាគមន៍ចំពោះលោក លោកស្រី សាស្ត្រាចារ្យ សិស្ស និស្សិត និងបញ្ញាវន្តទាំងអស់ ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការអានសៀវភៅរបស់យើងខ្ញុំ ដែលបានរៀបរាប់អំពី "**ការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញានៃម៉ាក និងសិទ្ធិអ្នកនិពន្ធនៅកម្ពុជា**"។ សារណាមួយនេះ បានតាក់តែងឡើងនៅក្នុងឱកាសបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ហើយនេះក៏ជាឱកាសដ៏វិសេសវិសាលមួយដែលយើងខ្ញុំអាចវាស់ស្ទង់ចំណេះដឹងតាមរយៈការសិក្សាអស់រយៈពេល ៤ ឆ្នាំ និងការស្រាវជ្រាវបន្ថែម។

ការសម្រេចជ្រើសរើសយកប្រធានបទនេះឡើង គឺក្នុងគោលបំណងសិក្សាបន្ថែមនៅក្នុងការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញានៅកម្ពុជា ដោយមើលឃើញពីសារៈប្រយោជន៍នៃវិស័យពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញានៅកម្ពុជា និងភាពរីកចម្រើនខាងផ្នែកវិស័យសេដ្ឋកិច្ចជាតិនោះ ព្រមទាំងសង្កេតឃើញកម្ពុជាកំពុងតែប្រឈមមុខទៅនឹងការការពារកម្មសិទ្ធិបញ្ញាផងដែរ។

ទោះបីជា យើងខ្ញុំបានពិនិត្យ និងកែសម្រួលជាច្រើនលើក ជាច្រើនសារហើយក្តី ក៏យើងខ្ញុំបានដឹងច្បាស់ថាកង្វះខាតនូវចំណុចមួយចំនួន អត្ថន័យ ឬខ្លឹមសារណាមួយពិតជាជៀសមិនផុតនោះឡើយ។

អាស្រ័យដូចបានជម្រាបមកខាងលើ សូមលោក លោកស្រី សាស្ត្រចារ្យ សិស្ស និស្សិត និងបញ្ញាវន្តទាំងអស់ មេត្តាអាធ្យាស្រ័យនូវរាល់កំហុសឆ្គងដែលបានកើតឡើងដោយអចេតនា ដោយក្តីអនុគ្រោះ។ សូមអរគុណ។

# មាតិកា

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១
## ផលប្រយោជន៍នៃកម្មសិទ្ធិបញ្ញានៅកម្ពុជា

**ផ្នែកទី១៖ ផលប្រយោជន៍នៃម៉ាក** ........ ៣

**កថាខណ្ឌទី១៖ សញ្ញាណទូទៅនៃម៉ាក** ........ ៣

ក. ប្រភេទនៃម៉ាក ........ ៤

ខ.គោលការណ៍នៃកិច្ចការពារម៉ាក ........ ៥

**កថាខណ្ឌទី២៖ ផលប្រយោជន៍នៃម៉ាកនៅកម្ពុជា** ........ ៧

ក. ផលប្រយោជន៍នៃម៉ាកនៅក្នុងវិស័យសេដ្ឋកិច្ច ........ ៧

១.ចំពោះសេដ្ឋកិច្ចជាតិ ........ ៧

២. ទំនាក់ទំនងពាណិជ្ជកម្ម ........ ៨

ខ. ផលប្រយោជន៍នៃម៉ាកនៅក្នុងសង្គម ........ ៨

១. ផលប្រយោជន៍សម្រាប់ម្ចាស់សិទ្ធិ ឬម្ចាស់ស្នាដៃ ........ ៨

២. ផលប្រយោជន៍សម្រាប់អ្នកប្រើប្រាស់ ........ ៩

**ផ្នែកទី២៖ ផលប្រយោជន៍នៃសិទ្ធិអ្នកនិពន្ធនៅកម្ពុជា** ........ ១០

**កថាខណ្ឌទី១៖ សញ្ញាណទូទៅនៃសិទ្ធិអ្នកនិពន្ធ** ........ ១០

ក. ស្ថានភាពគតិយុត្តនៃការកំណត់ឋានៈអ្នកនិពន្ធ ........ ១០

១. អ្នកនិពន្ធជាបុគ្គលដែលបង្កើតស្នាដៃ ........ ១០

២. អ្នកនិពន្ធត្រូវតែជារូបវន្តបុគ្គល ........ ១១

ខ. គោលការណ៍នៃកិច្ចការពារសិទ្ធិអ្នកនិពន្ធ ........ ១២

១.គោលការណ៍នៃកិច្ចការពារដោយស្វ័យប្រវត្តិ ........ ១២

២. ភស្តុតាងបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិរបស់អ្នកនិពន្ធ ........ ១៣

**កថាខណ្ឌទី២៖ ផលប្រយោជន៍នៃសិទ្ធិអ្នកនិពន្ធ** ........ ១៤

ក. ការទទួលបានការការពារសិទ្ធិរបស់អ្នកនិពន្ធ ........ ១៤
១. ការទទួលបាននូវការការពារស្នាដៃ ........ ១៤
១.១. សិទ្ធិបេតិកភណ្ឌ ........ ១៤
១.២. សិទ្ធសីលធម៌ ........ ១៥
ខ. ផលប្រយោជន៍ដែលទទួលបាននៅក្នុងសង្គម ........ ១៦
១. ផលប្រយោជន៍សម្រាប់វិស័យវប្បធម៌ ........ ១៧
២. ផលប្រយោជន៍សម្រាប់សង្គមជាតិ ........ ១៨

## ជំពូកទី២

## ផលប៉ះពាល់នៃការរំលោភបំពានកម្មសិទ្ធិបញ្ញានៅកម្ពុជា

**ផ្នែកទី១៖ ការរំលោភបំពានសិទ្ធិលើម៉ាកនៅកម្ពុជា** ........ ២០
**កថាខណ្ឌទី១៖ រូបភាពនៃអំពើរំលោភសិទ្ធិលើម៉ាក** ........ ២០
ក. ការក្លែងបន្លំម៉ាក ........ ២០
១. ការផលិតឡើងវិញនៃម៉ាក ........ ២១
២. ការធ្វើត្រាប់តាមម៉ាក ........ ២១
ខ. ការច្រេកផលិតផល ........ ២១
គ. ការប្រើប្រាស់ម៉ាក ........ ២២
**កថាខណ្ឌទី២៖ បញ្ហាប្រឈម និងផលប៉ះពាល់ពីការរំលោភបំពានកម្មសិទ្ធិម៉ាក** ........ ២២
ក. បញ្ហាប្រឈមនៃការរំលោភក្នុងតថភាពសង្គម ........ ២២
ខ. ផលប៉ះពាល់ពីការរំលោភបំពានម៉ាក ........ ២៣
គ. ការរាំងស្ទះនៃការការពារម៉ាក ........ ២៤
១. កង្វះខាតចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញា ........ ២៥
២. ភាពព្រងើយកន្តើយរបស់ម្ចាស់ម៉ាក ........ ២៥
៣. ភាពអសកម្មភាពរបស់មន្ត្រីមួយចំនួន ........ ២៦
**កថាខណ្ឌទី៣៖ វិធានការនៃការការពារម៉ាកតាមផ្លូវច្បាប់** ........ ២៦

ក. វិធានការបណ្ដោះអាសន្ន ........................................................ ២៧
១. លក្ខខណ្ឌនៃវិធានការបណ្ដោះអាសន្ន ........................................ ២៧
២. ដំណើរការនៃវិធានការបណ្ដោះអាសន្ន ........................................ ២៧
៣. ការលុបចោលនៃវិធានការបណ្ដោះអាសន្ន ...................................... ២៨
ខ. វិធានការតាមមាត់ច្រកព្រំដែន ...................................................... ២៨
១. តួនាទី និងភារកិច្ចរបស់ម្ចាស់ម៉ាក ................................................ ២៨
២. កាតព្វកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ច ......................................... ២៩
គ. យន្តការស្ដាពរ ............................................................................ ៣០
ឃ. ទណ្ឌកម្មប្រឆាំងនឹងអំពើក្លែងបន្លំម៉ាក ............................................. ៣០
១. សំណងរដ្ឋប្បវេណី ................................................................... ៣០
២. ទោសព្រហ្មទណ្ឌ ..................................................................... ៣២
**ផ្នែកទី២៖ ការរំលោភបំពានសិទ្ធិអ្នកនិពន្ធនៅកម្ពុជា** ........................... ៣២
**កថាខណ្ឌទី១៖ ចរិតលក្ខណៈនៃការរំលោភបំពានសិទ្ធិអ្នកនិពន្ធ** .................. ៣៣
ក. លក្ខណៈនៃអំពើរំលោភបំពានសិទ្ធិអ្នកនិពន្ធ ...................................... ៣៣
១. រូបភាពនៃអំពើរំលោភសិទ្ធិអ្នកនិពន្ធ ............................................. ៣៣
២. ការរំលោភសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ ...................................... ៣៤
ខ. ទិដ្ឋភាពនៃអំពើរំលោភបំពានសិទ្ធិអ្នកនិពន្ធ ...................................... ៣៧
១. មូលហេតុនៃអំពើរំលោភសិទ្ធិរបស់អ្នកនិពន្ធ .................................... ៣៧
២. បុគ្គលពាក់ព័ន្ធនឹងអំពើរំលោភសិទ្ធិរបស់អ្នកនិពន្ធ .............................. ៣៨
**កថាខណ្ឌទី២៖ បញ្ហាប្រឈម និងផលប៉ះពាល់ពីការរំលោភបំពានសិទ្ធិអ្នកនិពន្ធ** ............ ៤១
ក. បញ្ហាប្រឈមនៃការរំលោភសិទ្ធិអ្នកនិពន្ធក្នុងតថភាពសង្គម ........................ ៤១
ខ. ផលប៉ះពាល់នៃការរំលោភសិទ្ធិអ្នកនិពន្ធ .......................................... ៤២
១. ការប៉ះពាល់សិទ្ធិរបស់អ្នកនិពន្ធ ................................................... ៤២
២. ផលអវិជ្ជមានក្នុងវិស័យវប្បធម៌ ................................................... ៤៣

គ. តម្លាភាពនៃការអនុវត្តច្បាប់ ........................................................................ ៤៤
១. អានុភាពនៃការអនុវត្តច្បាប់ ................................................................................ ៤៥
១.១. អានុភាពនៃប្រតិសកម្មនៃច្បាប់............................................................ ៤៥
១.២. ឥទ្ធិពលនៃច្បាប់អន្តរជាតិ.................................................................... ៤៦
២. ការមើលរំលងនៃការអនុវត្តរបស់បុគ្គល ................................................................៤៧
**កថាខណ្ឌទី៣៖ វិធានការការពារសិទ្ធិអ្នកនិពន្ធ** ........................................................ ៤៨
ក. វិធានការជូនដំណឹង ........................................................................................ ៤៨
ខ. វិធានការបណ្តោះអាសន្ន..................................................................................... ៤៨
គ. វិធានការមាត់ច្រកព្រំដែន .................................................................................. ៤៩
ឃ. ទណ្ឌកម្មនៃអំពើរំលោភសិទ្ធិអ្នកនិពន្ធ ................................................................. ៤៩
១. សំណងរដ្ឋប្បវេណី ............................................................................................ ៤៩
២. ទោសព្រហ្មទណ្ឌ.............................................................................................. ៥០
**សេចក្តីសន្និដ្ឋាន** ................................................................................................... ៥១
**អនុសាសន៍** ........................................................................................................... ៥២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

បណ្តាប្រទេសនៅលើពិភពលោក តែងតែមានកត្តាជំរុញដោយពឹងផ្អែកទៅលើវិស័យឯកជន ព្រោះវាជាយានមួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការយកចិត្តទុកដាក់ចំពោះវិស័យនេះ ធ្វើឱ្យប្រទេសអភិវឌ្ឍន៍ជាច្រើនបានចូលខ្លួនជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ហើយប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។ មូលហេតុដែលប្រទេសជាច្រើននៅលើពិភពលោកបង្កើតបទដ្ឋានផ្សេងៗដែលទាក់ទងទៅនឹងកម្មសិទ្ធិបញ្ញា គឺដើម្បីផ្តល់នូវសីលធម៌ក្នុងការប្រកួតប្រជែងក្នុងវិស័យពាណិជ្ជកម្មដោយស្មោះត្រង់។

ម្យ៉ាងវិញទៀត វាជាគោលដៅរបស់រដ្ឋនីមួយៗ ក្នុងការលើកទឹកចិត្តទៅដល់អ្នកធ្វើអាជីវកម្មស្របច្បាប់ក្នុងប្រទេសជាតិរបស់ពួកគេ។ ប្រសិនបើមិនមានការយកចិត្តទុកដាក់លើវិស័យកម្មសិទ្ធិបញ្ញានោះទេ គឺអាចធ្វើឱ្យពាណិជ្ជករមានការខាតបង់ដែលអាចឈានទៅរកភាពក្ស័យធន និងធ្វើឱ្យខាតបង់ចំពោះចំណូលសេដ្ឋកិច្ចជាតិផងដែរ។

ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាយើង រាជរដ្ឋាភិបាលក៏បានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីបញ្ជ្រាបវិស័យពាណិជ្ជកម្មទៅក្នុងគោលនយោបាយរបស់ជាតិ ដើម្បីជំរុញឱ្យមានកំណើនសេដ្ឋកិច្ចជាតិផងដែរ។ ដើម្បីបញ្ជ្រាបវិស័យនេះ ប្រកបដោយប្រសិទ្ធិភាពខ្ពស់ ជាក់ស្តែងកម្ពុជាត្រូវបង្កើត និងបង្កើនទំនាក់ទំនងរវាងវិស័យពាណិជ្ជកម្ម និងគោលនយោបាយជាតិឱ្យមានភាពច្បាស់លាស់ ដើម្បីទាក់ទាញអ្នកវិនិយោគបរទេស និងអ្នកវិនិយោគក្នុងស្រុក។ ទំនាក់ទំនងវិស័យពាណិជ្ជកម្ម និងគោលនយោបាយជាតិ មានន័យថាជាការទាក់ទងគ្នានៃការការពាររវាងស្នាដៃផលិតផល ឬបច្ចេកទេសផ្សេងៗដែលពាណិជ្ជករយកមកធ្វើពាណិជ្ជកិច្ចជាមួយលិខិតបទដ្ឋានរបស់រដ្ឋ។ ដូច្នេះហើយទើបប្រទេសកម្ពុជាបានអនុម័តទៅលើបទដ្ឋានមួយចំនួន ដើម្បីការពារទៅលើសិទ្ធិកម្មសិទ្ធិបញ្ញារបស់អ្នកវិនិយោគទុនដែលបានមកធ្វើការវិនិយោគនៅកម្ពុជា។ ក្រៅពីការដើរតួនាទីជាច្បាប់ដែលសម្របសម្រួលក្នុងវិស័យពាណិជ្ជកម្ម កម្មសិទ្ធិបញ្ញា ក៏ជាច្បាប់ដែលការពារសិទ្ធិរបស់អ្នកនិពន្ធ ចំពោះស្នាដៃរបស់ពួកគេដែលបានបង្កើតឡើង។ កម្មសិទ្ធិបញ្ញារួមមាន កម្មសិទ្ធិឧស្សាហកម្ម និងកម្មសិទ្ធិអក្សរសាស្ត្រ និងសិល្បៈ។

ទោះបីជាប្រទេសកម្ពុជាពឹងផ្អែកទៅលើវិស័យកម្មសិទ្ធិបញ្ញា ចំពោះចំណូលសេដ្ឋកិច្ចជាតិ ក៏ដូចជា សេដ្ឋកិច្ចរបស់បុគ្គលឯកជនក្តី សព្វថ្ងៃនេះ បុគ្គលមួយចំនួនហាក់ដូចជានៅមិនទាន់យល់ច្បាស់អំពីការអនុវត្តនៃច្បាប់កម្មសិទ្ធិបញ្ញានៅឡើយ។ ដើម្បីធានាបាននូវការប្រកួតប្រជែងទៀងត្រង់ ក៏ដូចជាការការពារស្នាដៃរបស់ម្ចាស់សិទ្ធិ ការយល់ដឹងឱ្យកាន់ច្បាស់ពីច្បាប់កម្មសិទ្ធិបញ្ញា ជាពិសេស ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងច្បាប់ស្តីពីសិទ្ធិ

អ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ពិតជាមានសារៈសំខាន់ណាស់សម្រាប់បុគ្គលដែលពាក់ព័ន្ធ ដើម្បីការពារប្រយោជន៍ខាងលើ និងអភិរក្សនូវសមិទ្ធផលដែលកើតចេញពីគំនិតបញ្ញារបស់ខ្លួន។ ដូច្នេះយោងតាមខ្លឹមសារខាងលើ ការយល់ដឹងអំពីច្បាប់កម្មសិទ្ធិបញ្ញាបានផ្តល់ប្រយោជន៍ចំពោះម្ចាស់សិទ្ធិ ថាតើពួកគាត់នឹងទទួលបានការការពារអ្វីខ្លះក្នុងករណីដែលមានការរំលោភបំពានទៅលើស្នាដៃរបស់ពួកគាត់ ក៏ដូចជានៅពេលដែលមានអំពើនោះកើតឡើង តើច្បាប់កម្មសិទ្ធិបញ្ញាមានវិធានការយ៉ាងដូចម្តេច ហើយវាមានផលប៉ះពាល់យ៉ាងណាខ្លះទៅដល់សង្គម ក៏ដូចជាម្ចាស់សិទ្ធិផ្ទាល់។

គោលបំណងនៃការស្រាវជ្រាវប្រធានបទមួយនេះ គឺដើម្បីពង្រីកការយល់ដឹងពីសិទ្ធិកម្មសិទ្ធិបញ្ញានៅកម្ពុជា ជាពិសេសផលប្រយោជន៍នៃការលើកស្ទួយវិស័យកម្មសិទ្ធិបញ្ញាជាតិ បញ្ហាប្រឈមនៃការរំលោភបំពានស្នាដៃរបស់ម្ចាស់សិទ្ធិ ក៏ដូចជាស្វែងយល់ពីតម្លាភាពនៃការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាដែលមានកំណត់ទាំងក្នុងយន្តការច្បាប់ជាតិ និងយន្តការច្បាប់អន្តរជាតិ ទើបយើងខ្ញុំជ្រើសរើសប្រធានបទ "**ការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញានៃម៉ាក និងសិទ្ធិអ្នកនិពន្ធនៅកម្ពុជា**" នេះ។ ប្រធានបទស្រាវជ្រាវមួយនេះ នឹងធ្វើការសិក្សាផ្តោតសំខាន់ទៅលើសិទ្ធិឧស្សាហកម្មនៃម៉ាក និងសិទ្ធិអក្សរសាស្ត្រ និងសិល្បៈនៃសិទ្ធិអ្នកនិពន្ធតែប៉ុណ្ណោះ ដោយផ្អែកទៅលើទិដ្ឋភាពសង្គមនៃកិច្ចអនុវត្តន៍ច្បាប់របស់កម្ពុជា ដោយលើកឡើងពីបទប្បញ្ញត្តិនានា ដែលទាក់ទងទៅនឹងការការពារ និងវិធានការទប់ស្កាត់ការរំលោភបំពានលើម៉ាក និងសិទ្ធិអ្នកនិពន្ធ ទាំងក្រោមយន្តការច្បាប់ជាតិ និងយន្តការច្បាប់អន្តរជាតិ។ បន្ថែមពីនេះទៅទៀត ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ដោយកំណត់វិសាលភាពយកត្រឹមតែម៉ាកដែលជាផ្នែកនៃកម្មសិទ្ធិឧស្សាហកម្ម និងសិទ្ធិអ្នកនិពន្ធដែលជាផ្នែកនៃកម្មសិទ្ធិអក្សរសាស្ត្រ និងសិល្បៈ ដោយបានកំណត់នៅពេលដែលកម្ពុជាបានបង្កើត និងអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា។

នៅក្នុងប្រធានបទស្រាវជ្រាវមួយនេះនឹងធ្វើការលើកឡើងអំពី (១) ផលប្រយោជន៍នៃកម្មសិទ្ធិបញ្ញានៅកម្ពុជា ដែលធ្វើការសិក្សាអំពីសញ្ញាណទូទៅនៃម៉ាក និងសិទ្ធិអ្នកនិពន្ធ ដើម្បីជួយឱ្យអ្នកអានបានដឹងជាមុននូវលក្ខណៈទូទៅនៃកម្មសិទ្ធិបញ្ញា រួមជាមួយផលប្រយោជន៍នៃកម្មសិទ្ធិបញ្ញា និង (២) ផលប៉ះពាល់នៃការរំលោភបំពានកម្មសិទ្ធិបញ្ញានៅកម្ពុជា ដោយលើកឡើងអំពីរូបភាពនៃអំពើរំលោភបំពានសិទ្ធិ រួមជាមួយបញ្ហាប្រឈមចម្បងដែលកើតចេញពីអំពើរំលោភបំពានកម្មសិទ្ធិបញ្ញានេះ។

# ជំពូកទី១
# ផលប្រយោជន៍នៃកម្មសិទ្ធិបញ្ញានៅកម្ពុជា

## ផ្នែកទី១៖ ផលប្រយោជន៍នៃម៉ាកនៅកម្ពុជា

នាពេលបច្ចុប្បន្ន ប្រទេសកម្ពុជាកំពុងមានភាពរីកចម្រើនក្នុងវិស័យកម្មសិទ្ធិបញ្ញា ជាពិសេសប្រជាជនកម្ពុជា មានការពេញនិយមទៅនឹងប្រភេទម៉ាកល្បីៗដែលភាគច្រើន គឺជាម៉ាកដែលនាំចូលមកពីបរទេស ដោយសារតែពួកគេមានប្រាក់ចំណូលកាន់ខ្ពស់ និងជីវភាពកាន់តែប្រសើរ។ ដូចនេះការស្វែងយល់អំពីផលប្រយោជន៍របស់ម៉ាកសម្រាប់ប្រទេសកម្ពុជា (កថាខណ្ឌទី២) គឺជាការចាំបាច់ដែលប្រជាជនកម្ពុជាគួរយល់ដឹង។ ប៉ុន្តែ ដើម្បីអាចធ្វើការបកស្រាយអំពីផលប្រយោជន៍របស់ម៉ាកយើងគួរគប្បីសិក្សាអំពីសញ្ញាណនៃម៉ាក (កថាខណ្ឌទី១) ឱ្យបានច្បាស់លាស់ជាមុនសិន។

### កថាខណ្ឌទី១៖ សញ្ញាណទូទៅនៃម៉ាក

ម៉ាកត្រូវបានប្រើប្រាស់គ្របដណ្តប់ទៅលើទំនិញ និងសេវា។ ម៉ាក សំដៅដល់សញ្ញាដែលអាចមើលឃើញ ហើយអាចសម្គាល់ភាពខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ។[១] ម៉ាកអាចត្រូវបានបង្កើតឡើងបានក្នុងលក្ខណៈជាអក្សរ លេខ ពាក្យ រូបសញ្ញា ឬនិមិត្តសញ្ញា(Logo) ការរួមបញ្ចូលគ្នានៃពាក្យនិងលេខ ការរួមបញ្ចូលគ្នានៃអក្សរនិងរូបសញ្ញា ពណ៌ ការរួមបញ្ចូលគ្នានៃពណ៌ ឈ្មោះ ទម្រង់បីវិមាត្រ ហត្ថលេខា ពាក្យស្លោក ជាដើម។ នៅពេលដែលយកម៉ាកមកប្រើប្រាស់លើទំនិញហៅថា "**ពាណិជ្ជសញ្ញា**"។

ឧទាហរណ៍៖ ម៉ាក “DELL” ជាពាណិជ្ជសញ្ញាដែលត្រូវបានប្រើប្រាស់លើផលិតផលអេឡិចត្រូនិច។

ចំណែកឯ ម៉ាកដែលប្រើទៅលើផ្នែកសេវាកម្ម ត្រូវបានគេហៅថា "**សេវាសញ្ញា**" ។

ឧទាហរណ៍៖ ម៉ាក “DHL” ជាសេវាសញ្ញា ដែលត្រូវប្រើប្រាស់សម្រាប់ផ្តល់សេវារបស់ក្រុមហ៊ុនដឹកជញ្ជូន។

ពោលអតិថិជនទូទៅ អាចធ្វើការកត់សម្គាល់យ៉ាងងាយស្រួលនូវប្រភេទនៃម៉ាក ជាពាណិជ្ជសញ្ញា ឬសេវាសញ្ញា ដោយផ្អែកទៅលើទំនិញ ឬសេវាដែលពាក់ម៉ាកនោះ។ យោងតាមនិយមន័យនៃច្បាប់ម៉ាក អ្វីដែលអាចចាត់ទុកជាម៉ាកបានគឺ "សញ្ញាដែលមើលឃើញ" ឬច្បាប់ទទួលស្គាល់តែសញ្ញាដែលមើលឃើញតែប៉ុណ្ណោះ ដែលអាចចុះបញ្ជីជាម៉ាកបាន ហើយសញ្ញាដែលមិនអាចមើលឃើញមិនអាចត្រូវបានចាត់ទុកថាជាម៉ាកក្រោមច្បាប់របស់ប្រទេសកម្ពុជាឡើយ។ ម្យ៉ាងវិញទៀត

[១] ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់,០៧ កុម្ភៈ ២០០២, មាត្រា២ (ចំណុចក)

ម៉ាកមានគោលដៅសម្រាប់សម្គាល់ភាពខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសប៉ុណ្ណោះ នេះមានន័យថាមានតែនីតិបុគ្គល (ក្រុមហ៊ុនពាណិជ្ជកម្ម) ប៉ុណ្ណោះដែលអាចក្លាយជាម្ចាស់ម៉ាក ដោយយោងតាមច្បាប់របស់កម្ពុជា។ ដូចនេះ តើម៉ាកមានប្រភេទអ្វីខ្លះ? ហើយតើម្ចាស់ម៉ាកត្រូវទទួលបានការការពារដោយរបៀបណា?

**ក. ប្រភេទនៃម៉ាក**

នៅក្នុងពាណិជ្ជសញ្ញារួមមាន ម៉ាក ម៉ាកសមូហភាព(Collective Mark) និងពាណិជ្ជនាម។ ម៉ាកអាចសម្តែងឡើងក្រោមទម្រង់ដូចជា៖

- ម៉ាកជាពាក្យ រួមមានឈ្មោះក្រុមហ៊ុន នាមត្រកូល ឈ្មោះទីតាំងភូមិសាស្ត្រណាមួយ ឬជាការបញ្ចូលនៃពាក្យមួយក្រុម ។ល។

  ឧទាហរណ៍៖ Coca-Cola ជាម៉ាកដែលតំណាងឱ្យភេសជ្ជៈរបស់ក្រុមហ៊ុនកូកា-កូឡា។
- ម៉ាកជាអក្សរ អាចជាអក្សរមួយ ឬការរួមបញ្ចូលអក្សរជាច្រើន។

  ឧទាហរណ៍៖ Canon ជាម៉ាកដែលតំណាងឱ្យផលិតផលអេឡិចត្រូនិច។
- ម៉ាកជាលេខ អាចមានលេខមួយ ឬលេខច្រើន ។

  ឧទាហរណ៍៖  ជាសញ្ញាដែលតំណាងឱ្យផលិតផលថ្នាំជក់ (បារី)។
- ម៉ាកជារូបសញ្ញា គឺជារូបភាពមួយប្លែក ដែលមានលក្ខណៈពិសេសបង្កប់នូវអត្ថន័យរបស់ផលិតផល ឬក៏ជាសញ្ញាសម្គាល់អ្វីមួយដែលដាក់នៅលើទំនិញ ឬសេវា។

  ឧទាហរណ៍៖ រូបផ្លែប៉ោម គឺជានិមិត្តសញ្ញាដែលបានប្រើប្រាស់ក្នុងក្រុមហ៊ុន Apple
- ម៉ាកជានិមិត្តសញ្ញា គឺជាសញ្ញាដែលមានក្បូរក្បាច់ មានរូបតំណាង ឬអាចជាការផ្តុំបញ្ចូលគ្នាជាឡូហ្គូ លេខ អក្សរ ជាដើម។

  ឧទាហរណ៍៖ ជាសញ្ញា ដែលត្រូវបានប្រើប្រាស់លើផលិតផលកាម៉េរ៉ាឌីជីថល។
- ម៉ាកជាស្លាកសញ្ញា ដែលមានប្រភេទខុសៗគ្នា អាចជាក្រដាស ផ្លាស្ទិច ក្រណាត់ អំបោះ ស្បូត្រ នៅលើស្លាកសញ្ញានោះអាចមានអក្សរ ឬឡូហ្គូផងដែរ។

  ឧទាហរណ៍៖ 

- ការរួមបញ្ចូលគ្នានៃពាក្យ អក្សរ លេខ និមិត្តសញ្ញា ស្លាកសញ្ញា ឈ្មោះ និងហត្ថលេខា (Combinations Thereof) ។

  ឧទាហរណ៍៖ RAYON BAKERY Kodak EXPRESS

- ម៉ាកអាចជាពណ៌ ឬពណ៌ច្រើនចម្រុះគ្នា ឬពណ៌ដែលមានបែបផែនត្រឹមត្រូវហើយមិនអាចលាយបានដោយងាយ។ ពោលគឺ ពណ៌ដែលម្ចាស់ម៉ាកអាចប្រើផ្តាច់មុខបាន លុះត្រាតែពណ៌នោះ មានការច្នៃប្រឌិតមានភាពពិតប្រាកដដែលវាបង្ហាញនូវសារៈសំខាន់ចំពោះពាណិជ្ជនាម។

ឧទាហរណ៍៖

- ម៉ាកជាសញ្ញាដែលអាចឆ្លុះបីជ្រុង (Three dimensional sign) អាចជារូបរាងនៃទំនិញ ឬការវេចខ្ចប់របស់ទំនិញ។

ឧទាហរណ៍ ៖ 

- ម៉ាកជាឈ្មោះ ឬជាហត្ថលេខា

ឧទាហរណ៍៖ , 

ដូចនេះ យើងអាចនិយាយបានថាម៉ាក គឺជាសញ្ញាដែលបានផ្តល់ឯកត្តភាពដល់ទំនិញនៃសហគ្រាសនានា និងអាចធ្វើការបែងចែកប្រភេទទំនិញបានថែមទៀត។

**ខ. គោលការណ៍នៃកិច្ចការពារម៉ាក**

ម៉ាក មិនត្រូវបានការពារដោយស្វ័យប្រវត្តិនោះទេ ហេតុនេះហើយ ម៉ាកដែលទទួលបានការការពារ លុះត្រាតែម៉ាកនោះបានចុះបញ្ជី ទើបអាចប្រើសិទ្ធិផ្តាច់មុខបាន។[២] គោលការណ៍ "First to file" ត្រូវយកមកអនុវត្តន៍ គឺអ្នកចុះបញ្ជីមុននឹងទទួលបានការការពារជាអាទិភាព។ ម្ចាស់ម៉ាកអាចដាក់ពាក្យសុំចុះបញ្ជីម៉ាក នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ដោយត្រូវបំពេញតាមលក្ខខណ្ឌទាំងឡាយតាមច្បាប់កំណត់៖ លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៃការចុះបញ្ជីម៉ាក។ យោងតាមមាត្រា ២(១) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ អាចត្រូវបានចាត់ទុកជាម៉ាក និងអាចទទួលបានការការពារ លុះត្រាតែម៉ាកជាសញ្ញាអាចមើលឃើញហើយផ្ទុយពីទំនិញ ឬសេវា។ ដូច្នេះ ក្លិន សម្លេង រសជាតិ មិនអាចចាត់ទុកជាម៉ាកដែលទទួលបានការការពារក្នុងក្របខ័ណ្ឌនៃច្បាប់របស់កម្ពុជាឡើយ។

ច្បាប់បានហាមមិនឱ្យចុះបញ្ជីបានទេ ចំពោះម៉ាកមួយចំនួន ដែលមានលក្ខណៈដូចជា៖[៣]

- ម៉ាកដែលមិនអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវា របស់សហគ្រាសមួយទៅ

[២] ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់,០៧ កុម្ភៈ ២០០២, មាត្រា ៣
[៣] ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់,០៧ កុម្ភៈ ២០០២,មាត្រា ៤

សហគ្រាសមួយផ្សេងទៀត។

- ម៉ាកដែលបណ្ដាលឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីដ៏ល្អរបស់ជាតិ។
- ម៉ាកដែលអាចនាំឱ្យសាធារណជន ឬមជ្ឈដ្ឋានពាណិជ្ជកម្មភាន់ច្រឡំទៅនឹងប្រភពភូមិសាស្ត្រនៃទំនិញ ឬសេវាពាក់ព័ន្ធ ឬធាតុដើម ឬលក្ខណៈខាងក្រៅរបស់ទំនិញ ឬសេវានោះ។
- ម៉ាកដែលដូចគ្នា និង/ឬត្រាប់តាម ឬមានចំណុចណាមួយដូចសញ្ញាជាតិ ទង់ជាតិ និងនិមិត្តរូបផ្សេងៗ ឈ្មោះ ឬឈ្មោះសង្ខេប ឬអក្សរកាត់នៃឈ្មោះ ឬសញ្ញា ឬត្រាជាផ្លូវការដែលអនុម័តដោយរដ្ឋណាមួយ អង្គការអន្តររដ្ឋាភិបាល ឬអង្គការដែលបង្កើតដោយអនុសញ្ញាអន្តរជាតិមួយ លើកលែងតែមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនោះ ឬអង្គការនោះ។
- ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បីក្នុងព្រះរាជាណាចក្រកម្ពុជា ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ ហើយដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ទំនិញ ឬសេវាដែលមិនដូចគ្នា ឬមិនប្រហាក់ប្រហែលគ្នាដោយការប្រើប្រាស់ម៉ាកនោះធ្វើឱ្យខូចប្រយោជន៍របស់ម្ចាស់នៃម៉ាកល្បី។
- ម៉ាកដែលដូចគ្នា ឬស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងម៉ាក ដែលជាកម្មសិទ្ធិរបស់ម្ចាស់ផ្សេងដែលបានចុះបញ្ជីរួចហើយ ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីមុន ឬបានទទួលអាទិភាពចុះបញ្ជីមុននៅឯបរទេស ចំពោះទំនិញ ឬសេវាដូចគ្នា ឬទំនិញ ឬសេវា ដែលមានលក្ខណៈពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ។

ម៉ាកដែលបានចុះបញ្ជីហើយ ត្រូវបានទទួលការការពារក្នុងរយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះបញ្ជី ហើយតាមការស្នើសុំ ការចុះបញ្ជីម៉ាកមួយអាចធ្វើឡើងសារជាថ្មី សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំម្តង ជាបន្តបន្ទាប់ដោយឥតកំណត់។ ចំពោះពាក្យស្នើសុំចុះបញ្ជីឡើងវិញ ជាគោលការណ៍ គេអាចត្រូវបញ្ជូនទៅឱ្យមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ៦ (ប្រាំមួយ) ខែមុនពេលផុតកំណត់សុពលភាពនៃម៉ាកដែលបានចុះបញ្ជីរួច។ ច្បាប់ម៉ាកក៏បានកំណត់អំពីរយៈពេលដែលត្រូវបានអនុគ្រោះដល់ម្ចាស់ម៉ាក ដែលពុំបានដាក់ពាក្យស្នើសុំចុះបញ្ជីសារជាថ្មីក្នុងរយៈពេលកំណត់អាចដាក់ពាក្យស្នើសុំចុះបញ្ជីសារជាថ្មីក្នុងរយៈពេល ៦ (ប្រាំមួយ) ខែចាប់ពីថ្ងៃអស់សុពលភាពនៃម៉ាក។[៤] លើសពីនេះទៅទៀត ច្បាប់ម៉ាកនៃប្រទេសកម្ពុជា ក៏បានចែងអំពីអានុភាពប្រតិសកម្មផងដែរ ដោយអនុញ្ញាតឱ្យធ្វើការចុះបញ្ជីសារឡើងវិញសម្រាប់ម៉ាកដែលបាន

[៤] ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់,០៧ កុម្ភៈ ២០០២, មាត្រា១២

ចុះបញ្ជីមុនពេលច្បាប់ចូលជាធរមាន (មុនឆ្នាំ២០០២)។

**កថាខណ្ឌទី២៖ ផលប្រយោជន៍នៃម៉ាកនៅកម្ពុជា**

ជាគោលការណ៍ រដ្ឋបានបង្កើតច្បាប់កម្មសិទ្ធិបញ្ញា គឺក្នុងគោលបំណងលើកទឹកចិត្តដល់សកម្មភាពនៃការបង្កើតស្នាដៃថ្មី និងជំរុញឱ្យមានភាពស្មើគ្នាក្នុងការធ្វើពាណិជ្ជកិច្ច ជាពិសេសលើកតម្កើងដល់ការអភិវឌ្ឍធនធានមនុស្ស សង្គម និងសេដ្ឋកិច្ចជាតិ។ ម៉ាក ក៏ដូចជាកម្មសិទ្ធិបញ្ញាដទៃទៀតដែរ គឺផ្ដល់នូវសិទ្ធិទាំងផ្នែកសីលធម៌ ផ្នែកសេដ្ឋកិច្ចដល់អ្នកបង្កើតស្នាដៃថ្មី និងផ្ដល់ដល់សាធារណជននូវសិទ្ធិទទួលបានការប្រើប្រាស់ស្នាដៃដែលបានបង្កើតថ្មីទាំងនោះ។

**ក. ផលប្រយោជន៍នៅក្នុងវិស័យសេដ្ឋកិច្ច**

**១. ចំពោះសេដ្ឋកិច្ចជាតិ**

ថ្វីត្បិតតែកម្ពុជាជាប្រទេសដែលមានការអភិវឌ្ឍទាបជាងប្រទេសអភិវឌ្ឍន៍ដទៃទៀតក្ដី ក៏ប៉ុន្តែកម្ពុជាក៏បានទទួលផលប្រយោជន៍ភាគច្រើនពីការធានាការសន្យាបន្ទាប់ពីការចូលជាសមាជិករបស់ WTO (World Trade Organization) ដែលបានផ្ដល់នូវក្របខ័ណ្ឌមួយសម្រាប់កែទម្រង់សេដ្ឋកិច្ច និងកំណែទម្រង់ដទៃទៀត ដែលនឹងជួយប្រទេសកម្ពុជាឱ្យមានលទ្ធភាពក្នុងការប្រកួតប្រជែងក្នុងទីផ្សារបរទេស ទន្ទឹមនឹងនេះ សមាជិកភាពនេះក៏បានផ្ដល់បរិយាកាសដ៏ល្អក្នុងការទាក់ទាញការវិនិយោគទាំងវិនិយោគិនក្នុងស្រុក និងការវិនិយោគផ្ទាល់ពីបរទេសផងដែរ។ ក្រៅពីនេះ កម្ពុជាក៏បានបង្កើត "ច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់" ដែលត្រូវបានអនុម័ត និងចូលជាធរមាននៅថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ២០០២។ ដោយគោលបំណងនៃការបង្កើត គឺដើម្បីការពារម៉ាក និងពាណិជ្ជនាមដែលត្រូវបានចុះបញ្ជីស្របច្បាប់ក្នុងប្រទេសកម្ពុជា។

ដោយសារវិស័យម៉ាកកំពុងមានការរីកចម្រើន បានជំរុញឱ្យមានការកើនឡើងនូវទំហំនៃការវិនិយោគចូលមកក្នុងប្រទេសកម្ពុជា ពោលគឺបានទាក់ទាញវិនិយោគទុនជាម្ចាស់ម៉ាកល្បីៗឱ្យមកបណ្ដាក់ទុនធ្វើអាជីវកម្មនៅប្រទេសកម្ពុជាកាន់តែច្រើន និងប្រសើរជាលំដាប់។ ជាក់ស្ដែង លទ្ធផលនេះបានស្ដែងឱ្យឃើញតាមរយៈពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងឆ្នាំ ២០១៨ សរុបចំនួន ៥.៨៤២ បើធៀបនឹងឆ្នាំ ២០១៧ មានការកើនឡើង ១៦% ( ៥.១២៣ ក្នុងឆ្នាំ ២០១៧) ក្នុងនោះម៉ាកដែលបានការអនុញ្ញាតចុះបញ្ជីមានចំនួន ៤.១៨៦ ម៉ាក មានការកើនឡើង ៦% បើធៀបទៅនឹងឆ្នាំ ២០១៧ ដែលមានសរុប ៣.៩១៧ ម៉ាក។[៥] ទិន្នន័យនេះ អាចឆ្លុះបញ្ចាំងឱ្យឃើញពីផលប្រយោជន៍ជូនជាតិ ដោយការប្រមូលពន្ធចូលរដ្ឋតាមរយៈការបង់កម្រៃចុះបញ្ជីពីសំណាក់អ្នកដាក់ពាក្យស្នើសុំ។ ដូចនេះ កម្រៃដែលទទួលបានមកពីការចុះបញ្ជី វាក៏ជាផ្នែកមួយនៃប្រភពចំណូលដ៏សំខាន់សម្រាប់ទ្រទ្រង់

[៥] របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ ២០១៨ និងទិសដៅអនុវត្តន៍ការងារឆ្នាំ ២០១៩ នៃក្រសួងពាណិជ្ជកម្ម

សេដ្ឋកិច្ចជាតិ និងសម្រាប់យកទៅអភិវឌ្ឍន៍ប្រទេសទៅតាមតម្រូវការចាំបាច់ចំពោះមុខស្របតាមគោលនយោបាយជាតិ។

**២. ទំនាក់ទំនងពាណិជ្ជកម្ម**

ការរីកចម្រើននៃម៉ាកក្នុងសកម្មភាពពាណិជ្ជកម្ម គឺដោយសារតែការកើនឡើងនៃការប្រកួតប្រជែងក្រុមហ៊ុនក្នុងការធ្វើពាណិជ្ជកម្មក្នុងប្រទេសជាច្រើន។ ម៉ាក ត្រូវបានប្រើដើម្បីកំណត់អត្តសញ្ញាណយ៉ាងសាមញ្ញាតាមរយៈអ្នកប្រើប្រាស់ទំនិញ ឬសេវា ព្រមទាំងគុណភាព និងតម្លៃ។ ដូចនេះ ម៉ាកមួយអាចចាត់ទុកថាជាចំណុចសំខាន់នៃការទំនាក់ទំនងដែលបានប្រើប្រាស់ ដោយអ្នកផលិតដើម្បីទាក់ទាញអ្នកប្រើប្រាស់ទំនិញ។

កម្មសិទ្ធិបញ្ញាក៏បានដើរតួនាទីយ៉ាងសំខាន់ ដើម្បីលើកកម្ពស់វិស័យពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា ជាពិសេស សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ដែលមានសមត្ថភាព និងមានភាពច្នៃប្រឌិតសម្រាប់ផលិតផលរបស់ពួកគេ ដើម្បីការពារកម្មសិទ្ធិបញ្ញានៅពេលដែលបានចុះបញ្ជីការពារពាណិជ្ជសញ្ញារបស់ពួកគេរួច។

ជាងនេះទៅទៀត កិច្ចព្រមព្រៀងនៃអង្គការពាណិជ្ជកម្មពិភពលោកស្តីពីបញ្ហាកម្មសិទ្ធិបញ្ញាទាក់ទងនឹងពាណិជ្ជកម្ម TRIPs បានទាមទារឱ្យសមាជិកទាំងឡាយគោរពតាមស្តង់ដារអន្តរជាតិក្នុងកម្រិតអប្បបរមា ហើយប្រទេសកម្ពុជាបានប្តេជ្ញាចិត្តប្រតិបត្តិទាំងស្រុងតាមកិច្ចព្រមព្រៀងស្តីពីបញ្ហាកម្មសិទ្ធិបញ្ញាទាក់ទងនឹងពាណិជ្ជកម្ម ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ មកម្ល៉េះ។

**ខ. ផលប្រយោជន៍នៃម៉ាកនៅក្នុងសង្គម**

**១. ផលប្រយោជន៍សម្រាប់ម្ចាស់សិទ្ធិ ឬម្ចាស់ស្នាដៃ**

ការការពារម៉ាក ជាកម្លាំងចលករមួយដ៏សំខាន់ក្នុងការលើកទឹកចិត្តដល់ម្ចាស់ម៉ាកក្នុងការបង្កើតស្នាដៃថ្មីរបស់ពួកគាត់។ ក្នុងការបង្កើតស្នាដៃនីមួយៗ គឺមានការលំបាកណាស់ទម្រាំតែលេចចេញជារូបរាងត្រូវចំណាយទាំងពេលវេលា គំនិត និងថវិកា ជាពិសេសម្ចាស់ស្នាដៃនោះត្រូវប្រឹងអស់ទាំងកម្លាំងកាយចិត្ត ដើម្បីយកចិត្តទុកដាក់ទៅលើស្នាដៃរបស់គាត់។ នៅពេលដែលស្នាដៃថ្មីៗទាំងនោះត្រូវបានបង្កើតឡើង ម្ចាស់ស្នាដៃត្រូវធ្វើតាមនីតិវិធីនៃច្បាប់ដោយដាក់ស្នើសុំចុះបញ្ជី ដើម្បីឱ្យផលិតផលរបស់គាត់ទទួលបានការការពារ។ ម្យ៉ាងវិញទៀត គាត់ត្រូវចំណាយថវិកាជាច្រើនដើម្បីផ្សព្វផ្សាយនូវស្នាដៃរបស់ខ្លួនធ្វើយ៉ាងណាឱ្យមានភាពទាក់ទាញពីសំណាក់អតិថិជន ដើម្បីឱ្យស្នាដៃរបស់គាត់មានគេស្គាល់ច្រើន ក៏ដូចជាមានការគាំទ្រកាន់តែច្រើនផងដែរ។ លើសពីនេះទៅទៀត ម្ចាស់ដើម ឬម្ចាស់សិទ្ធិក៏មានសិទ្ធិបេតិកភណ្ឌលើម៉ាកនោះ ដែលសិទ្ធិបេតិកភណ្ឌនេះសំដៅទៅលើសិទ្ធិអនុញ្ញាតឱ្យម្ចាស់ម៉ាកនោះ អាចប្រើប្រាស់ម៉ាករបស់ខ្លួន ដើម្បីសម្គាល់នូវទំនិញ ឬសេវា

របស់ខ្លួន។[៦] ការទទួលស្គាល់ និងព្រមផ្តល់កិច្ចការពារដល់ម្ចាស់ម៉ាកក្នុងការប្រើប្រាស់ម៉ាកនោះលើ ទំនិញ ឬសេវារបស់ខ្លួន បើទោះបីជាច្បាប់ពុំបានចែងនូវរូបភាពនៃបម្រើបម្រាស់សិទ្ធិនេះថាយ៉ាង ដូចម្តេចខ្លះក៏ដោយ ក៏ប៉ុន្តែបើផ្អែកតាមតួនាទីនៃម៉ាកដូចបានកំណត់នៅក្នុងនិយមន័យនៃម៉ាក ការ ប្រើប្រាស់ម៉ាកនេះមានន័យថា ម្ចាស់ម៉ាកអាចផលិតម៉ាកនោះសារជាថ្មី បិទម៉ាក ធ្វើអាជីវកម្ម ឬលុប ចោលម៉ាកនោះបាន ចំពោះផលិតផលជាទំនិញ ឬសេវា ដែលម្ចាស់ម៉ាកបានយកទៅចុះបញ្ជីស្រប ច្បាប់។ ជាងនេះទៅទៀត ដោយហេតុថាម៉ាកជាទ្រព្យអរូបិយ ម្ចាស់ម៉ាកអាចដាក់បញ្ចាំទ្រព្យនេះ ដើម្បីទទួលបាននូវដើមទុនក្នុងការពង្រីកអាជីវកម្ម ឬអភិវឌ្ឍន៍ពាណិជ្ជកម្ម និងអាចធ្វើមូលនិធិ ពាណិជ្ជកម្មសម្រាប់សហគ្រាស។ សិទ្ធិទាំងនេះនឹងត្រូវបានផ្តល់ចំពោះតែម្ចាស់ម៉ាកតែម្នាក់គត់ ហើយបុគ្គលដទៃផ្សេងពីម្ចាស់ម៉ាកពុំអាចបំពានសិទ្ធិទាំងនេះ តាមរយៈការប្រើប្រាស់ម៉ាកដែលខ្លួន គ្មានសិទ្ធិនោះបានឡើយ។

ដូចនេះ សិទ្ធិប្រើប្រាស់ម៉ាកដោយម្ចាស់ម៉ាកខ្លួនឯងផ្ទាល់ ក៏បានបង្កប់ផងដែរនូវចរិតលក្ខណៈ ជាសិទ្ធិកម្មសិទ្ធិ និងក៏អាចប្រើប្រាស់ផ្តាច់មុខនៅលើទឹកដីនៃរដ្ឋដែលទទួលយកព្រមចុះបញ្ជីម៉ាក នោះ។

### ២. ផលប្រយោជន៍សម្រាប់អ្នកប្រើប្រាស់

ការការពារម៉ាកមិនមែនត្រឹមតែផ្តល់ផលប្រយោជន៍ជូនចំពោះតែម្ចាស់ម៉ាកប៉ុណ្ណោះទេ វាក៏ បាន ផ្តល់ផលប្រយោជន៍ដល់អ្នកប្រើប្រាស់ផងដែរ។ ផលិតផលមួយដែលបានបង្កើតឡើង ត្រូវ ឆ្លងកាត់ការត្រួតពិនិត្យយ៉ាងល្អិតល្អន់ជាមុនសិន ទើបអនុញ្ញាតឱ្យដាក់ធ្វើអាជីវកម្មនៅលើទីផ្សារ ដើម្បីធានាទៅដល់សុវត្ថិភាពចំពោះអ្នកប្រើប្រាស់ ផ្ទុយទៅវិញ ទំនិញមួយចំនួនដែលមិនបានឆ្លង កាត់ការត្រួតពិនិត្យ ហើយមានការក្លែងបន្លំដូចទៅនឹងទំនិញពិតប្រាកដនឹងមិនត្រូវបានអនុញ្ញាត ឬ ត្រូវហាមឃាត់មិនឱ្យធ្វើអាជីវកម្មផលិតផលនោះលើទីផ្សារឡើយ។ ជាពិសេស វាបានជួយឱ្យអតិថិ ជនឱ្យបានដឹងនូវទំនិញដែលមានគុណភាព ធ្វើឱ្យពួកគេជ្រើសរើសនូវទំនិញដែលពួកគេចង់ប្រើ ប្រាស់ និងយល់ដឹងកាន់តែច្បាស់អំពីម៉ាកនៃផលិតផលនីមួយៗ ពោលការការពារម៉ាក បានបង្កឱ្យ មានលក្ខណៈងាយស្រួលដល់អ្នកប្រើប្រាស់ក្នុងការចំណាំផលិតផលពិតប្រាកដ ដោយមិនធ្វើឱ្យ មានការភាន់ច្រឡំទៅនឹងផលិតផលពាក់ម៉ាកក្លែងបន្លំ។ ដូចនេះ អ្នកប្រើប្រាស់ ដែលបានជ្រើស រើសយកផលិតផល ឬសេវាកម្មដែលបានឆ្លងកាត់ការត្រួតពិនិត្យ ឬទទួលបានការចុះបញ្ជីត្រឹមត្រូវ និងមិនប៉ះពាល់ដល់សុខភាពឡើយ ឬមានទំនុកចិត្តខ្ពស់ចំពោះផលិតផល ឬសេវាកម្មទាំងនោះ។

[៦] ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់,០៧ កុម្ភៈ ២០០២, មាត្រា១១(ចំណុចក)។

## ផ្នែកទី២៖ ផលប្រយោជន៍នៃសិទ្ធិអ្នកនិពន្ធនៅកម្ពុជា

ដោយសារប្រទេសកម្ពុជាកំពុងតែមានការរីកចម្រើនស្ទើរគ្រប់វិស័យ ធ្វើឱ្យការងារតែងនិពន្ធមានការប្រសើរឡើងជាងមុនផងដែរ។ អ្នកបង្កើតស្នាដៃនានា បានចាប់ផ្តើមគិតគូរអំពីសិទ្ធិទៅលើស្នាដៃថ្មីៗរបស់ពួកគេយ៉ាងផុសផុលគួរឱ្យកត់សម្គាល់ ទោះបីជាការរំលោភបំពានទៅលើសិទ្ធិរបស់អ្នកនិពន្ធនៅតែបន្តកើតមានក្រោមរូបភាពផ្សេងៗគ្នាយ៉ាងណាក៏ដោយ។ ដូចនេះ ការសិក្សាឱ្យបានច្បាស់លាស់អំពីសិទ្ធិអ្នកនិពន្ធ (កថាខណ្ឌទី១) គឺជាបញ្ហាចាំបាច់ ហើយការយល់ដឹងអំពីផលប្រយោជន៍នៃសិទ្ធិអ្នកនិពន្ធក៏កាន់តែចាំបាច់ថែមទៀត (កថាខណ្ឌទី២) ដើម្បីជាកម្លាំងចិត្តដល់អ្នកដែលប្រឹងប្រែងបង្កើតស្នាដៃថ្មីៗទាំងនោះ។

### កថាខណ្ឌទី១៖ សញ្ញាណទូទៅនៃសិទ្ធិអ្នកនិពន្ធ

សិទ្ធិអ្នកនិពន្ធ គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិទាំងឡាយនៃកម្មសិទ្ធិបញ្ញា ដែលអ្នកនិពន្ធបានបង្កើតឡើងនៅក្នុងការតាក់តែងនិពន្ធផ្សេងៗ គំនូរ ស្នាដៃស្ថាបត្យកម្ម និងស្នាដៃជាច្រើនផ្សេងទៀត។ សិទ្ធិអ្នកនិពន្ធ ជាសិទ្ធិរបស់ម្ចាស់ស្នាដៃក្នុងការទទួលបាននូវកិច្ចការពារស្របច្បាប់លើស្នាដៃរបស់ខ្លួនដែលត្រូវបានបង្កើតឡើងដោយបញ្ញាស្មារតី និងមនោសញ្ចេតនារបស់អ្នកនិពន្ធ។ ស្នាដៃអ្នកនិពន្ធ ត្រូវបានការពារស្របច្បាប់នៅពេលដែលស្នាដៃនោះត្រូវបានបង្កើតឡើងជាស្នាដៃរូបិយ។

#### ក. ស្ថានភាពគតិយុត្តនៃការកំណត់ឋានៈអ្នកនិពន្ធ

ក្នុងការកំណត់គុណភាពជាអ្នកនិពន្ធស្នាដៃមួយ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានបង្កើតនូវគោលការណ៍មួយចំនួន គឺអ្នកនិពន្ធជាបុគ្គលដែលបង្កើតស្នាដៃ (១) ក៏ប៉ុន្តែចំពោះបញ្ហាដែលថានីតិបុគ្គល ឬរូបវន្តបុគ្គល អាចចាត់ទុកថាជាអ្នកនិពន្ធដែរឬទេ ក៏នឹងត្រូវធ្វើការបកស្រាយឱ្យបានច្បាស់លាស់ផងដែរ (២) ។

#### ១. អ្នកនិពន្ធជាបុគ្គលដែលបង្កើតស្នាដៃ

អនុលោមតាមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលប្រកាសឱ្យប្រើនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ បានកំណត់ថាជនដែលបង្កើតស្នាដៃ គឺជាអ្នកនិពន្ធ ដើម្បីជាការលើកទឹកចិត្តដល់អ្នកបង្កើតស្នាដៃទាំងឡាយ ដោយនៅក្នុងអត្ថន័យនេះ អ្នកនិពន្ធត្រូវតែជាបុគ្គលដែលបានបង្កើតស្នាដៃនោះដោយផ្ទាល់ ទើបអាចក្លាយជាម្ចាស់កម្មសិទ្ធិលើស្នាដៃដែលសាមីអ្នកនិពន្ធបានបង្កើតឡើង។[៧]

ម្យ៉ាងវិញទៀត ឋានៈជាអ្នកនិពន្ធ គឺជាឋានៈរបស់បុគ្គលម្នាក់ ឬច្រើននាក់ជាម្ចាស់កម្មសិទ្ធិ

[៧] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៤

លើស្នាដៃដែលសាមីខ្លួនបានបង្កើតឡើង ហើយស្នាដៃនោះត្រូវបានផ្សព្វផ្សាយជាសាធារណៈលើកលែងតែមានភស្តុតាងផ្ទុយ។[៨] ឋានៈជាអ្នកនិពន្ធ សំដៅទៅលើគុណសម្បត្តិដើម្បីអាចក្លាយជាអ្នកនិពន្ធ។ យោងតាមមាត្រា ១១ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃព្រះរាជាណាចក្រកម្ពុជា គោលការណ៍នៃការទទួលបានឋានៈ ឬគុណភាពជាអ្នកនិពន្ធស្នាដៃត្រូវបានដាក់ឱ្យចំណុះទៅនឹងលក្ខខណ្ឌជាគ្រឹះតែមួយគត់ ពោលគឺ ស្ថានភាពនៃការបង្កើតស្នាដៃដែលច្បាប់មួយទទួលស្គាល់។ ចំណែកឯ ការផ្សព្វផ្សាយនូវស្នាដៃរបស់ខ្លួនជាសាធារណៈ គឺគ្រាន់តែជាលក្ខខណ្ឌទម្រង់មួយ ដើម្បីអនុញ្ញាតឱ្យសាធារណជនដឹងឮអំពីគុណសម្បត្តិជាអ្នកនិពន្ធស្នាដៃ ដែលត្រូវបានច្បាប់ការពាររួចហើយតែប៉ុណ្ណោះ។

ការទទួលស្គាល់គោលការណ៍នេះ ក៏អាចត្រូវបានបកស្រាយប្រសិនបើគ្មានបណ្តឹងជំទាស់ណាមួយពីសំណាក់អ្នកនិពន្ធពិតប្រាកដដែលបានបង្កើតស្នាដៃនោះទេ នោះនឹងអាចបកស្រាយនៅក្នុងសម្មតិកម្មពីរយ៉ាងៈ បុគ្គលដែលបានប្រើប្រាស់ឈ្មោះលើស្នាដៃនោះហើយ គឺជាអ្នកនិពន្ធស្នាដៃ ឬជាអ្នកទទួលសិទ្ធិជាអ្នកតំណាងឱ្យអ្នកនិពន្ធដែលបានបង្កើតស្នាដៃនោះ ទាំងសិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌រហូតដល់គុណសម្បត្តិជាអ្នកនិពន្ធពិតប្រាកដត្រូវបានអះអាង នេះមានន័យថាអ្នកតំណាងមិនមែនកើតចេញពីកិច្ចព្រមព្រៀងណាមួយឡើយ គឺកើតចេញពីការសន្មតដោយច្បាប់។

### ២. អ្នកនិពន្ធត្រូវតែជារូបវន្តបុគ្គល

អ្នកនិពន្ធជាជនដែលបង្កើតស្នាដៃ ដោយស្នាដៃនោះត្រូវតែកើតចេញពីការច្នៃប្រឌិត ដោយបង្កើតឡើងដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនាយ៉ាងពិតប្រាកដរបស់មនុស្ស។ ក្នុងន័យនេះយើងអាចសន្និដ្ឋានបានថាច្បាប់របស់កម្ពុជា គឺទទួលស្គាល់តែអ្នកនិពន្ធដែលជារូបវន្តបុគ្គលតែប៉ុណ្ណោះ ដោយសំអាងថាការប្រើប្រាស់គំនិត ឬការប្រើមនោសញ្ចេតនា គឺកើតចេញពីការគិតរបស់បុគ្គលម្នាក់ៗផ្សេងៗគ្នា ព្រោះយើងមិនអាចខ្ចីគំនិត ឬមនោសញ្ចេតនាពីអ្នកដទៃបាននោះឡើយ។

ក៏ប៉ុន្តែ បើយោងតាមមាត្រា ៣ ចំណុច ១ក នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានចែងថា "ស្នាដៃអ្នកនិពន្ធ សំដៅដល់ស្នាដៃដែលបង្កើតឡើងដោយជនដែលសញ្ជាតិខ្មែរ ឬជនដែលមានលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមមាននីតិបុគ្គល ហើយត្រូវបានបង្កើតឡើងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា"។[៩] តាមរយៈបញ្ញត្តិនេះ វាហាក់ដូចមានភាពស្រពិចស្រពិលក្នុងការកំណត់ឋានៈអ្នកនិពន្ធ ក៏ប៉ុន្តែមាត្រា ១៣ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដដែលនេះហាក់បានចែងពីការ

[៨] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល,មាត្រា ១១

[៩] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៣ (ចំណុច១ ក)

ទទួលស្គាល់នីតិបុគ្គល ក្នុងឋានៈជាអ្នក និពន្ធស្នាដៃសម្ងហាភាពវិញ។[១០]

**ខ. គោលការណ៍នៃកិច្ចការពារសិទ្ធិអ្នកនិពន្ធ**

សិទ្ធិអ្នកនិពន្ធ នឹងត្រូវបានអនុវត្តន៍ និងការពារទៅលើស្នាដៃមួយចំនួនស្របតាមលក្ខខណ្ឌកំណត់ដោយច្បាប់។ ស្នាដៃដែលត្រូវទទួលបានការការពារមានដូចជា៖[១១]

- ស្នាដៃដែលបង្កើតឡើងដោយជនមានសញ្ជាតិខ្មែរ ឬជនដែលមានលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមមាននីតិបុគ្គលហើយត្រូវបានបង្កើតឡើងតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ស្នាដៃសោតទស្សន៍ដែលមានផលិតករមានទីស្នាក់ការ ឬមានលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ស្នាដៃស្ថាបត្យកម្ម ដែលបានសាងសង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងស្នាដៃសិល្បៈផ្សេងទៀត ដែលភ្ជាប់ទៅនឹងអគារ ឬរចនាសម្ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ស្នាដៃ ដែលព្រះរាជាណាចក្រកម្ពុជាមានកាតព្វកិច្ចការពារក្រោមសន្ធិសញ្ញាអន្តរជាតិ។
- ស្នាដៃដែលបោះពុម្ពផ្សាយលើកដំបូងនៅបរទេស ហើយត្រូវបានយកមកបោះពុម្ពផ្សាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងអំឡុងពេល ៣០ ថ្ងៃ។

ជាគោលការណ៍អ្នកនិពន្ធស្នាដៃ មានសិទ្ធិផ្តាច់មុខលើស្នាដៃ។[១២] អ្នកនិពន្ធមានសិទ្ធិអនុញ្ញាត ឬហាមឃាត់រាល់ការប្រើប្រាស់ ការចម្លង ការផលិតឡើងវិញនូវស្នាដៃរបស់ខ្លួនបាន។

**១. គោលការណ៍នៃការការពារដោយស្វ័យប្រវត្តិ**

ជាគោលការណ៍នៅក្នុងវិស័យកម្មសិទ្ធិបញ្ញា ការចុះបញ្ជីជាលក្ខខណ្ឌចាំបាច់បំផុតដើម្បីទទួលបានកិច្ចការពារតាមផ្លូវច្បាប់។ ការចុះបញ្ជី ជាកាតព្វកិច្ចរបស់ម្ចាស់សិទ្ធិនៃកម្មសិទ្ធិបញ្ញា ប៉ុន្តែគោលការណ៍នេះមិនត្រូវបានអនុវត្តន៍ចំពោះសិទ្ធិអ្នកនិពន្ធឡើយ។ ពោលការចុះបញ្ជីការពារសិទ្ធិអ្នកនិពន្ធមិនមែនជាកាតព្វកិច្ចរបស់ម្ចាស់ស្នាដៃទេ ប៉ុន្តែវាជាសិទ្ធិរបស់ម្ចាស់ស្នាដៃ។ ស្នាដៃអ្នកនិពន្ធអាចទទួលបាននូវកិច្ចការពារទោះបីជាម្ចាស់ស្នាដៃបានចុះបញ្ជី ឬមិនបានចុះបញ្ជីក៏ដោយ[១៣]។ ប្រសិនបើម្ចាស់ស្នាដៃមិនមានបំណងចុះបញ្ជីស្នាដៃរបស់ខ្លួនទេ ពួកគេអាចបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើស្នាដៃរបស់ខ្លួនបាន។

សិទ្ធិផ្តាច់មុខលើស្នាដៃនឹងកើតមានឡើងដោយស្វ័យប្រវត្តិ នៅពេលដែលស្នាដៃត្រូវបាន

[១០] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ១៣
[១១] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៣
[១២] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ១៨
[១៣] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៣៨

បង្កើតជារូបរាង និងបោះផ្សាយជាសាធារណៈ។ អ្នកនិពន្ធ ក៏អាចទទួលបាននូវកិច្ចការពារលើស្នាដៃផងដែរ តាមរយៈការចុះបញ្ជីស្នាដៃនៅនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ម្ចាស់ស្នាដៃ ដែលបានដាក់ពាក្យសុំចុះបញ្ជីការពារលើស្នាដៃតាមរយៈសិទ្ធិអ្នកនិពន្ធ ត្រូវមានកាតព្វកិច្ចបង់ថ្លៃសេវារដ្ឋបាលចុះបញ្ជីសិទ្ធិអ្នកនិពន្ធ[១៤] ដែលត្រូវបានកំណត់ដោយប្រកាសអន្តរក្រសួងនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[១៥]។

ផលប្រយោជន៍នៃការចុះបញ្ជីស្នាដៃផ្តល់ភាពងាយស្រួលដល់ម្ចាស់ស្នាដៃ នៅក្នុងការបង្ហាញភស្តុតាងបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិរបស់ខ្លួនលើស្នាដៃ ចំពោះមុខអាជ្ញាធរមានសមត្ថកិច្ចនៅពេលមានវិវាទ ឬអំពើរំលោភសិទ្ធិរបស់ម្ចាស់ស្នាដៃ។ ក្នុងករណីដែលម្ចាស់ស្នាដៃពុំបានចុះបញ្ជីការពារទេ វានឹងបង្កើតជាឧបសគ្គដល់ម្ចាស់ស្នាដៃក្នុងការបង្ហាញភស្តុតាងពីអត្ថិភាពនៃសិទ្ធិលើស្នាដៃនោះនៅពេលមានអំពើរំលោភលើសិទ្ធិរបស់ម្ចាស់ស្នាដៃ។ ក្នុងករណីនេះ ម្ចាស់ស្នាដៃអាចបង្ហាញភស្តុតាងមួយចំនួន ដែលអាចបញ្ជាក់ពីសិទ្ធិរបស់ខ្លួនលើស្នាដៃ៖ ការតម្កល់ស្នាដៃនៅស្ថាប័នរដ្ឋ កិច្ចសន្យាចែកចាយស្នាដៃនៅស្ថាប័នរដ្ឋ កិច្ចសន្យាចែកចាយស្នាដៃជាមួយអ្នកចែកចាយ ឯកសារបញ្ជាក់ពីការបោះពុម្ពផ្សាយលើកដំបូង។ល។ ប្រសិនបើម្ចាស់ស្នាដៃពុំអាចរកភស្តុតាងបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិលើស្នាដៃបានទេ ម្ចាស់ស្នាដៃអាចជួបការលំបាកក្នុងការអនុវត្តសិទ្ធិនៃបណ្តឹងប្រឆាំងនឹងបុគ្គលដែលបានរំលោភសិទ្ធិ និងទាមទារសំណងលើការខូចខាតទាំងឡាយ ដែលកើតចេញពីអំពើរំលោភនោះ។ លើសពីនេះទៅទៀត ម្ចាស់ស្នាដៃអាចនឹងបាត់បង់សិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌លើស្នាដៃទាំងស្រុងតែម្តង។

ដូច្នេះ ទោះបីច្បាប់ពុំបានប្បញ្ញត្តិអំពីកាតព្វកិច្ចក្នុងការចុះបញ្ជីស្នាដៃក៏ដោយ ដើម្បីការពារសិទ្ធិអ្នកនិពន្ធនៅក្នុងប្រទេសកម្ពុជាឱ្យបានរឹងមាំ ម្ចាស់ស្នាដៃគួរតែចាត់វិធានការការពារ និងទប់ស្កាត់ជាមុនតាមមធ្យោបាយរដ្ឋបាល ពោលគឺចុះបញ្ជីស្នាដៃជាមួយមន្ត្រីចុះបញ្ជី ឬតម្កល់ស្នាដៃ។

### ២. ភស្តុតាងបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិរបស់អ្នកនិពន្ធ

ស្នាដៃដែលត្រូវបានដាក់ពាក្យស្នើសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីនឹងចេញវិញ្ញាបនបត្របញ្ជាក់អំពីការចុះបញ្ជីស្នាដៃ។ វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីសិទ្ធិអ្នកនិពន្ធ ម្ចាស់ស្នាដៃអាចបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើស្នាដៃ។ ក្រៅពីវិញ្ញាបនបត្របញ្ជាក់ពីការចុះបញ្ជីសិទ្ធិអ្នកនិពន្ធ ម្ចាស់ស្នាដៃអាច

[១៤] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៤០

[១៥] ប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ និង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, លេខ៩៨៧, ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

បញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើស្នាដៃរបស់ខ្លួនតាមរយៈមធ្យោបាយផ្សេងទៀត មានជាអាទិ៍៖

- ឯកសារបញ្ជាក់ពីការបោះពុម្ពផ្សាយលើកដំបូងនៅកម្ពុជា៖ ប័នសារជាតិ បណ្ណាល័យជាតិ ឬបណ្ណាល័យរបស់គ្រឹះស្ថានសិក្សារដ្ឋនានា។
- ឯកសារបញ្ជាក់ពីការតម្កល់ស្នាដៃនៅស្ថាប័នរដ្ឋ ឬឯកជននៅកម្ពុជា៖ បណ្ណាល័យនៃគ្រឹះស្ថានអប់រំឯកជន បណ្ណាគារ ។ល។
- កិច្ចសន្យាស្តីពីការបោះពុម្ពស្នាដៃ ឬការផ្តល់សិទ្ធិចែកចាយស្នាដៃ ក្នុងដែនដីនៃកម្ពុជា៖ កិច្ចសន្យាអាជ្ញាប័ណ្ណ កិច្ចសន្យាបោះពុម្ពជាមួយរោងពុម្ព កិច្ចសន្យាការងារ ចំពោះស្នាដៃសមូហភាព។ល។

ហេតុដូច្នេះ នៅពេលមានវិវាទអ្នកនិពន្ធអាចប្រើមធ្យោបាយបង្ហាញភស្តុតាងសមស្របណាមួយដែលអាចធ្វើបាន។

**កថាខណ្ឌទី២៖ ផលប្រយោជន៍កម្មសិទ្ធិបញ្ញានៃសិទ្ធិអ្នកនិពន្ធ**

សិទ្ធិអ្នកនិពន្ធក៏ដូចជាកម្មសិទ្ធិបញ្ញាដទៃទៀតដែរ គឺផ្តល់នូវសិទ្ធិដល់អ្នកបង្កើតស្នាដៃថ្មីទាំងផ្នែកសីលធម៌ និងផ្នែកបេតិកភណ្ឌ ព្រមទាំងផ្តល់ផលប្រយោជន៍ជាច្រើនចំពោះសង្គម និងសេដ្ឋកិច្ចជាតិទាំងមូល។

**ក. ការទទួលបានការការពារសិទ្ធិរបស់អ្នកនិពន្ធ**

គ្រប់វិស័យនៃច្បាប់កម្មសិទ្ធិបញ្ញា គឺទាក់ទងដល់កិច្ចការពារស្នាដៃដែលបង្កើតឡើងដោយបញ្ញារបស់មនុស្ស។ ផ្នែកដែលសំខាន់នៃសិទ្ធិនេះគឺ ការពារលើស្នាដៃអក្សរសាស្ត្រ និងស្នាដៃសិល្បៈ មានដូចជា អត្ថបទសរសេរ តន្ត្រី រូបគំនូរ ចម្រៀង ព្រមទាំងបច្ចេកវិទ្យា ដូចជាកម្មវិធីកុំព្យូទ័រ និងប្រព័ន្ធទិន្នន័យអេឡិចត្រូនិច។ កិច្ចការពារស្នាដៃសំដៅទៅលើការការពារចំពោះស្នាដៃសរសេរ ឬការសម្តែងចេញពីគំនិតរបស់ម្ចាស់ស្នាដៃ មិនមែនការពារលើយោបល់ទេ។

ស្នាដៃដែលត្រូវបានបង្កើតឡើងចេញជារូបរាងច្បាស់លាស់ នឹងត្រូវបានការពារសម្រាប់រយៈពេលមួយតាមកំណត់របស់ច្បាប់។ រយៈពេលនៃកិច្ចការពារនេះខុសគ្នាទៅតាមប្រភេទនៃសិទ្ធិនីមួយៗ។ អ្នកនិពន្ធទទួលបានសិទ្ធិផ្តាច់មុខលើស្នាដៃ។ សិទ្ធិនេះត្រូវបានទទួលស្គាល់ដោយច្បាប់ជាតិ។ សិទ្ធិអ្នកនិពន្ធមានពីរប្រភេទ គឺសិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌។[១៦]

**១. សិទ្ធិបេតិកភណ្ឌ**

សិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ គឺជាសិទ្ធិខាងសេដ្ឋកិច្ចដែលអនុញ្ញាតឱ្យម្ចាស់សិទ្ធិទទួលបាននូវកម្រៃពីការប្រើប្រាស់ស្នាដៃរបស់ខ្លួន ហើយដែលសិទ្ធិនេះជាសិទ្ធិផ្តាច់មុខ។ សិទ្ធិផ្តាច់មុខនៃការ

[១៦] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ១៨

ធ្វើអាជីវកម្មលើសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ គឺត្រូវបានធានាដោយច្បាប់សិទ្ធិទាំងនោះរួមមាន សិទ្ធិផលិតឡើងវិញ សិទ្ធិតាំងពិពណ៌ជាសាធារណៈ សិទ្ធិក្នុងការលក់ដូរ ឬជួលនូវស្នាដៃច្បាប់ដើម សិទ្ធិលើការបកប្រែស្នាដៃជាភាសាបរទេស និងសិទ្ធិក្នុងការបង្កើតស្នាដៃបន្ត។[១៧] អាជ្ញាយុកាលនៃសិទ្ធិបេតិកភណ្ឌនេះ ច្បាប់បានកំណត់ទៅតាមប្រភេទស្នាដៃដូចខាងក្រោមៈ

- ចំពោះស្នាដៃឯកបុគ្គល រយៈពេលនៃការការពារសិទ្ធិនេះ ត្រូវធ្វើឡើងអស់មួយជីវិតរបស់អ្នកនិពន្ធ ការការពារគិតចាប់តាំងពីថ្ងៃដែលបានបង្កើតស្នាដៃ ហើយបូក ៥០ (ហាសិប) ឆ្នាំ ទៀតក្រោយពេលអ្នកនិពន្ធទទួលមរណភាព។[១៨]
- ចំពោះស្នាដៃអនាមិក ឬស្នាដៃរហស្សនាម ត្រូវបានការពារក្នុងរយៈពេល ៧៥ (ចិតសិបប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលស្នាដៃនោះបានបោះផ្សាយលើកដំបូង ដោយមានការអនុញ្ញាតពីម្ចាស់សិទ្ធិ។ ប្រសិនបើស្នាដៃអនាមិក ឬស្នាដៃរហស្សនាមនោះបានបង្កើត ការការពារមានរយៈពេល ១០០ (មួយរយ) ឆ្នាំ គិតចាប់ពីពេលបង្កើតស្នាដៃ។ បើសិនជាមុនពេលកំណត់នៃកិច្ចការពារពីច្បាប់អត្តសញ្ញាណអ្នកនិពន្ធត្រូវបានបង្ហាញឱ្យសាធារណៈជនបានស្គាល់ច្បាស់ឥតសង្ស័យនោះ ការការពារចំពោះស្នាដៃនោះគិតរយៈពេល ១០០ (មួយរយ) ឆ្នាំ បូក ៥០ (ហាសិប) ឆ្នាំ ទៀតក្រោយពេលដែលអ្នកនិពន្ធទទួលមរណភាព។
- ស្នាដៃសមូហភាព ឬស្នាដៃសោតទស្សន៍ ឬស្នាដៃបច្ឆាមរណៈ ត្រូវទទួលបានការការពារពីច្បាប់រយៈពេល ៧៥ (ចិតសិបប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលស្នាដៃនោះបានបោះផ្សាយជាលើកដំបូងត្រឹមត្រូវតាមច្បាប់។ ប្រសិនបើពុំបានផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល ៥០ (ហាសិប) ឆ្នាំ បន្ទាប់ពីពេលបង្កើតស្នាដៃនោះច្បាប់ធ្វើការការពារក្នុងរយៈពេល ១០០(មួយរយ) ឆ្នាំ គិតចាប់តាំងពីស្នាដៃនោះបានបង្កើត។[១៩]

សិទ្ធិបេតិកភណ្ឌនេះ គឺជាកម្មវត្ថុនៃការលក់ ដែលត្រូវធ្វើឡើងដោយលាយល័ក្ខណ៍អក្សរជាក់លាក់ក៏ដូចជាមានចែងពី កម្រិតទំហំគោលដៅទីកន្លែង និងរយៈពេលនៃការផ្ទេរ និងផ្ទេរទៅទាយាទបានដោយមូលហេតុមរណភាពរបស់អ្នកនិពន្ធ។[២០]

### ២. សិទ្ធិសីលធម៌

សិទ្ធិសីលធម៌របស់អ្នកនិពន្ធ គឺជាសិទ្ធិដែលនៅជាប់ជាមួយអ្នកនិពន្ធជានិរន្តន៍លើខ្លឹមសារទម្រង់ទាំងមូលនៃស្នាដៃ ឈ្មោះរបស់អ្នកនិពន្ធ។ល។ សិទ្ធិសីលធម៌ ជាសិទ្ធិដែលត្រូវតម្រូវឱ្យគេ

[១៧] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ២១ (វាក្យខណ្ឌទី១)

[១៨] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៣០

[១៩] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៣១

[២០] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៣៣, មាត្រា ៣៤ និងមាត្រា ៣៥

គោរពឈ្មោះអ្នកនិពន្ធ បែបបទនៃការបោះផ្សាយ និងការបកប្រែ ដែលនាំឱ្យខូចកេរ្តិ៍ឈ្មោះរបស់អ្នកនិពន្ធផ្ទាល់។ សិទ្ធិសីលធម៌របស់អ្នកនិពន្ធរួមមាន៖[២១]

- អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខក្នុងការសម្រេចពីរបៀប និងពេលវេលានៃការផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈ ព្រមទាំងបែបបទគ្រប់គ្រងការផ្សព្វផ្សាយ។ ពោល អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខលើស្នាដៃរបស់ខ្លួន គឺអ្នកនិពន្ធចង់ចាត់ចែងប្រើប្រាស់ ឬអាស្រ័យផលទៅលើស្នាដៃរបស់ខ្លួនដោយសេរី កុំឱ្យតែការប្រើប្រាស់នោះប៉ះពាល់ដល់សិទ្ធិអ្នកដទៃ។ ឧទាហរណ៍៖ អ្នកនិពន្ធ មានសិទ្ធិចង់ធ្វើការផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈ ឬមិនចង់ផ្សព្វផ្សាយស្នាដៃរបស់ខ្លួនគឺជាសិទ្ធិរបស់គាត់ មិនមាននរណាម្នាក់អាចចាប់បង្ខំគាត់ឱ្យផ្សព្វផ្សាយស្នាដៃរបស់គាត់បានឡើយ។
- អ្នកនិពន្ធ មានសិទ្ធិកំណត់ឱ្យមានការទទួលស្គាល់នូវឈ្មោះ ឋានៈ និងស្នាដៃរបស់ខ្លួនសម្រាប់ទាក់ទងជាមួយសាធារណជន។ ឧទាហរណ៍៖ អ្នកនិពន្ធអាចធ្វើការបោះផ្សាយនូវស្នាដៃរបស់ខ្លួនដោយបង្ហាញនូវឈ្មោះ ឬឋានៈរបស់ខ្លួននៅលើស្នាដៃរបស់គាត់ក្នុងគោលបំណង ដើម្បីឱ្យសាធារណជនស្គាល់ថាគាត់ជាម្ចាស់ស្នាដៃពិតប្រាកដ ដូច្នេះ ប្រសិនបើសាធារណជនចង់ប្រើប្រាស់ស្នាដៃរបស់គាត់ក្នុងគោលបំណងខាងសេដ្ឋកិច្ច នោះត្រូវតែសុំការអនុញ្ញាតពីម្ចាស់សិទ្ធិ ហើយត្រូវបញ្ជាក់ពីឈ្មោះ និងឋានៈរបស់អ្នកនិពន្ធផងដែរ។
- អ្នកនិពន្ធមានសិទ្ធិជំទាស់នូវគ្រប់រូបភាពបំផ្លើស ឬការកាត់ចោលខ្លឹមសារ ការកែប្រែខ្លឹមសារដែលជាហេតុធ្វើឱ្យខូចកេរ្តិ៍ឈ្មោះ ឬកត្តិយសរបស់ខ្លួន។ នេះបញ្ជាក់ថា ប្រសិនបើមានបុគ្គលណាម្នាក់បានយកស្នាដៃរបស់គាត់ទៅធ្វើការកែប្រែ ឬបម្លែង ឬនិយាយបំផ្លើសខុសពីការពិតជាហេតុធ្វើឱ្យមានការខូចខាត ឬប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់អ្នកនិពន្ធ គាត់អាចចេញមុខប្រឆាំង ឬធ្វើការប្តឹងបុគ្គលនោះ ដើម្បីឱ្យទទួលខុសត្រូវទៅលើទង្វើដែលខ្លួនបានប្រព្រឹត្ត។

សិទ្ធិសីលធម៌ គឺជាសិទ្ធិអចិន្ត្រៃយ៍មិនអាចលក់ដូរ មិនអាចរឹបអូសបាន និងមិនអាចផុតអាជ្ញាយុកាលឡើយ។ សិទ្ធិនេះអាចត្រូវផ្ទេរទៅឱ្យទាយាទរបស់អ្នកនិពន្ធ ដោយមូលហេតុអ្នកនិពន្ធទទួលមរណភាព ឬប្រគល់ជូនតតីយជនបានតាមរយៈមតកសាសន៍។ ក្នុងករណីដែលគ្មានអ្នកទទួលមរតក រដ្ឋដែលតំណាងដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជាអ្នកគ្រប់គ្រង។[២២] ដូច្នេះ សិទ្ធិសីលធម៌ស្ថិតនៅជាប់ជាមួយអ្នកនិពន្ធជារៀងរហូតដរាបណាស្នាដៃនោះមិនទាន់បាត់បង់។

### **ខ. ផលប្រយោជន៍ដែលទទួលបាននៅក្នុងសង្គម**

[២១] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ២០

[២២] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ១៩

### ១. ផលប្រយោជន៍សម្រាប់វិស័យវប្បធម៌

ស្នាដៃដែលបានបង្កើតឡើងដោយអ្នកនិពន្ធ ក៏ជាផ្នែកមួយក្នុងការផ្សព្វផ្សាយ និងពង្រីកការយល់ដឹងអំពីវប្បធម៌។ សិទ្ធិអ្នកនិពន្ធ ជាផ្នែកមួយនៃសិទ្ធិមនុស្ស ដែលមានចែងក្នុងសេចក្តីប្រកាសសាកលស្តីពីសិទ្ធិមនុស្ស និងក្នុងកិច្ចព្រមព្រៀងអន្តរជាតិរបស់អង្គការសហប្រជាជាតិ និងជាច្បាប់ដ៏សំខាន់មួយសម្រាប់ការពារសិទ្ធិលើស្នាដៃវប្បធម៌។ ស្នាដៃមួយនៃវប្បធម៌ ជាស្នាដៃដែលមនុស្សបានបង្កើតឡើង ដើម្បីធ្វើឱ្យប្រសើរឡើងនូវចិត្តគំនិត និងការត្រិះរិះពិចារណារបស់មនុស្ស។ ស្នាដៃវប្បធម៌មិនរាប់បញ្ចូលនូវការបង្កើតគ្រឿងម៉ាស៊ីន ឬបច្ចេកវិទ្យា ដែលរួមចំណែកដោយចំពោះសម្រាប់បង្កើនភាពងាយស្រួលនៃរបៀបរស់នៅ និងការងារ។ វត្ថុទាំងអស់នេះមិនចាត់ទុកជាស្នាដៃវប្បធម៌ឡើយ ព្រោះជាការទាក់ទងសំខាន់ទៅនឹងការអភិវឌ្ឍបច្ចេកវិទ្យានៃអារ្យធម៌ ដូច្នេះហើយទើបច្បាប់ការពារសិទ្ធិលើវត្ថុទាំងនោះ ជាច្បាប់ផ្សេងពីសិទ្ធិអ្នកនិពន្ធ។[២៣] ដូច្នេះ ពាក្យស្នាដៃវប្បធម៌រួមមានគ្រប់ទម្រង់នៃអក្សរសិល្ប៍ ដូចជាប្រលោមលោក កំណាព្យ ឬឈុតរឿង ក៏ដូចជា គ្រប់ទម្រង់នៃការសម្តែងគំនិត មានរូបគំនូរ តូរ្យតន្ត្រី ភាពយន្ត និងលទ្ធផលនៃការសិក្សាខាងវិទ្យាសាស្ត្រដែលមានភាពស្មុគ្រស្មាញ។ ស្នាដៃវប្បធម៌អាចមានន័យ ជាការសម្តែងចេញនូវការបង្កបង្កើតដោយគំនិតបញ្ញា និងមនោសញ្ចេតនារបស់មនុស្ស។ ការសម្តែងបែបនេះអាចមានឥទ្ធិពលលើចិត្តគំនិត និងការរំភើបរបស់មនុស្សផ្សេងទៀត។ ដោយហេតុនេះហើយ ច្បាប់បានទទួលស្គាល់ជនដែលបង្កើតបាននូវស្នាដៃវប្បធម៌ ហើយជននោះមានសិទ្ធិផ្តាច់មុខលើស្នាដៃ និងធានាទទួលបាននូវផលប្រយោជន៍ពេលណាមានអ្នកផ្សេងធ្វើអាជីវកម្មលើស្នាដៃរបស់ខ្លួន។ អ្នកនិពន្ធ គឺជាមនុស្សសេរី និងជាអ្នកច្នៃប្រឌិតបង្កើតថ្មីដែលត្រូវការដឹងរឿងរ៉ាវក្នុងធម្មជាតិ និងសង្គមជាច្រើន ដើម្បីយកមកប្រឌិតប្រៀបធៀបទៅតាមទំនោរនៃឆន្ទៈរបស់ខ្លួនទុកជាការកំសាន្ត និងពិចារណាសំដៅទៅរកការបង្កើតគំនិតថ្មី។ អ្នកនិពន្ធអាចតាក់តែងព្រឹត្តិការណ៍មួយទៅជាកំណាព្យ ជារឿងប្រឌិត ជាចម្រៀង ភាពយន្ត និងរូបថ្លុកកំប្លុកកំប្លែងផងដែរ ទៅតាមជំនាញ ឬទេពកោសល្យរបស់ខ្លួនដោយរើសយកស្ថានការណ៍សង្គមណាមួយទុកឱ្យអ្នកអានពិចារណា។ និយាយជារួម តាមរយៈស្នាដៃនិពន្ធពិតជាអាចស្តែងឱ្យឃើញអំពីតម្លៃវប្បធម៌របស់សង្គមជាតិមួយ នេះមានន័យថា កាលណានៅក្នុងប្រទេសមួយដែលមានការរីកចម្រើនលើការតែងនិពន្ធស្នាដៃថ្មីៗ ដោយបង្កើតជាភាពពេញលេញនិយមមួយទៅដល់សាធារណជន គឺបង្ហាញឱ្យឃើញពីភាពរីកចម្រើនលូតលាស់ និងភាពរុងរឿងនៃវប្បធម៌ជាតិទាំងមូលផងដែរ។

**ឧទាហរណ៍:** បើរាប់ចាប់ពីទសវត្សរ៍ទី៦០ ក្រោយអ្នកនិពន្ធញ៉ុក ថែម និងនូ ហាច ដែលមាន

[២៣] តាម៉ុតស៊ូ ហូហ្ស៊ុយមី, សៀវភៅអ្នកនិពន្ធអ្នកស្រុកអាស៊ី

ស្នាដៃលក្ខណៈអក្សរសិល្ប៍ខ្មែរក្នុងមួយជីវិត បានបន្សល់ស្នាដៃដោយការបោះពុម្ព និងចំណាយថវិកាខ្លួនឯងផ្ទាល់ មិនក្រោម ២០ ស្នាដៃនោះទេ ហើយក្រោយឆ្នាំ ១៩៧០ មានអ្នកនិពន្ធជាសិស្ស និងនិស្សិតដែលចូលចិត្តតែងនិពន្ធ ហើយបោះពុម្ពខ្លួនឯង មិនលើសពី ១០០ ស្នាដៃ នោះឡើយ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីការវិវត្តពីជំនាន់មួយទៅជំនាន់មួយ ហើយបានផ្សារភ្ជាប់ទៅនឹងការឱ្យតម្លៃខ្ពស់ក្នុងអក្សរសិល្ប៍ខ្មែរ។ ស្នាដៃអ្នកនិពន្ធទសវត្សរ៍ទី៦០ បានបង្ហាញពីការរៀបរាប់ជាពាក្យកាព្យភាគច្រើន ដែលធ្វើឱ្យអ្នកអានជក់ចិត្តជិតអារម្មណ៍យ៉ាងខ្លាំងទៅតាមសាច់រឿងដែលបង្ហាញពីតថភាពសង្គម ដូចជារឿងកាកី ទុំទាវ ផ្នែកសម័យមាន កុលាបប៉ៃលិន ផ្កាស្រពោន ដែលបានបង្ហាញពីជីវិតក្នុងសង្គមដែលទាក់ទាញអ្នកអានឱ្យជក់ចិត្ត និងចង់តាមដានរាល់ថ្ងៃ។ លុះចូលដល់ឆ្នាំ ១៩៧០ ស្នាដៃអ្នកនិពន្ធស្រករមុនក៏រសាត់ផុតទៅបន្សល់នូវស្នាដៃនិពន្ធជំនាន់ក្រោយតែស្នាដៃជំនាន់មុនក៏នៅតែរក្សាបាននូវឥទ្ធិពលស្នាដៃចាស់ដដែល ដោយបានក្លាយទៅជាគំរូហើយបានបញ្ចូលទៅក្នុងកម្មវិធីអប់រំសិក្សាផងដែរ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ ដូចជាបណ្តាំក្រម ង៉ុយដែលបានឆ្លុះបង្ហាញពីតថភាពសង្គមខ្មែររាប់រយឆ្នាំមកហើយ ប៉ុន្តែស្នាដៃនេះក៏នៅតែអាចរក្សាបាននូវតម្លៃអប់រំដ៏មហាសាលក្នុងប្រទេសកម្ពុជា។

### ២. ផលប្រយោជន៍សម្រាប់សង្គមជាតិ

កិច្ចការពារសិទ្ធិរបស់អ្នកនិពន្ធ ជាកត្តាដ៏ចាំបាច់មួយក្នុងការលើកទឹកចិត្តដល់អ្នកនិពន្ធ និងធានាដល់កម្រិតជីវភាពល្អប្រសើររបស់អ្នកនិពន្ធ និងអ្នកពាក់ព័ន្ធ ជាពិសេស កត្តិយស សេចក្តីថ្លៃថ្នូរ និងធានាដល់ការរីកចម្រើនក្នុងវិស័យសិល្បៈជាតិទាំងមូលទៀតផង។ ឆ្លើយតបជាមួយនឹងផលប្រយោជន៍ដែលសង្គមជាតិទទួលបានតាមរយៈវិស័យអ្នកនិពន្ធ សំដៅទៅលើការតម្កល់ និងការចុះបញ្ជីនៃស្នាដៃរបស់អ្នកនិពន្ធ។ យ៉ាងណាមិញ ដូចបានរៀបរាប់ខាងលើ អ្នកនិពន្ធជាអ្នកដែលទាញបានផលប្រយោជន៍ដោយផ្ទាល់ពីស្នាដៃរបស់ខ្លួន។ រាល់ស្នាដៃទាំងអស់ត្រូវទទួលបាននូវកិច្ចការការពារពីច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ជាស្វ័យប្រវត្តិ។ អ្នកនិពន្ធ ឬម្ចាស់សិទ្ធិអាចតម្កល់ទុកស្នាដៃ នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។[២៩]

ចំណែកឯសង្គមវិញ ជាអ្នកដែលទទួលបានផលប្រយោជន៍ដោយប្រយោលពីការតម្កល់ និងការចុះបញ្ជីនៃស្នាដៃអ្នកនិពន្ធ។ ការចុះបញ្ជីអាចធ្វើឡើងបានដោយស្ម័គ្រចិត្ត នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលការចុះបញ្ជីត្រូវចុះឈ្មោះពិតប្រាកដរបស់អ្នកនិពន្ធចុះថ្ងៃ ខែ ឆ្នាំ នៃស្នាដៃដែលបានផ្សព្វផ្សាយ ជាលើកដំបូង និងចុះថ្ងៃ ខែ ឆ្នាំ នៃការបង្កើតស្នាដៃ ព្រមទាំងចុះពីសិទ្ធិរបស់

[២៩] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៣៨

អ្នកនិពន្ធ។[២៥] ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវចេញវិញ្ញាបនប័ត្រចំពោះស្នាដៃដែលបានត្រូវបានចុះបញ្ជី។ អ្នកស្នើសុំចុះបញ្ជី ត្រូវបង់កម្រៃទៅតាមប្រកាសរួមរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[២៦] តាមរយៈការតម្កល់ និងការចុះបញ្ជី ទោះបីវាជាចំណុចតូចមួយដែលផ្តល់ឱ្យសង្គមដោយការបង់កម្រៃសេវានៅពេលចុះបញ្ជីក៏ដោយ តែវាជាការផ្តល់នូវគុណតម្លៃដល់ព្រះរាជាណាចក្រកម្ពុជាដោយការមានអ្នកនិពន្ធជាជនជាតិកម្ពុជាផ្ទាល់។

[២៥] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៣៩

[២៦] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៤០

# ជំពូកទី ២

# ផលប៉ះពាល់នៃការរំលោភបំពានកម្មសិទ្ធិបញ្ញានៅកម្ពុជា

## ផ្នែកទី១៖ ការរំលោភបំពានសិទ្ធិលើម៉ាកនៅកម្ពុជា

បច្ចុប្បន្ន ការរំលោភបំពានម៉ាកនៅប្រទេសកម្ពុជាភាគច្រើន គឺជាការប្រើប្រាស់ម៉ាកដែលមិនត្រឹមត្រូវ និងមិនមានការគោរពនូវបទប្បញ្ញត្តិច្បាប់សម្រាប់ការប្រើប្រាស់ម៉ាកដែលបានចុះបញ្ជីរួចហើយក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានការយល់ព្រមពីម្ចាស់សិទ្ធិ។ ដូចនេះ ការស្វែងយល់អំពីផលប៉ះពាល់នៃការរំលោភបំពានម៉ាកនៅកម្ពុជា (កថាខណ្ឌទី៣) ជាការចាំបាច់សម្រាប់ម្ចាស់សិទ្ធិ។ ប៉ុន្តែ ដើម្បីឈានទៅដល់ការបកស្រាយអំពីផលប៉ះពាល់នៃការរំលោភបំពានសិទ្ធិលើម៉ាក យើងគប្បីសិក្សាជាមុនអំពីរូបភាពនៃការរំលោភបំពានសិទ្ធិ (កថាខណ្ឌទី១) និងវិធានការទប់ស្កាត់រួមទាំងទណ្ឌកម្មដែលត្រូវអនុវត្តនៅពេលដែលមានការរំលោភបំពានកើតឡើង (កថាខណ្ឌទី២)។

### កថាខណ្ឌទី១៖ រូបភាពនៃការរំលោភបំពានសិទ្ធិលើម៉ាក

អំពើរំលោភបំពានសិទ្ធិលើម៉ាក គឺជាការប្រព្រឹត្តដោយជនណាម្នាក់ក្រៅជាម្ចាស់ម៉ាក ដោយប្រើប្រាស់ម៉ាកនោះគ្រប់រូបភាពដោយមិនមានការអនុញ្ញាតជាមុនពីសំណាក់ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[២៧] យោងតាមមាត្រា ៦១ (វាក្យខណ្ឌ៥) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ បានចែងថាទំនិញដែលពាក់ក្លែងក្លាយមានន័យថា ទំនិញទាំងឡាយ រួមទាំងសំបកវេចខ្ចប់ផង ដែលមានម៉ាកដូចគ្នា នឹងត្រូវបានចុះបញ្ជីត្រឹមត្រូវទាក់ទងទៅនឹងទំនិញនោះ ដោយគ្មានការអនុញ្ញាត ឬមិនអាចសំគាល់បាននូវលក្ខណៈខុសគ្នាពីទិដ្ឋភាពសំខាន់ៗនៃម៉ាកដែលធ្វើការរំលោភបំពានសិទ្ធរបស់ម្ចាស់ម៉ាកស្របច្បាប់ ក្រោមច្បាប់នៃប្រទេសនាំចូល។ ដូចនេះ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តច្បាប់ម៉ាក អំពើរំលោភបំពានអាចកើតមានឡើងតាមរយៈបីរូបភាព គឺការក្លែងបន្លំម៉ាក ការច្រកផលិតផល និងការប្រើប្រាស់ម៉ាកដោយពុំមានការអនុញ្ញាត។ ផលិតផលដែលកើតចេញពីអំពើដូចបានរៀបរាប់នេះ ត្រូវបានចាត់ទុកថាជាទំនិញដែលពាក់ម៉ាកក្លែងក្លាយ។

#### ក. ការក្លែងបន្លំម៉ាក

អំពើក្លែងបន្លំម៉ាក គឺជាការធ្វើត្រាប់តាមនៃផលិតផលមួយ។ ការក្លែងបន្លំម៉ាក គឺជាប្រភេទនៃអំពើរំលោភសិទ្ធិលើម៉ាកមួយដែលត្រូវបានហាមឃាត់ ដោយច្បាប់ម៉ាក។ ដោយយោងតាមមាត្រា ៦៤ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ពុំបានកំណត់អំពីនិយមន័យនៃការក្លែងបន្លំម៉ាកទេ ក៏ប៉ុន្តែមានចែងអំពីទោសព្រហ្មទណ្ឌ និងទោសពិន័យលើអំពើ

[២៧] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់,០៧ កុម្ភៈ ២០០២, មាត្រា ១១ (ចំណុចក)

ក្លែងបន្លំម៉ាកតែប៉ុណ្ណោះ។ ជាទូទៅ ការក្លែងបន្លំម៉ាកអាចត្រូវបានធ្វើឡើងតាមរូបភាពដូចជា៖ ការផលិតឡើងវិញ និងការធ្វើត្រាប់តាមម៉ាក។

**១. ការផលិតឡើងវិញនៃម៉ាក**

ការផលិតឡើងវិញនៃម៉ាក សំដៅទៅលើការចម្លងដូចទាំងស្រុងទៅនឹងម៉ាកដែលត្រូវបានចុះបញ្ជីរួច ហើយបានប្រើប្រាស់ ឬមានគោលដៅនៃការប្រើប្រាស់លើប្រភេទនៃទំនិញ ឬសេវាដូចគ្នា។ ការក្លែងបន្លំម៉ាកតាមរយៈការផលិតឡើងវិញមានលក្ខខណ្ឌពីរ៖ គឺម៉ាកដែលផលិតឡើងវិញនោះត្រូវបានប្រើប្រាស់លើប្រភេទនៃទំនិញ ឬសេវាដូចគ្នាទៅនឹងប្រភេទទំនិញ ឬសេវានៃម៉ាកដែលចុះបញ្ជីរួច។ លក្ខខណ្ឌនេះ មានលក្ខណៈងាយស្រួលក្នុងការពិចារណាដោយពិនិត្យទៅលើប្រភេទនៃទំនិញ ឬសេវាដូចគ្នាទៅនឹងប្រភេទទំនិញ ឬសេវានៃម៉ាកដែលបានចុះបញ្ជីរួចលើវិញ្ញាបនបត្រចុះបញ្ជីម៉ាក។ ចំពោះម៉ាកល្បីវិញ ការផលិតឡើងវិញនូវម៉ាកដែលបានចុះបញ្ជីរួច ហើយការប្រើប្រាស់លើប្រភេទនៃទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែល ឬដែលពាក់ព័ន្ធគ្នាក៏ដោយ ក៏អាចចាត់ទុកជាអំពើក្លែងបន្លំម៉ាកបានដែរ។ ក្នុងករណីនេះ ទោះបីជាចំណុចណាមួយនៃម៉ាកល្បីក៏អាចចាត់ជាការបន្លំដោយផ្នែកនៃម៉ាកល្បីដែរ។ ជាទូទៅ ករណីនេះច្រើនកើតមានចំពោះម៉ាកជាបង្គុំនៃសញ្ញា ឬរូបភាព។

**២. ការធ្វើត្រាប់តាមម៉ាក**

ការធ្វើត្រាប់តាមម៉ាកដែលបានចុះបញ្ជីរួចហើយ គឺជាអំពើរំលោភបំពានម៉ាកដែលត្រូវបានដាក់ផ្តន្ទាទោសដោយយោងតាមមាត្រា ៦៥ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ប៉ុន្តែប្បញ្ញត្តិនេះ មិនបានកំណត់អំពីនិយមន័យនៃការធ្វើត្រាប់តាមម៉ាកទេ។ ការធ្វើត្រាប់តាមម៉ាក គឺជាការផលិតឡើងវិញនូវម៉ាកដែលមានលក្ខណៈដូច ឬប្រហាក់ប្រហែលដែលធ្វើឱ្យមានការភ័ន្តច្រឡំដល់សាធារណៈជន។ ច្បាប់ម៉ាក ពុំបានបញ្ជាក់ច្បាស់លាស់អំពីភាពខុសគ្នានៃការផលិតឡើងវិញ និងការធ្វើត្រាប់តាមម៉ាកឡើយ។ ដូច្នេះ ភាពស្រដៀងគ្នា ដែលអាចធ្វើឱ្យមានការភ័ន្តច្រឡំដល់សាធារណៈជន ជាកត្តាចំបងដើម្បីវិនិច្ឆ័យអំពីអំពើធ្វើត្រាប់តាមម៉ាក។ លក្ខណៈវិនិច្ឆ័យបែបនេះ នឹងត្រូវយកមកពិចារណាលើគ្រប់ថ្នាក់នៃផលិតផល និងសេវាចំពោះការធ្វើត្រាប់តាមម៉ាកល្បី។[២៨]

**ខ. ការច្រកផលិតផល**

ការច្រកផលិតផល សំដៅទៅលើការយកសំបកវេចខ្ចប់ដែលមានម៉ាកដែលបានចុះបញ្ជីរួចទៅដាក់ផលិតផលថ្មីដែលពុំមែនជាផលិតផលនៃម្ចាស់ម៉ាក។

---

[២៨] នី វិចិត្រ, *"នីតិកម្មសិទ្ធិបញ្ញាកម្ពុជា"* (២០១៣), ២៣២។

ជាក់ស្តែង ផលិតផលទឹកក្រូចនៃយីហោល្បីមួយ ត្រូវបានច្រកដោយផ្ទាល់ដៃពីក្បាលរ៉ូប៊ីណេចូលទៅក្នុងដប ហើយដាក់ចរាចរណ៍ក្នុងទីផ្សារកម្ពុជា។[២៩]

**គ. ការប្រើប្រាស់ម៉ាក**

ការប្រើប្រាស់ម៉ាក អាចត្រូវបានធ្វើឡើងតាមច្រើនរូបភាព។ ជារួមការប្រើប្រាស់ម៉ាកដែលត្រូវបានចាត់ទុកថាជាអំពើក្លែងបន្លំម៉ាក គឺរាល់ការប្រើប្រាស់ដែលពុំមានការអនុញ្ញាតពីម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច។ ច្បាប់ម៉ាកនៃប្រទេសកម្ពុជា បានប្បញ្ញាត្តិអំពីការប្រើប្រាស់តាមរយៈ ការនាំចូល ការលក់ ការប្រកាសលក់ ឬមានបំណងលក់។ ច្បាប់ម៉ាកក៏បានប្បញ្ញាត្តិអំពីទោសព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ចំពោះអំពើផ្សព្វផ្សាយពាណិជ្ជកម្មទំនិញ ដោយបញ្ញាត្តិអំពីការប្រកាសលក់ ឬការនាំចូលដោយចេតនានូវផលិតផលក្លែងបន្លំ ត្រូវបានផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃមាត្រា ៦៥ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។ ក្នុងន័យនេះ ការប្រកាសលក់អាចត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយនៃការផ្សព្វផ្សាយគ្រប់ប្រភេទ។

**កថាខណ្ឌទី២៖ បញ្ហាប្រឈម និងផលប៉ះពាល់ពីការរំលោភបំពានកម្មសិទ្ធិម៉ាក**

**ក. បញ្ហាប្រឈមនៃការរំលោភបំពានក្នុងតថភាពសង្គម**

ដោយសារប្រទេសកម្ពុជាកំពុងជួបប្រទះកំណើននៃភាពមិនស៊ីចង្វាក់គ្នាក្នុងតំបន់ និងការកើនឡើងនៃគម្លាតផ្នែកកម្រិតចំណូលនៃក្រុមប្រជាពលរដ្ឋផ្សេងៗគ្នា ជាផ្នែកមួយនៃបញ្ហាសង្គម ដែលលេចចេញពីដំណើរការអភិវឌ្ឍ។ បណ្តាស្ថាប័នដែលពាក់ព័ន្ធ ក៏បានរៀបចំសិក្ខាសាលាជាច្រើនដែលទាន់ទិនជាមួយនឹងការរំលោភបំពាននៃម៉ាក ក៏ប៉ុន្តែចំណេះដឹង និងពត៌មានទូទៅនឹងផលប៉ះពាល់នៃការរំលោភបំពានហាក់ដូចនៅមានកម្រិតនៅឡើយ។ ការកើនឡើងនៃការរំលោភបំពានម៉ាកជាបញ្ហាដ៏ស្មុគស្មាញមួយក្នុងការទប់ស្កាត់ និងបង្ក្រាបផលិតផលដែលបានពាក់ម៉ាកក្លែងក្លាយដែលកំពុងដាក់ចរាចរណ៍ពេញទីផ្សារនៅក្នុងប្រទេសកម្ពុជានេះ ដែលជាមូលហេតុធ្វើឱ្យមន្ត្រីមានសមត្ថកិច្ចពិបាកក្នុងការបង្ក្រាប កាលបើយើងមានវិធានការណ៍តឹងរឹងប្រជាពលរដ្ឋដែលធ្វើអាជីវកម្មនៅលើទីផ្សាររឹតតែខឹងសម្បារ ជាពិសេសអាចធ្វើឱ្យពួកគាត់ឈានទៅរកការធ្វើកូដកម្មផងដែរ។ មន្ត្រីមានសមត្ថកិច្ចមានការលំបាកណាស់ក្នុងការលុបបំបាត់ចោលទាំងស្រុងនូវផលិតផល ដែលពាក់ម៉ាកក្លែងក្លាយទាំងនោះ ដែលកន្លងមកមានផលិតផលដែលពាក់ម៉ាកក្លែងក្លាយ ដូចជាម៉ាក Louis Vuiiton, Dior, Charles and Keith, Pedro ដែលជាផលិតផល កាបូប ខ្សែរក្រវ៉ាត់ ស្បែកជើងជាដើមដែលបានដាក់ចរាចរណ៍នៅលើទីផ្សាររបស់កម្ពុជាសព្វថ្ងៃ។

---

[២៩] សុ វណ្ណារ៉ា, "ទឹកក្រូចម៉ាកថ្មីច្រកផ្ទាល់ដៃពីក្បាលរ៉ូប៊ីណេចូលដប ចរាចរណ៍យ៉ាងគគ្រឹកគគ្រេងពាខេត្តទៅហើយ", *នគរធំ*, ១១ កក្កដា ២០១៩។

ម្យ៉ាងវិញទៀត ការរំលោភបំពានម៉ាកក៏ជាផ្នែកមួយដ៏សំខាន់ដែលបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅដល់ការអនុវត្តច្បាប់ក្នុងប្រទេស ទោះបីវាអាចជួយឱ្យសេដ្ឋកិច្ចជាតិ រួមទាំងវិស័យសេដ្ឋកិច្ចឯកជនមានការប្រសើរឡើងក្តី តែផ្ទុយទៅវិញ បើការរំលោភបំពាននៅតែមានវាបានធ្វើឱ្យសេដ្ឋកិច្ចទីផ្សារកម្ពុជាស្ថិតនៅក្នុងភាពកង្វល់ដ៏ធំមួយរបស់បណ្តាក្រុមហ៊ុនវិនិយោគធំៗមួយចំនួន ដែលប្រែក្លាយសេដ្ឋកិច្ចទីផ្សារកម្ពុជាទៅជាសេដ្ឋកិច្ចទីផ្សារ ដោយពោរពេញទៅដោយផលិតផលលួចម្លងដោយគ្មានអ្នកវិនិយោគណាហ៊ានមកធ្វើការវិនិយោគមកលើប្រទេសកម្ពុជា ព្រោះតែបញ្ហាការរំលោភបំពានម៉ាកនៅកម្ពុជា។

**ខ. ផលប៉ះពាល់ពីការរំលោភបំពានម៉ាក**

ប្រទេសកម្ពុជា ជាប្រទេសមួយដែលត្រូវបានគេចាត់ទុកជាប្រទេសក្រីក្រ ដោយសារតែមានសង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំ។ ដូចនេះ ការការពារម៉ាកឱ្យទទួលបាននូវប្រសិទ្ធិភាពនោះវានឹងបានរួមចំណែកយ៉ាងសកម្ម ទៅដល់វិស័យសេដ្ឋកិច្ចឱ្យមានភាពរីកចំរើន ផ្ទុយទៅវិញ ប្រសិនបើការអនុវត្តន៍វិស័យកម្មសិទ្ធិបញ្ញានៅប្រទេសកម្ពុជាមិនមានប្រសិទ្ធិភាពទេនោះ វាបណ្តាលឱ្យមានផលប៉ះពាល់ទៅដល់សេដ្ឋកិច្ចជាតិទាំងមូល។ ដោយសេដ្ឋកិច្ចជាតិយើងនៅមានកម្រិត ដែលជាហេតុងាយនឹងទទួលរងនូវផលប៉ះពាល់ដែលបណ្តាលពីការរំលោភបំពានម៉ាក។ ជាងនេះទៅទៀត ជីវភាពប្រជាពលរដ្ឋ គឺពឹងផ្អែកទៅលើសេដ្ឋកិច្ចជាតិ កាលណាសេដ្ឋកិច្ចជាតិមានការធ្លាក់ចុះជីវភាពរបស់ប្រជាពលរដ្ឋក៏មានសភាពយ៉ាប់យ៉ឺនទៅតាមនោះដែរ ធ្វើឱ្យពួកគេពិបាកក្នុងការធ្វើអាជីវកម្មសម្រាប់ការនាំចេញ និងនាំចូលនូវផលិតផលមួយចំនួន។ ជាពិសេស អតិថិជនដែលជាអ្នកប្រើប្រាស់ មិនមានទំនុកចិត្តក្នុងការប្រើប្រាស់ផលិតផលផ្សេងៗដែលដាក់ចរាចរណ៍នៅលើទីផ្សារ ព្រោះពួកគេមិនដឹងថាផលិតផលនោះ គឺជាផលិតផលដែលពាក់ក្លែងបន្លំ ឬយ៉ាងណា។ បើសិនជា បញ្ហារំលោភបំពានម៉ាកនៅតែមានបន្ត ឬមានការកើនឡើងនឹងបណ្តាលឱ្យសេដ្ឋកិច្ចជាតិរឹតតែមានការធ្លាក់ចុះ បាត់បង់ទីផ្សារសម្រាប់ផលិតផលនាំចេញ នាំចូល ជាពិសេស បាត់បង់ទំនុកចិត្តពីសំណាក់អ្នកវិនិយោគ ដែលមានការភ័យខ្លាច ប្រសិនបើពួកគេនៅតែមកបណ្តាក់ទុន ក៏ដូចជានាំចូលផលិតផលម៉ាកល្បីណាមួយ ចូលមកក្នុងទីផ្សារកម្ពុជា នោះពួកគេនឹងស្វែងរកប្រាក់ចំណេញពីផលិតផលនោះ ឬពួកគេនឹងប្រឈមមុខនឹងការខាតបង់។

ឧទាហរណ៍៖ ក្រុមហ៊ុន Uniliver Cambodia ដែលជាក្រុមហ៊ុននាំចូលផលិតផលល្បីចូលមកប្រទេសកម្ពុជា បានលើកឡើងថា ក្នុងចំណោមផលិតផល ២១ ម៉ាករបស់ខ្លួនមានផលិតផល ៤ ឬ៥ ម៉ាកដែលត្រូវបានរំលោភបំពានដោយការបន្លំម៉ាក និង ១០ ម៉ាកទៀត ត្រូវបានបំពានដោយការរំលោភសិទ្ធិនាំចូលទីផ្សារកម្ពុជាផ្តាច់មុខ។ ការរំលោភបំពានទាំងនេះ បានធ្វើឱ្យទំហំពាណិជ្ជកម្ម

របស់ក្រុមហ៊ុនមានការខាតបង់ចន្លោះពី ១០ ភាគរយ ទៅ ១៥ ភាគរយ បើគិតត្រឹមឆ្នាំ ២០១៧ មានចំនួន ៨០ លានដុល្លារ។[៣០]

ជារួមមក ការរំលោភបំពានម៉ាក គឺត្រូវបានចាត់ទុកជាបញ្ហាដ៏ស្មុគស្មាញមិនថា ម្ចាស់សិទ្ធិ ឬអ្នកប្រើប្រាស់។ សម្រាប់ម្ចាស់សិទ្ធិ វាមានផលប៉ះពាល់ទៅដល់ផលប្រយោជន៍ខាងផ្នែកបេតិកភណ្ឌ ដោយម្ចាស់សិទ្ធិបានខាតបង់ថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ ជាក់ស្តែងយោងតាមឧទាហរណ៍ខាងលើចំណែកឯអ្នកប្រើប្រាស់ មិនបានដឹងថាខ្លួនកំពុងតែប្រើប្រាស់ផលិតផលគុណភាពក្លែងក្លាយឬយ៉ាងណា ប្រសិនបើពួកគេបានប្រើប្រាស់ផលិតផលក្លែងបន្លំនោះ នាំឱ្យប៉ះពាល់ចំពោះសុខភាពអ្នកប្រើប្រាស់ ក៏ដូចជាគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការការពារអ្នកវិនិយោគស្របច្បាប់។

**គ. ការរាំងស្ទះនៃការការពារម៉ាក**

កម្មសិទ្ធិបញ្ញា គឺជាប្រព័ន្ធច្បាប់មួយដែលការពារលើកទឹកចិត្ត និងអនុញ្ញាតឱ្យម្ចាស់កម្មសិទ្ធិបញ្ញាទាំងអស់ប្រកបរបរអាជីវកម្មរបស់ខ្លួនប្រកបដោយភាពជោគជ័យ។ ច្បាប់នេះបានការពារមិនឱ្យអ្នកដទៃរំលោភបំពានទៅលើម្ចាស់កម្មសិទ្ធិ ដែលបានធ្វើអាជីវកម្មនោះឡើយ។ ច្បាប់កម្មសិទ្ធិបញ្ញា បានធានាការពារទៅលើម្ចាស់កម្មសិទ្ធិករទាំងក្នុងស្រុក និងក្រៅស្រុកឱ្យប្រកបអាជីវកម្មរបស់ខ្លួន បើមានជនណាម្នាក់រំលោភបំពានលើកម្មសិទ្ធិរបស់ខ្លួន ផលិតករមានគំនិតផ្តួចផ្តើមរកវិធីចាត់ការទៅតាមវិធានការដោះស្រាយតាមផ្លូវច្បាប់ ដើម្បីទប់ស្កាត់កុំឱ្យតតិយជនរំលោភទៅលើកម្មសិទ្ធិបញ្ញារបស់ខ្លួនបានឡើយ។ ផលិតករ ឬអាជីករអាចស្រាវជ្រាវ ឬបង្កើតនូវអ្វីដែលថ្មីៗ ដើម្បីនាំយកផលិតផលទាំងនោះមកចុះបញ្ជីការពារ ឬរក្សាគុណភាព ឬតម្លៃដើម្បីឱ្យអ្នកប្រើប្រាស់ទុកចិត្តលើផលិតផល និងការពារផលប្រយោជន៍ទីផ្សារ។ ម្ចាស់កម្មសិទ្ធិនីមួយៗ ត្រូវមានតួនាទីរួមចំណែកការពារនូវកម្មសិទ្ធិបញ្ញារបស់ខ្លួនដោយយកចិត្តទុកដាក់ ទៅលើការរំលោភបំពានពីសំណាក់ជនទីបី។

ទោះបីជាការការពារម៉ាកនៅក្នុងនីតិកម្ពុជាមានប្រសិទ្ធិភាព និងបានផ្តល់ផលប្រយោជន៍ជាច្រើនដល់អ្នកវិនិយោគ ម្ចាស់ម៉ាក និងអតិថិជនក៏ដោយ ក៏ប៉ុន្តែវាមិនបានធ្វើឱ្យការការពារម៉ាកនេះមានប្រសិទ្ធភាពទាំងស្រុងនោះទេ។ យើងឃើញថាមានកត្តាមួយចំនួនដែលបណ្តាលឱ្យមានការរាំងស្ទះក្នុងការការពារម៉ាក ហើយវានៅតែជាបញ្ហាដែលគួរឱ្យកត់សម្គាល់ប្រសិនបើការអនុវត្តច្បាប់ម៉ាកនៅកម្ពុជានៅតែមិនអាចប្រព្រឹត្តទៅរលូន។ កត្តាដែលធ្វើឱ្យមានការរាំងស្ទះក្នុងវិធានការការពារម៉ាកនៅក្នុងនីតិកម្ពុជា អាចបណ្តាលមកពីភាពព្រងើយកន្តើយរបស់ម្ចាស់ម៉ាក ចំពោះការរំលោភ

[៣០] ម៉ិច ដាណែត, "ក្រុមហ៊ុននាំចូលផលិតផលល្បីពីបរទេស សុំឱ្យរដ្ឋាភិបាលទប់ស្កាត់ទំនិញក្លែងក្លាយ", *ថ្មីៗ*, ០៩ ធ្នូ ២០១៧។

បំពានទៅលើផលិតផលរបស់ខ្លួន ជួនកាលបណ្ដាលមកពីភាពអសកម្មរបស់មន្ត្រីមួយចំនួនក្នុងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ក៏ដូចជាប្រទេសកម្ពុជាពុំទាន់មានច្បាប់គ្រប់គ្រាន់ នៅមានការខ្វះខាតចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញាមួយចំនួនព្រោះថាច្បាប់កម្មសិទ្ធិបញ្ញាហាក់ដូចជានៅថ្មីនៅឡើយចំពោះប្រជាពលរដ្ឋកម្ពុជា។

**១. កង្វះខាតចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញា**

ថ្វីត្បិតតែប្រទេសកម្ពុជាមានច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ដែលត្រូវបានអនុម័តឱ្យប្រើប្រាស់នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ រួចមកហើយ ក៏ប៉ុន្តែការផ្សព្វផ្សាយច្បាប់នេះពុំទាន់មានលក្ខណៈទូលំទូលាយនៅឡើយទេ សម្រាប់ម្ចាស់សិទ្ធិផ្ទាល់ ក៏ដូចជាបុគ្គលដែលពាក់ព័ន្ធ និងអ្នកប្រើប្រាស់មួយចំនួន។ ការដែលពួកគាត់មិនទាន់យល់ច្បាស់នោះហើយ ទើបជាហេតុដែលធ្វើឱ្យពួកគាត់ផលិត និងប្រើប្រាស់ផលិតផលដែលក្លែងក្លាយ។

**២. ភាពព្រងើយកន្តើយរបស់ម្ចាស់ម៉ាក**

ម្ចាស់ម៉ាកមួយចំនួន បានទទួលការចុះបញ្ជីម៉ាករបស់គាត់ហើយ ដោយគាត់មិនបានអើពើតាមដានពិនិត្យរាល់ផលិតផលដែលមានការក្លែងបន្លំទៅលើរបស់គាត់ ព្រោះគាត់គិតថានៅពេលដែលម៉ាកនៃផលិតផលរបស់គាត់ទទួលការចុះបញ្ជី គឺមានមន្ត្រីមានសមត្ថកិច្ចតាមការពារម៉ាករបស់ខ្លួនគ្រប់ពេលវេលារួចហើយ។ ទង្វើនេះស្ដែងឱ្យឃើញពីការមិនបានយល់ ឬសិក្សាឱ្យបានលម្អិតពីច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់។ ផ្ទុយទៅវិញ ម្ចាស់ម៉ាកផ្ទាល់ ដែលត្រូវពិនិត្យតាមដានរាល់ទំនិញដែលមានការក្លែងបន្លំនោះ ព្រោះមានតែម្ចាស់ម៉ាកប៉ុណ្ណោះ ទើបដឹងថាផលិតផលនោះជាផលិតផលក្លែងបន្លំឬអត់។

ម្យ៉ាងវិញទៀត ម្ចាស់ម៉ាក គឺជាបុគ្គលដ៏សំខាន់នៅក្នុងការបង្ក្រាបករណីរំលោភបំពានម៉ាកដែលបានកើតឡើង ឬបម្រុងនឹងកើតមាន ព្រោះគាត់អាចដឹងពីភាពស្រដៀងគ្នានៃផលិតផលរបស់ខ្លួនទៅនឹងផលិតផលក្លែងបន្លំ ហើយដាក់ពាក្យប្ដឹងដើម្បីឱ្យមន្ត្រីមានសមត្ថកិច្ចចុះធ្វើអន្តរាគមន៍ទាន់ពេលវេលា។ ក៏ប៉ុន្តែ បើម្ចាស់ម៉ាកមិនបានអើពើនោះទេ ការក្លែងបន្លំ និងការរំលោភបំពានម៉ាកនឹងកើតមានឡើងកាន់តែច្រើនឡើងទៅលើផលិតផលរបស់ខ្លួន ព្រោះថាអាជ្ញាធរមានសមត្ថកិច្ចមិនអាចអនុវត្តន៍លើការរំលោភបំពានលើស្នាដៃរបស់ម្ចាស់ម៉ាកបានទេ បើសិនមិនមានពាក្យបណ្ដឹងពីម្ចាស់ម៉ាកនោះ។

លើសពីនេះទៅទៀត ទោះបីជាមានការរំលោភបំពាន ឬការក្លែងបន្លំម៉ាកមួយចំនួនហើយក៏ដោយ ម្ចាស់កម្មសិទ្ធិទាំងនោះមិនព្រមប្ដឹងតុលាការ ឬនាយកដ្ឋានកម្មសិទ្ធិបញ្ញា ឬការិយាល័យប្រឆាំងបទល្មើសសេដ្ឋកិច្ច ដើម្បីសុំឱ្យមន្ត្រីមានសមត្ថកិច្ចជួយដោះស្រាយឡើយ។ បើសិនការ

រំលោភបំពាននោះ នៅតែមាននៅលើទីផ្សារ នាំឱ្យមានសកម្មភាពកើនឡើង តម្លាភាពនៃការការពារម៉ាកត្រូវបានចុះខ្សោយ បាត់បង់នូវភាពជឿទុកចិត្តពីអតិថិជន ព្រោះពួកគេគិតថាផលិតផលម៉ាកដែលពួកគេបានប្រើប្រាស់នោះមានលក្ខណៈក្លែងក្លាយ ខ្វះការធានាគុណភាព។

**៣. ភាពអសកម្មភាពរបស់មន្ត្រីមួយចំនួន**

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ម៉ាកគឺជាបញ្ហាដ៏ស្មុគស្មាញមួយ ហើយការយល់ដឹងផ្នែកកម្មសិទ្ធិបញ្ញា ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលនៅមិនទាន់មានលក្ខណៈទូលំទូលាយផងដែរ។ ភាពអសកម្មរបស់មន្ត្រីមួយចំនួនតូច ក៏ជាកត្តារាំងស្ទះនៃការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធិភាពផងដែរ ព្រោះពួកគាត់មិនសូវបានយកចិត្តទុកដាក់ក្នុងការទទួលខុសត្រូវទៅលើតួនាទីអ្វីដែលពួកគាត់កំពុងកាន់កាប់នោះឡើយ។

ឧទាហរណ៍៖ ក្រុមហ៊ុនមួយ បានបញ្ញាទិញស្រាពីបរទេស ១កុងទីន័រ បន្ទាប់ពីទទួលបានភាពជោគជ័យក្នុងការធ្វើអាជីវកម្ម ក្រុមហ៊ុននោះ មានបំណងចង់សុំសិទ្ធិផ្តាច់មុខក្នុងការនាំស្រានោះចូលមកលក់ក្នុងប្រទេសរបស់ខ្លួន។ ដោយសារតែការចង់បានសិទ្ធិផ្តាច់មុខ ក្រុមហ៊ុននោះ ក៏បានសហការជាមួយមន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដើម្បីទទួលបានការចុះបញ្ជីដោយមិនទាន់មានការយល់ព្រមពីម្ចាស់ដើម។

នៅក្នុងករណីនេះ ព្រោះតែមន្ត្រីសមត្ថកិច្ចមួយចំនួនតូចគាត់មិនបានគិតដល់ពីផលវិបាកនៃការមិនមានការអនុញ្ញាតពីម្ចាស់ដើម ដោយគាត់សហការជាមួយក្រុមហ៊ុននោះ។ ហេតុនេះហើយទើបបង្កឱ្យមានការរាំងស្ទះដល់ការអនុវត្តច្បាប់ម៉ាកនៅកម្ពុជា ព្រោះតែគាត់គិតតែផលប្រយោជន៍បុគ្គល។

**កថាខណ្ឌទី៣៖ វិធានការនៃការការពារម៉ាកតាមផ្លូវច្បាប់**

ច្បាប់ម៉ាកបានកំណត់អំពីវិធានការសមស្របមួយចំនួន ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសរំលោភម៉ាកតាមរយៈការនាំចូលផលិតផលក្លែងបន្លំមកក្នុងទីផ្សារកម្ពុជា។ វិធានការទាំងនោះរួមមានវិធានការតាមមាត់ច្រកព្រំដែន និងវិធានការបណ្តោះអាសន្ន។ ការរំលោភបំពានម៉ាកត្រូវបានប្រព្រឹត្តដោយជនណាម្នាក់ក្រៅពីម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួចនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយមិនមានការយល់ព្រមពីម្ចាស់ម៉ាក។ ដើម្បីទប់ស្កាត់នូវការរំលោភបំពានសិទ្ធិរបស់ម្ចាស់ម៉ាកនីមួយៗ ដែលបានចុះបញ្ជីយ៉ាងត្រឹមត្រូវបានកំណត់នោះ ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ បានចាត់វិធានការពីរយ៉ាងក្នុងការទប់ស្កាត់គឺ វិធានការបណ្តោះអាសន្ន និងវិធានការតាមមាត់ច្រកព្រំដែន។

### ក. វិធានការបណ្ដោះអាសន្ន

វិធានការបណ្ដោះអាសន្ន គឺជាវិធានដែលតុលាការបានដាក់ចេញនូវសំណើរបស់អ្នកប្តឹង (ម្ចាស់ម៉ាក) ដើម្បីទប់ស្កាត់ការរំលោភបំពាន ដែលការរំលោភបំពាននោះប្រុងនឹងកើតមាន ឬរក្សាទុកនូវភស្តុតាងដែលពាក់ព័ន្ធអំពីការរំលោភកម្មសិទ្ធិបញ្ញារបស់ម្ចាស់ម៉ាកនីមួយៗ។[៣១]

### ១. លក្ខខណ្ឌនៃវិធានការបណ្ដោះអាសន្ន

វិធានការបណ្ដោះអាសន្ន មានលក្ខណៈជាបន្ទាន់ និងមានប្រសិទ្ធិភាពចំពោះម្ចាស់ម៉ាក ប៉ុន្តែវាអាចបណ្តាលឱ្យមានភាពអន្តរាយដែលមិនអាចជួសជុលបាន ចំពោះម្ចាស់សិទ្ធិ បើសិនជាម្ចាស់ម៉ាកមានការយឺតយ៉ាវនៅពេលដែលភស្តុតាងអាចនឹងត្រូវបានគេបំផ្លាញចោល ដោយសារការប្រើរយៈពេលយូរ។ ដើមចោទ ត្រូវគោរពនូវលក្ខខណ្ឌចំពោះការការពារនូវកម្មសិទ្ធិបញ្ញារបស់ខ្លួន ដើម្បីដាក់ចេញនូវវិធានការបណ្ដោះអាសន្ន ដែលមានលក្ខខណ្ឌដូចជា៖ [៣២]

- ភស្តុតាងត្រឹមត្រូវដែលមាន ហើយអាចធ្វើឱ្យតុលាការយល់ស្របក្នុងកម្រិតមួយគ្រប់គ្រាន់សម្រាប់សន្និដ្ឋានបញ្ជាក់ថាដើមចោទ គឺជាម្ចាស់ពិតប្រាកដ ហើយសិទ្ធិរបស់អ្នកប្តឹងកំពុងត្រូវបានគេរំលោភ ឬការរំលោភនោះអាចនឹងកើតមានកើតឡើងក្នុងពេលឆាប់ៗ។
- ប្រាក់កក់ធានាដែលតម្រូវ ឬការធានាដែលមានតម្លៃស្មើនៃប្រាក់កក់គ្រប់គ្រាន់ក្នុងការការពារចុងចម្លើយ និងទប់ស្កាត់មិនឱ្យមានការរំលោភបំពាន។ ប្រាក់កក់ធានានេះត្រូវស្ថិតនៅក្រោមការកំណត់របស់តុលាការ។

វិធានការបណ្ដោះអាសន្ន ត្រូវចេញដោយដីកាសម្រេចរបស់តុលាការ។ ប្រសិនបើមានករណីចាំបាច់តុលាការអាចតម្រូវឱ្យដើមបណ្តឹងតម្កល់ប្រាក់ធានាសមស្រប ដើម្បីធានាការខូចខាតនានាចំពោះចុងចម្លើយដែលអាចកើតមានឡើងដោយសារការអនុវត្តវិធានការនេះ។

### ២. ដំណើរការនៃវិធានការបណ្ដោះអាសន្ន

តុលាការត្រូវជូនដំណឹងដល់ម្ចាស់ម៉ាក អំពីសេចក្តីសម្រេចពីការចាត់វិធានការបណ្ដោះអាសន្ន នៅពេលដែលវិធានការត្រូវបានដាក់ចេញ ចុងចម្លើយអាចដាក់ពាក្យបណ្តឹងទៅតុលាការស្នើសុំឱ្យពិនិត្យអំពីវិធានការបណ្ដោះអាសន្នឡើងវិញ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ។ ប្រឈមនឹងបណ្តឹងសុំឱ្យពិនិត្យឡើងវិញដោយចុងចម្លើយនេះ (ករណីបើមាន) តុលាការក៏ត្រូវផ្តល់នូវឱកាសសវនាការដល់ភាគីដែលពាក់ព័ន្ធត្រូវពិនិត្យហើយត្រូវត្រួតពិនិត្យវិធានការឡើងវិញ និងតម្កល់កែតម្រូវ ឬលុបចោលនូវសេចក្តី

---

[៣១] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ០៧ កុម្ភៈ ២០០២, មាត្រា ២៩
[៣២] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ០៧ កុម្ភៈ ២០០២, មាត្រា ៣០

សម្រេចរបស់ខ្លួន នៅក្នុងរយៈពេលសមស្របមួយតាមច្បាប់កំណត់។[៣៣]

### ៣. ការលុបចោលវិធានការបណ្តោះអាសន្ន

នៅក្នុងករណីដែលដើមចោទ (ម្ចាស់សិទ្ធិ) មិនបានទទួលដំណឹងអំពីការដាក់ចេញនូវវិធានការបណ្តោះអាសន្ន នៅក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីការដាក់ចេញនូវវិធានការនេះ ឬនៅក្នុងរយៈពេលមួយសមស្របដែលបានកំណត់ដោយតុលាការ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន មិនបានផ្តួចផ្តើមបន្តសំណុំរឿងបណ្តឹង ដែលឈានទៅដល់សេចក្តីសម្រេចអំពីអង្គសេចក្តីនៃករណី តុលាការត្រូវលុបចោលនូវវិធានការបណ្តោះអាសន្ន ដោយផ្អែកតាមសំណើររបស់ចុងចម្លើយ។[៣៤] នៅពេលដែលវិធានការបណ្តោះអាសន្នត្រូវបានលុបចោល ហើយតុលាការបានរកឃើញថាគ្មានការរំលោភបំពានទេ នោះតុលាការមានសិទ្ធិសម្រេចឱ្យដើមចោទសងឱ្យចុងចម្លើយនូវសំណងសមស្រប ចំពោះការខូចខាតដែលបានកើតឡើងក្នុងការអនុវត្តវិធានការបណ្តោះអាសន្ននោះ។[៣៥]

### ខ. វិធានការតាមមាត់ច្រកព្រំដែន

វិធានការតាមមាត់ច្រកព្រំដែន គឺជាវិធានការដែលត្រូវបានប្រឆាំង និងទប់ស្កាត់នូវរាល់ទំនិញនាំចូលតាមច្រកព្រំដែនដែលម្ចាស់ម៉ាកបានដាក់ពាក្យប្តឹងទៅរដ្ឋបាលគយ ឬអាជ្ញាធរមានសមត្ថកិច្ចឱ្យឃាត់ទុកនូវទំនិញណា ដែលសង្ស័យថាជាផលិតផលក្លែងបន្លំ ដោយមានបង្ហាញនូវភស្តុតាងច្បាស់លាស់ថាគាត់ជាម្ចាស់ម៉ាកដែលមានការចុះបញ្ជីយ៉ាងត្រឹមត្រូវ។[៣៦]

### ១. តួនាទី និងភារកិច្ចរបស់ម្ចាស់ម៉ាក

ម្ចាស់ម៉ាកមានតួនាទី ធ្វើពាក្យបណ្តឹងទៅមន្ត្រីមានសមត្ថកិច្ចនៅតាមច្រកព្រំដែន ឱ្យជួយធ្វើអន្តរាគមន៍ទៅលើផលិតផលដែលក្លែងបន្លំម៉ាករបស់ខ្លួន ដើម្បីជួយទប់ស្កាត់រាល់ការរំលោភបំពានមកលើផលិតផលរបស់ខ្លួន។ ពាក្យបណ្តឹងនោះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងអមមកជាមួយលិខិតមួយចំនួនដូចជា៖[៣៧]

- វិញ្ញាបនបត្រចុះបញ្ជីម៉ាក។
- មូលហេតុនៃការប្តឹង និងភស្តុតាងបង្ហាញថាទំនិញនោះក្លែងក្លាយមែន។
- ការរៀបរាប់ដ៏ល្អិតល្អន់ពីទំនិញដែលម៉ាករបស់វាត្រូវបានប្រើប្រាស់ ព្រមទាំងគំរូនៃផលិតផល

[៣៣] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ០៧ កុម្ភៈ ២០០២, មាត្រា ៣២
[៣៤] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ០៧ កុម្ភៈ ២០០២, មាត្រា ៣៣
[៣៥] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ០៧ កុម្ភៈ ២០០២, មាត្រា ៣៤
[៣៦] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ០៧ កុម្ភៈ ២០០២, មាត្រា ៣៥
[៣៧] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ០៧ កុម្ភៈ ២០០២, មាត្រា ៣៦

ពិតប្រាកដផង ប្រសិនបើមានសំណូមពរ។

- ឈ្មោះ និងអាស័យដ្ឋានរបស់អ្នកប្តឹង និងតំណាងរបស់គេដែលត្រូវរៀបរាប់ឱ្យបានសព្វគ្រប់តាមការកំណត់។
- លិខិតអនុញ្ញាតពីម្ចាស់ម៉ាកដែលបានចុះបញ្ជី ប្រសិនបើពាក្យបណ្តឹងនោះត្រូវបានដាក់ដោយតំណាងដែលទទួលសិទ្ធិ។
- កម្រៃរដ្ឋបាលតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ។

**២. កាតព្វកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ច**

អាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងទៅដើមបណ្តឹង បន្ទាប់ពីបានទទួលនូវពាក្យបណ្តឹង ថាពាក្យបណ្តឹងរបស់ខ្លួនត្រូវបានទទួលស្គាល់ត្រឹមត្រូវ ឬបដិសេធ ឬមួយរក្សាទុកក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ។[៣៨] ហើយអាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិស្នើឱ្យអ្នកប្តឹង បង់ប្រាក់ធានា ឬតម្រូវឱ្យមានការធានា ដែលមានតម្លៃស្មើនៃប្រាក់កក់គ្រប់គ្រាន់សម្រាប់ការពារ អ្នកនាំចូល អ្នកទទួល អ្នកនាំចេញ ឬអ្នកប្តឹង និងអាជ្ញាធរមានសមត្ថកិច្ច។ ផ្អែកទៅលើប្រាក់ធានា ដែលអ្នកប្តឹងត្រូវតម្កល់ទុក យោងតាមមាត្រា ៣៨ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ បានប្បញ្ញត្តិថាប្រាក់ធានានេះត្រូវបានកំណត់តាមរបៀប និងបែបបទមួយដែលមិនឱ្យរាំងដល់ការអនុវត្តនីតិវិធីនេះដោយមិនសមហេតុផល។ ម្យ៉ាងវិញទៀត រដ្ឋបាលគយ និងរដ្ឋាករត្រូវព្យួរទុកនូវទំនិញក្នុងរយៈពេលដំបូង និងរយៈពេលដែលត្រូវបានពន្យារមិនលើសពី ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីមានការយល់ព្រមតាមពាក្យបណ្តឹង។ រដ្ឋបាលគយ និងរដ្ឋាករត្រូវជូនដំណឹងទៅអ្នកនាំចូល និងអ្នកប្តឹង អំពីការព្យួរទុកនូវការធ្វើបែបទំនិញ ហើយត្រូវបញ្ជាក់ពីមូលហេតុនៃការព្យួរ និងប្រាប់ពីអាស័យដ្ឋាន ឈ្មោះនៃអ្នកប្តឹង ដល់អ្នកនាំចូលផងដែរ។ ក្រោយពេលអ្នកប្តឹងបានទទួលដំណឹងអំពីឃាត់ទុកទំនិញ ក្នុងរយៈពេលមិនហួសពី ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បើសិនរដ្ឋបាលគយ និងរដ្ឋាករបានទទួលនូវពត៌មានថាចំណាត់ការ ដែលនាំឱ្យមានការសម្រេចនូវអង្គសេចក្តីនៃករណីមិនត្រូវផ្តួចផ្តើមឡើង ដោយភាគីមួយទៀតផ្សេងពីចុងចម្លើយ ឬអាជ្ញាធរដែលបានប្រគល់សិទ្ធិត្រឹមត្រូវមិនបានអនុវត្តន៍វិធានការបណ្តោះអាសន្ន ដើម្បីពន្យារពេលដោះលែងទំនិញទេ ទំនិញនោះនឹងត្រូវដោះលែងតែក្នុងករណីដែលមានលក្ខខណ្ឌផ្សេងៗទៀតសម្រាប់ការនាំចូល ឬនាំចេញត្រូវបានគោរព។[៣៩] ចំណែកឯអាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិសម្រេចឱ្យប្តឹងសងទៅម្ចាស់អ្នកដែលនាំចូល អ្នកនាំចេញ និងអ្នកទទួលទំនិញនូវបំណងសមស្រប ចំពោះការខូចខាតរបស់គេ ដែលបណ្តាលមក

[៣៨] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ០៧ កុម្ភៈ ២០០២, មាត្រា ៣៧
[៣៩] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ០៧ កុម្ភៈ ២០០២, មាត្រា ៤០

ពីការឃាត់ទំនិញមិនត្រឹមត្រូវ។ ក្រោយពីបានពិនិត្យទំនិញ ដែលបានបញ្ជាក់ឱ្យដឹងថាជាទំនិញក្លែងក្លាយ រដ្ឋបាលគយ និងរដ្ឋាករ អាចជូនពត៌មានទៅម្ចាស់សិទ្ធិ ដោយមិនប៉ះពាល់ដល់ការការពារនូវពត៌មានសម្ងាត់ រដ្ឋបាលគយ និងរដ្ឋាករ។ រដ្ឋបាលគយ និងរដ្ឋាករ និងអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិបំផ្លាញចោលនូវទំនិញដែលពាក់ម៉ាកក្លែងក្លាយ និងមិនអនុញ្ញាតឱ្យបន្តការនាំចេញនូវទំនិញដែលម៉ាកក្លែងក្លាយ ឬដាក់ទំនិញនោះឱ្យនៅក្រោមនីតិផ្សេងទៀតរបស់គយ។

ប្រសិនបើពិនិត្យឃើញថាទំនិញដែលត្រូវបានហាមឃាត់នោះ ជាទំនិញពាក់ម៉ាកក្លែងក្លាយ និងភស្តុតាងគ្រប់គ្រាន់ រដ្ឋបាលគយ និងរដ្ឋាករត្រូវកសាងសំណុំរឿងទៅតុលាការ។ លើសពីនេះទៅទៀត អាជ្ញាធររដ្ឋបាលគយ និងរដ្ឋាករមានសិទ្ធិបំផ្លាញទំនិញក្លែងបន្លំតាមរយៈសេចក្តីសម្រេចរបស់តុលាការ។

**គ. យន្តការស្ថាពរ**

យន្តការស្ថាពរ សំដៅដល់វិធានការរបស់តុលាការ នៅក្នុងការសម្រេចនូវអង្គសេចក្តីនៃករណីរំលោភបំពានម៉ាក ដោយចេញជាសាលក្រមវិនិច្ឆ័យក្តីលើករណីរំលោភបំពានម៉ាកនោះ។ ម្ចាស់សិទ្ធិលើម៉ាកដែលត្រូវបានគេបំពានសិទ្ធិត្រូវផ្តួចផ្តើមនូវនីតិវិធីបណ្តឹងទៅតុលាការជាចាំបាច់ បើទោះបីជាយន្តការតាមច្រកព្រំដែន ឬយន្តការបណ្តោះអាសន្ន ត្រូវបានដាក់ឱ្យដំណើរការរួចរាល់ហើយក្តី។ ដោយសារតែមានអំណាចតុលាការទេ ដែលអាចសម្រេចអំពីបទល្មើស និងទោសទណ្ឌបាន ពោល គឺមានតែសេចក្តីសម្រេចរបស់តុលាការតែប៉ុណ្ណោះ ដែលអាចប្រកាសអំពីវត្តមាននៃអំពើក្លែងបន្លំម៉ាក និងការដាក់ឱ្យដំណើរការទោសទណ្ឌលើជនល្មើស ដែលបានប្រព្រឹត្តនោះផងដែរ។ ចំណែកឯ យន្តការបណ្តោះអាសន្ន និងយន្តការតាមមាត់ច្រកព្រំដែន គឺគ្រាន់តែសម្រួលដល់ប្រសិទ្ធិភាពនៃយន្តការស្ថាពរនេះតែប៉ុណ្ណោះ។

**ឃ. ទណ្ឌកម្មប្រឆាំងនឹងអំពើក្លែងក្លាយបន្លំម៉ាក**

អំពើក្លែងបន្លំម៉ាកនេះ គឺជាកម្មវត្ថុនៃការទទួលត្រូវទាំងខាងព្រហ្មទណ្ឌ និងខាងរដ្ឋប្បវេណី។ ទណ្ឌកម្មរដ្ឋប្បវេណី សំដៅដល់ការទទួលខុសត្រូវផ្ទាល់របស់ជនល្មើសនៃអំពើក្លែងបន្លំម៉ាក ចំពោះម្ចាស់ម៉ាកដែលត្រូវបានទទួលការការពារ។ ទណ្ឌកម្មនេះ រួមមានទាំងការហាមឃាត់មិនឱ្យបន្តប្រព្រឹត្តអំពើក្លែងបន្លំម៉ាកនេះតទៅទៀត (តាមរយៈការបញ្ឈប់ការប្រើប្រាស់ម៉ាកនោះរួមទាំងការរឹបអូស និងការបំផ្លាញទំនិញដែលពាក់ម៉ាកក្លែងក្លាយនោះចោល ។ ល ។) និងតម្រូវឱ្យសងសំណងរដ្ឋប្បវេណី ក្នុងករណីក្លែងបន្លំម៉ាកនេះ ដែលជាទូទៅគឺតែងស្ថិតនៅក្រោមវិធាននៃនីតិរួម។

**១. សំណងរដ្ឋប្បវេណី**

ការទាមទារសំណងរដ្ឋប្បវេណី ជាសិទ្ធិរបស់ម្ចាស់ម៉ាក។ ច្បាប់ម៉ាកពុំចែងអំពីរូបមន្តនៃការ

កំណត់អំពីការទាមទារសំណងឡើយ ប៉ុន្តែច្បាប់ក៏ពុំបានបិទសិទ្ធិរបស់ម្ចាស់ម៉ាកក្នុងការទាមទារសំណងលើការខូចខាតដែលកើតចេញពីអំពើរំលោភបំពានសិទ្ធិរបស់ម្ចាស់ម៉ាកដែរ។ ការទាមទារសំណងអាចត្រូវបានធ្វើឡើងដោយម្ចាស់ម៉ាកស្របច្បាប់ ដោយផ្អែកទៅលើទំហំនៃព្យសនកម្ម និងភស្តុតាងបញ្ជាក់អំពីទំហំនៃព្យសនកម្មនោះ។

**១.១. ព្យសនកម្មចំពោះម្ចាស់ម៉ាកដែលកើតចេញពីការរំលោភបំពាន**

ជាគោលការណ៍ ដោយពុំគិតពីការទាមទារសំណងលើសោហ៊ុយចំណាយផ្សេងៗក្នុងការចាត់នីតិវិធីប្រឆាំងនឹងការរំលោភបំពាន សំណងរដ្ឋប្បវេណីអាចត្រូវបានទូទាត់ ដោយផ្អែកទៅលើការខូចខាតក្នុងបីតំណាក់កាលគឺៈ សំណងលើព្យសនកម្មជាក់ស្តែងនាពេលបច្ចុប្បន្ន សំណងលើព្យសនកម្មនាអនាគត និងសំណងព្យសនកម្មរាប់ចាប់ពីពេល ដែលអំពើរំលោភបំពានកើតមាន។ សំណងទាំងបីតំណាក់កាលនោះ អាចទាមទារក្នុងពេលតែមួយតាមរយៈបណ្តឹងរបស់ម្ចាស់ម៉ាកទៅតុលាការ។[៩០]

**១.២. សំណងលើព្យសនកម្មជាក់ស្តែងនាពេលបច្ចុប្បន្ន**

អំពើរំលោភបំពានម៉ាកដែលត្រូវបានប្រព្រឹត្តឡើងដោយជនរំលោភបំពានបានបង្កឱ្យមានផលប៉ះពាល់ដល់ផលប្រយោជន៍របស់ម្ចាស់ម៉ាក ដែលកំពុងធ្វើអាជីវកម្មលើទីផ្សារ។ មិនតែប៉ុណ្ណោះ អំពើរំលោភបំពានម៉ាកបានធ្វើឱ្យម្ចាស់ម៉ាកស្របច្បាប់បាត់បង់នូវលទ្ធភាពប្រកួតប្រជែងលើទីផ្សារ ដោយអតិថិជនរបស់ខ្លួនបានបង្វែរទិសដៅទៅប្រើប្រាស់ទំនិញក្លែងក្លាយដែលមានតម្លៃថោកជាងទំនិញរបស់ម្ចាស់ម៉ាកដើម។ ក្នុងករណីនេះ ម្ចាស់ម៉ាកមានសិទ្ធិទាមទារសំណងលើការខូចខាតដែលកំពុងតែកើតមានដែលបណ្តាលមកពីអំពើក្លែងក្លាយរបស់អ្នករំលោភបំពាននេះ។

**១.៣.សំណងលើព្យសនកម្មនាពេលអនាគត**

អំពើរំលោភបំពានលើម្ចាស់ម៉ាកស្របច្បាប់ មិនត្រឹមតែបង្កព្យសនកម្មក្នុងអំឡុងពេលនៃការរកឃើញអំពើរំលោភបំពាននោះទេ។ គោលដៅនៃម៉ាក គឺដើម្បីទាក់ទាញអតិថិជន និងទំនុកចិត្តរបស់អ្នកប្រើប្រាស់មកលើផលិតផលរបស់សហគ្រាស ឬបុគ្គលម្ចាស់ម៉ាកនោះ។

ផលិតផលក្លែងបន្លំមិនត្រឹមតែធ្វើឱ្យម្ចាស់ម៉ាកដើមខាតបង់នូវរបបអាជីវកម្ម (ក្សយធន) របស់គាត់តែប៉ុណ្ណោះទេ តែថែមទាំងបាត់បង់នូវទំនុកចិត្តពីអ្នកប្រើប្រាស់ទូទៅ ដែលកើតចេញពីភាពមិនសមស្របនៃផលិតផលក្លែងបន្លំរបស់អ្នករំលោភបំពាន។

ការខាតបង់ទាំងផ្នែកសេដ្ឋកិច្ច សម្ភារៈ ជាពិសេសទំនុកចិត្តរបស់អ្នកប្រើប្រាស់អាចត្រូវអូសបន្លាយពេលដល់ទៅរាប់សិបឆ្នាំនាពេលអនាគតក៏មាន។ ក្នុងករណីនេះ ការខូចខាតដែលអាចកើត

[៩០] នី វិចិត្រ, *"នីតិកម្មសិទ្ធិបញ្ញាកម្ពុជា"* (២០១៣) , ២៣៧។

មានឡើង និងអាចទូទាត់បាននាអនាគតអាចជាកម្មវត្ថុនៃការទាមទារសំណងពីអ្នករំលោភបំពានដោយម្ចាស់ម៉ាក។

### ១.៤. សំណងព្យសនកម្មរាប់ចាប់ពីពេលដែលអំពើរំលោភបំពានកើតមាន

ដូចគ្នានេះដែរ ប្រសិនបើអំពើរំលោភបំពាននោះ ត្រូវបានអនុវត្តន៍អស់មួយរយៈពេលណាមួយនោះ រហូតដល់ពេលម្ចាស់សិទ្ធិបានដឹងអំពីរំលោភបំពានម្ចាស់ម៉ាកមានសិទ្ធិទាមទារសំណងលើការខូចខាតសមមូលទាំងឡាយ ដោយរាប់ចាប់ពីចំណុចចាប់ផ្តើមនៃអំពើរំលោភសិទ្ធិរហូតដល់ពេលដែលម្ចាស់សិទ្ធិស្របច្បាប់ចាត់វិធានការរាំងខ្ទប់អំពើរំលោភសិទ្ធិនោះ។

### ២. ទោសព្រហ្មទណ្ឌ

ជនណាដែលក្លែងបន្លំពាណិជ្ជសញ្ញា សេវាសញ្ញា ម៉ាកសមូហភាព ឬពាណិជ្ជនាមរបស់សហគ្រាសមួយផ្សេងទៀតដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចដែលមានចែងក្នុងមាត្រា ១១ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន) រៀល ដល់ ២០.០០០.០០០(ម្ភៃលាន) រៀល និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ដល់ ៥(ប្រាំ) ឆ្នាំ ឬទោសណាមួយនៃទោសទាំងពីរនេះ ចំពោះជនណាដែលនាំចូល លក់ ប្រកាសលក់ ឬមានបំណងលក់ ដោយចេតនានូវទំនិញដែលមានម៉ាកក្លែងបន្លំ ឬមានចេតនាផ្តល់សេវាចំពោះសេវាសញ្ញា ម៉ាកសមូហភាព ឬពាណិជ្ជនាមក្លែងបន្លំ ត្រូវបានផ្តន្ទាទោសដូចដែលបានរៀបរាប់ខាងលើ។[៤១] នៅក្នុងករណីដែលជននោះ មិនរាងចាល មាត្រា ៦៧ នៃច្បាប់ម៉ាក បានចែងអំពីការផ្តន្ទាទោសទ្វេរដង ទាំងទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ។ នៅក្នុងករណីដែលជនល្មើសដែលត្រូវទទួលខុសត្រូវ គឺជានីតិបុគ្គលវិញ ការទទួលខុសត្រូវទៅដល់នាយកគ្រប់គ្រង អ្នកចាត់ការ ឬតំណាងនៃនីតិបុគ្គលនោះផងដែរ លើកលែងតែពួកគេអាចបង្ហាញភ័ស្តុតាងតាមរយៈនីតិបុគ្គលនោះ ថាពួកគេពុំបានដឹងឮ ឬពុំបានយល់ស្របនឹងបទល្មើសក្លែងបន្លំម៉ាកនេះឡើយ។[៤២]

## ផ្នែកទី២៖ ការរំលោភបំពានសិទ្ធិអ្នកនិពន្ធនៅកម្ពុជា

ថ្វីត្បិតតែកម្ពុជាមានច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដើម្បីការពារលស្នាដៃដែលបង្កើតឡើងក៏ពិតមែន ក៏ប៉ុន្តែការលេចឡើងនៃអំពើរំលោភបំពាននៅតែកើតមានឡើងជារឿយៗ។ ដូចនេះ យើងនឹងធ្វើការសិក្សាទៅលើចរិតលក្ខណៈនៃការរំលោភបំពានសិទ្ធិ (កថាខណ្ឌទី១) ក៏ដូចជា វិធានការនៃការការពារសិទ្ធិរបស់អ្នកនិពន្ធ (កថាខណ្ឌទី២) និងតម្លាភាពនៃការ

[៤១] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ០៧ កុម្ភៈ ២០០២, មាត្រា៦៤, មាត្រា ៦៥ និង មាត្រា ៦៦

[៤២] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ០៧ កុម្ភៈ ២០០២, មាត្រា ៦៨

អនុវត្តច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ (កថាខណ្ឌទី៤) ព្រមទាំងស្វែងយល់អំពីបញ្ហាប្រឈម និងផលប៉ះពាល់ដែលកើតចេញពីអំពើរំលោភបំពានសិទ្ធិរបស់អ្នកនិពន្ធនេះ (កថាខណ្ឌទី៣) ផងដែរ។

## កថាខណ្ឌទី១៖ ចរិតលក្ខណៈនៃការរំលោភបំពានសិទ្ធិអ្នកនិពន្ធ

### ក. លក្ខណៈនៃអំពើរំលោភបំពានសិទ្ធិអ្នកនិពន្ធ

តើអំពើណាខ្លះ ដែលអាចចាត់ទុកថាជាអំពើរំលោភសិទ្ធិរបស់អ្នកនិពន្ធនៅក្នុងនីតិកម្ពុជា? ជាធម្មតាអំពើដែលត្រូវបានចាត់ទុកថាជាអំពើរំលោភសិទ្ធិអ្នកនិពន្ធនូវរាល់អំពើនៃការប្រើប្រាស់ ការចម្លងទាំងស្រុង ឬដោយផ្នែក ការផ្សព្វផ្សាយទាំងស្រុង ឬដោយផ្នែក តាមគ្រប់មធ្យោបាយដោយពុំមានការអនុញ្ញាតពីសំណាក់អ្នកនិពន្ធ។ អំពើរំលោភសិទ្ធិអ្នកនិពន្ធ សំដៅទៅលើការរំលោភសិទ្ធិបេតិកភណ្ឌ និង/ឬ សិទ្ធិសីលធម៌របស់អ្នកនិពន្ធ។

ការរំលោភលើសិទ្ធិបេតិកភណ្ឌសំដៅទៅលើការធ្វើអាជីវកម្ម ការផលិតឡើងវិញនូវស្នាដៃ ឬការចែកចាយស្នាដៃ ដោយពុំមានការអនុញ្ញាតពីអ្នកនិពន្ធស្នាដៃ។ អំពើរំលោភសិទ្ធិសីលធម៌សំដៅទៅលើអំពើនៃការកែប្រែខ្លឹមសារនៃស្នាដៃ ការដក ឬការដាក់បន្ថែមនូវខ្លឹមសារ ឬធាតុណាមួយនៃស្នាដៃ ការលុបឈ្មោះអ្នកនិពន្ធចេញពីស្នាដៃដោយពុំមានការអនុញ្ញាតពីម្ចាស់សិទ្ធិ។

### ១. រូបភាពនៃអំពើរំលោភបំពានសិទ្ធិអ្នកនិពន្ធ

សិទ្ធិបេតិកភណ្ឌ ឬសិទ្ធិសេដ្ឋកិច្ចរបស់អ្នកនិពន្ធ សំដៅទៅលើសិទ្ធិដែលអាចប្តូរជាប្រាក់បានតាមរយៈការធ្វើអាជីវកម្មលើស្នាដៃ ការផ្ទេរសិទ្ធិបេតិកភណ្ឌលើស្នាដៃឱ្យទៅតតីយជនដោយទទួលបាននូវកម្រៃតបស្នង។ សកម្មភាពដូចបានរៀបរាប់ខាងលើដោយពុំមានការអនុញ្ញាតពីម្ចាស់សិទ្ធិត្រូវបានចាត់ទុកថាជាអំពើរំលោភលើសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ។ បុគ្គលណាដែលបានលួចចម្លងស្នាដៃដោយពុំមានការអនុញ្ញាតពីម្ចាស់ស្នាដៃ ក្នុងគោលដៅធ្វើអាជីវកម្មបន្ត ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ត្រូវបានចាត់ទុកថាជាអំពើរំលោភសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ និងត្រូវទទួលទណ្ឌកម្មតាមច្បាប់។ អំពើដែលត្រូវបានចាត់ទុកថាជាបទល្មើស មានដូចខាងក្រោម៖

- ការផលិត ឬការនាំចូលដើម្បីដាក់លក់ ឬដាក់ជួលនូវឧបករណ៍ ឬគ្រឿងមធ្យោបាយណាមួយដែលធ្វើឡើង ឬយកលំនាំតាមក្នុងគោលបំណងឱ្យរាំងស្ទះដំណើរការល្អនៃឧបករណ៍ ឬគ្រឿងមធ្យោបាយទូទៅ ឬកាត់បន្ថយចំនួនការផលិតឡើងវិញនៃស្នាដៃហ្វូណូក្រាម ឬការផ្សាយតាមទូរផ្សាយ ឬធ្វើឱ្យខូចខាតគុណភាពនូវច្បាប់ចម្លង។ ការផលិត ឬការនាំចូលដើម្បីដាក់លក់ ឬដាក់ជួលនូវឧបករណ៍ ឬគ្រឿងមធ្យោបាយណាមួយដែលនាំឱ្យបុគ្គលគ្មានសិទ្ធិទទួលបានកម្មវិធីផ្សាយតាមសញ្ញា លេខកូដ ដែលផ្សាយតាមទូរផ្សាយ ឬផ្សាយជាសាធារណៈ តាមវិធីផ្សេង រួមមានការផ្សាយតាមផ្កាយរណប។

- ការលុបចោល ឬការកែប្រែពត៌មានស្តីពីរបបសិទ្ធិតាមទម្រង់អេឡិចត្រូនិច ដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ។
- ការចែកចាយ ឬការនាំចូលដើម្បីចែកចាយការផ្សាយតាមអង្គភាពទូរផ្សាយ ការផ្សាយ ជាសាធារណៈ ឬការដាក់ជូនសាធារណៈជននូវស្នាដៃ ឬការសម្តែង ឬហ្វូណូក្រាម ឬកម្មវិធីផ្សាយនៃអង្គភាពទូរផ្សាយដោយគ្មានការអនុញ្ញាត ហើយអ្នកប្រព្រឹត្តដឹងច្បាស់ថាពត៌មានស្តីពីរបបសិទ្ធិតាមទម្រង់អេឡិចត្រូនិចជាព័ត៌មានដែលត្រូវគេលុបចោល ឬកែប្រែរួចហើយ។

**២. ការរំលោភសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ**

ការរំលោភសិទ្ធិបេតិកភណ្ឌ គឺជាការរំលោភសិទ្ធិផ្តាច់មុខរបស់អ្នកនិពន្ធដែលរួមមានសិទ្ធិផលិតឡើងវិញ សិទ្ធិផ្សព្វផ្សាយជាសាធារណៈ សិទ្ធិបង្កើតស្នាដៃបន្ត និងសិទ្ធិផ្សេងៗទៀតក្នុងការប្រកបអាជីវកម្ម។

**២.១. សិទ្ធិផលិតឡើងវិញ**

សិទ្ធិផលិតឡើងវិញជាច្បាប់ដ៏សំខាន់សម្រាប់សិទ្ធិអ្នកនិពន្ធ គឺត្រូវបានផ្តល់ឱ្យចំពោះតែអ្នកនិពន្ធប៉ុណ្ណោះ ព្រោះវាទាក់ទងនឹងការគ្រប់គ្រងសិទ្ធិបោះពុម្ព។ រាល់ស្នាដៃនីមួយៗដែលអ្នកនិពន្ធខិតខំផលិតឡើង នៅពេលមានជនណាម្នាក់លួចយកទៅបោះពុម្ពឬថតចម្លងទៅលក់ឱ្យតតីយជនម្នាក់ទៀតដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធទេ នោះជាការរំលោភទៅលើសិទ្ធិផលិតឡើងវិញរបស់អ្នកនិពន្ធ។

**២.២. សិទ្ធិផ្សព្វផ្សាយជាសាធារណៈ**

បុគ្គលណាម្នាក់ ដែលមានបំណងធ្វើការចែកចាយនូវស្នាដៃមួយជាលក្ខណៈពាណិជ្ជកម្មចាំបាច់ត្រូវសុំការអនុញ្ញាតជាមុនពីអ្នកនិពន្ធ បើមិនដូច្នោះទេ ការបំពានលើសិទ្ធិចែកចាយប្រាកដជាកើតឡើង។ យ៉ាងណាក៏ដោយ ការផ្សាយបន្តផ្ទាល់តាមទូរផ្សាយដោយមិនមានការអនុញ្ញាតនូវរឿងដដែលនោះ មិនមែនជាការរំលោភបំពានលើសិទ្ធិចែកចាយនោះទេ ពីព្រោះឯកសារឬក៏ម៉ាស៊ីនថតសម្លេង មិនត្រូវបានគេចែកចាយជាសាធារណៈនោះទេ តែវាអាចជាការរំលោភបំពានលើសិទ្ធិសម្តែងជាសាធារណៈ។

បុគ្គលទាំងឡាយណាដែលយកស្នាដៃគេទៅសម្តែងជាសាធារណៈ គឺជាការរំលោភទៅលើសិទ្ធិសម្តែងជាសាធារណៈរបស់អ្នកនិពន្ធ កាលណាអ្នកនោះគ្មានការអនុញ្ញាតពីអ្នកនិពន្ធជាមុននោះទេ។ ចំពោះករណីក្រុមហ៊ុនមួយផ្តល់កន្លែងឱ្យអង្គុយដោយគិតថ្លៃ ហើយបញ្ចាំងខ្សែភាពយន្តឱ្យសាធារណៈជនចូលទស្សនា ការបញ្ចាំងដោយគ្មានការអនុញ្ញាតបែបនេះ អាចជាការរំលោភបំពានសិទ្ធិគ្រប់គ្រងការសម្តែងជាសាធារណៈ។ យោងតាមសេចក្តីសម្រេចរបស់តុលាការមួយចំនួន

បានកំណត់ថា ប្រសិនបើក្រុមហ៊ុនបានជួលកាសែតវីដេអូ ហើយបញ្ចាំងវានៅក្នុងរោងកណ្ដាលវាល ការបញ្ចាំងបែបនេះអាចជាការសម្ដែងជាសាធារណៈ ដូចនេះត្រូវតែទទួលបានការអនុញ្ញាតពីអ្នកនិពន្ធ ទោះបីជាយ៉ាងណាក៏ដោយ តុលាការបានលើកឡើងថាការជួលការសែតវីដេអូសម្រាប់បញ្ចាំងនៅក្នុងបន្ទប់នៃសណ្ឋាគារវិញ មិនមែនជាការរំលោភបំពានលើសិទ្ធិសម្ដែងជាសាធារណៈទេ ហើយតុលាការបានលើកឡើងទៀតថាការជួលកាសែតយកទៅបញ្ចាំងនៅតាមផ្ទះ ក៏មិនមែនជាការរំលោភបំពានដែរ។

ដោយសារតែមានភាពរីកចម្រើននៃបច្ចេកវិទ្យា បានបង្កនូវបញ្ហាជាច្រើន នៅក្នុងវិស័យអ្នកនិពន្ធ។ ភាពរីកចម្រើននៃបច្ចេកវិទ្យានោះ រួមមានការប្រើប្រាស់ផ្កាយរណបនៅក្នុងលំហអាកាសដើម្បីពង្រីកនូវប្រភេទនៃសញ្ញាគ្មានខ្សែ ការកើនឡើងលទ្ធភាពនៃការភ្ជាប់វិទ្យុ និងទូរទស្សន៍ទៅនឹងសញ្ញាទាំងឡាយដែលត្រូវបានផ្សាយតាមខ្សែកាប្លិ៍ និងការកើនឡើងនៃការប្រើប្រាស់នៃសម្ភារៈដែលអាចថតសម្លេង និងរូបភាពដែលត្រូវបានផ្សាយតាមទូរផ្សាយឬខ្សែកាប្លិ៍។ ការរីកចម្រើនទាំងនេះហើយ ធ្វើឱ្យមានបុគ្គលមួយចំនួនបានប្រើប្រាស់នូវបច្ចេកវិទ្យាទាំងនេះ ដើម្បីលួចចាប់យកនូវរូបភាព ឬសម្លេងផ្សេងៗយកមកប្រើប្រាស់ដោយខុសច្បាប់។

**ឧទាហរណ៍:** អ្នកនិពន្ធបានអនុញ្ញាតឱ្យស្ថានីយ៍ទូរទស្សន៍មួយចាក់ផ្សាយនូវស្នាដៃរបស់គាត់ក្នុងរយៈពេល៣ថ្ងៃ បើស្ថានីយ៍ទូរទស្សន៍នោះនៅតែបន្តការចាក់ផ្សាយលើសពីចំនួនថ្ងៃ ដែលបានកំណត់ថាជាការបំពានលើសិទ្ធិអ្នកនិពន្ធ។

### ២.៣. សិទ្ធិបង្កើតស្នាដៃបន្ត និងសិទ្ធិផ្សេងៗទៀតក្នុងការប្រកបអាជីវកម្ម

បុគ្គលណាម្នាក់ដែលមានបំណងបង្កើតស្នាដៃបន្ត ចាំបាច់ត្រូវតែសុំការអនុញ្ញាតជាមុនពីអ្នកនិពន្ធ បើមិនដូច្នោះទេ ជាការរំលោភបំពានលើសិទ្ធិបង្កើតស្នាដៃបន្ត បានកើតមានយ៉ាងប្រាកដឡើង។ យើងដឹងហើយថា អ្នកនិពន្ធមានសិទ្ធិធ្វើការបកប្រែស្នាដៃរបស់ខ្លួនជាភាសាបរទេស បុគ្គលទាំងឡាយណាដែលមានបំណងចង់ធ្វើការបកប្រែស្នាដៃនេះទៅជាភាសាបរទេស ត្រូវតែសុំការអនុញ្ញាតពីម្ចាស់សិទ្ធិអ្នកនិពន្ធជាមុនសិន បើពុំដូច្នោះទេ នឹងរំលោភទៅលើសិទ្ធិបកប្រែរបស់អ្នកនិពន្ធជាមិនខាន។

**ឧទាហរណ៍:** ក្រុមហ៊ុនមួយបាននាំចូលនូវខ្សែភាពយន្តមួយមកលក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅក្នុងការលក់ខ្សែភាពយន្តនេះ គាត់បានទទួលការអនុញ្ញាតឱ្យលក់ស្នាដៃនោះ ជាភាសាដើមរបស់ប្រទេស ដែលគាត់ទទួលបានការអនុញ្ញាតប៉ុណ្ណោះ។ តែដោយយល់ឃើញថារឿងនេះលក់មិនសូវដាច់ ពីព្រោះវានិយាយជាភាសាបរទេស ក្រុមហ៊ុននេះក៏បានធ្វើការបកប្រែទៅជាភាសាខ្មែរ។

ក្នុងករណីនេះ ក្រុមហ៊ុនបានរំលោភសិទ្ធិបកប្រែស្នាដៃរបស់អ្នកនិពន្ធ ឬម្ចាស់សិទ្ធិអ្នកនិពន្ធ ដោយក្រុមហ៊ុនបានបកប្រែស្នាដៃដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធឬម្ចាស់សិទ្ធិអ្នកនិពន្ធ។

មុនសតវត្សរ៍ទី២០ អ្នកនិពន្ធពិបាកការពារសិទ្ធិរបស់ស្នាដៃរបស់ខ្លួនណាស់ ជាពិសេស គឺពិបាកក្នុងការហាមឃាត់អ្នកដទៃមិនឱ្យយកលំនាំតាមស្នាដៃដែលគាត់បានបង្កើត តួយ៉ាង អ្នកនិពន្ធប្រលោមលោកម្នាក់មិនអាចបញ្ឈប់ អ្នកនិពន្ធរឿងល្ខោន ពីការយកលំនាំតាមរឿងប្រលោមលោករបស់គាត់ សម្រាប់ការសម្តែងលើឆាកនោះទេ។

### ២.៤. សិទ្ធិថត

បុគ្គលទាំងឡាយណា ដែលមានបំណងចង់ថតនូវស្នាដៃរបស់អ្នកនិពន្ធត្រូវតែសុំការអនុញ្ញាតជាមុនសិន។ ប្រសិនបើបុគ្គលណាចង់ថតសម្លេង ដោយថតតែទំនុកភ្លេង ឬក៏ទំនុកច្រៀងទេនោះ គេគ្រាន់តែសុំការអនុញ្ញាតពីម្ចាស់សិទ្ធិអ្នកនិពន្ធនៃទំនុកភ្លេង ឬទំនុកចម្រៀងនោះតែប៉ុណ្ណោះ។ បើគេចង់ថតទាំងទំនុកភ្លេង និងទំនុកចម្រៀង គេត្រូវតែសុំការយល់ព្រមពីម្ចាស់ទំនុកភ្លេងផង និងម្ចាស់ទំនុកចម្រៀងផងដែរ។

ក្នុងករណីដែលគេមិនទទួលបានការអនុញ្ញាតពីម្ចាស់ទំនុកភ្លេង ឬក៏ទំនុកចម្រៀងទេនោះគេនឹងរំលោភទៅលើសិទ្ធិអ្នកនិពន្ធរបស់ម្ចាស់ទំនុកភ្លេង ឬទំនុកចម្រៀង តែបើគេទទួលបានការអនុញ្ញាតតែម្ខាងពីម្ចាស់ទំនុកភ្លេង ឬទំនុកចម្រៀង ហើយគេថតទាំងទំនុកភ្លេង និងទំនុកចម្រៀង ជាការរំលោភទៅលើសិទ្ធិអ្នកនិពន្ធនៃម្ចាស់ទំនុកភ្លេង ឬទំនុកចម្រៀង ដែលគេពុំបានទទួលការអនុញ្ញាត។

**ឧទាហរណ៍:** លោក **ឯល ប៊ុនណា** ជាអ្នកនិពន្ធទាំងទំនុកច្រៀងនិងទំនុកភ្លេងនៃបទចម្រៀង "ដំបៅដួងចិត្ត"។ ដូចនេះ បើសិនមានបុគ្គលណាមួយថតបទចម្រៀងនោះដោយគ្មានការអនុញ្ញាតពីគាត់ទេ បុគ្គលនោះអាចនឹងរំលោភទៅលើសិទ្ធិថតរបស់គាត់។

### ២.៥. សិទ្ធិជួល

មានតែអ្នកនិពន្ធតែប៉ុណ្ណោះដែលមានសិទ្ធិជួលស្នាដៃរបស់ខ្លួន បើមានបុគ្គលណាមួយក្រៅ ពីអ្នកនិពន្ធ បានយកស្នាដៃរបស់អ្នកនិពន្ធទៅជួលឱ្យទៅបុគ្គលដទៃទៀត បើបុគ្គលនោះនឹងរំលោភទៅលើសិទ្ធិអ្នកនិពន្ធរបស់អ្នកនិពន្ធជាពុំខាន។

**ឧទាហរណ៍:** តូបមួយកន្លែងបានទិញថាសដើមនៃខ្សែភាពយន្តរឿងទុំទាវមកដាក់ជួល ដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិអ្នកនិពន្ធទេ ករណីនេះជាការរំលោភបំពានសិទ្ធិជួលរបស់ម្ចាស់សិទ្ធិអ្នកនិពន្ធ។ ផ្ទុយទៅវិញ គាត់នឹងលែងត្រូវចាត់ទុកថារំលោភទៅលើសិទ្ធិអ្នកនិពន្ធតទៅទៀត កាលណាគាត់បានទទួលនូវសិទ្ធិស្របច្បាប់ពីអ្នកនិពន្ធឱ្យយកស្នាដៃនោះទៅជួល។ ចំពោះកម្មវិធីកុំព្យូ

ទ័រដែលមិនមែនជាកម្មវត្ថុសំខាន់សម្រាប់ការដាក់ជូល។

**២.៦. សិទ្ធិនាំចូលស្នាដៃចម្លង**

ទាក់ទងនឹងការនាំចូលស្នាដៃចម្លងចេញពីស្នាដៃដើម របស់អ្នកនិពន្ធគឺមានតែអ្នកនិពន្ធខ្លួនឯងប៉ុណ្ណោះដែលមានសិទ្ធិនាំចូល។ បុគ្គលទាំងឡាយពុំមានសិទ្ធិនេះទេ ប្រសិនបើគេនាំចូលស្នាដៃទាំងនោះ នោះគេនឹងរំលោភទៅលើសិទ្ធិនាំចូលស្នាដៃរបស់អ្នកនិពន្ធហើយ។

សរុបមកការរំលោភបំពានសិទ្ធិអ្នកនិពន្ធ ច្រើនតែកើតមានឡើងនៅពេលដែលមានបុគ្គលណាមួយ ថតចម្លង បោះពុម្ព សម្តែង ផ្សព្វផ្សាយតាមទូរផ្សាយ ឬយកលំនាំតាមទាំងអស់ ឬផ្នែកសំខាន់នៃស្នាដៃដោយគ្មានការអនុញ្ញាតពីអ្នកបង្កើតស្នាដៃក្នុងគោលបំណងរកប្រាក់ចំណេញ។

**ខ. ទិដ្ឋភាពនៃអំពើរំលោភសិទ្ធិអ្នកនិពន្ធ**

**១. មូលហេតុនៃអំពើរំលោភសិទ្ធិរបស់អ្នកនិពន្ធ**

អំពើរំលោភសិទ្ធិអ្នកនិពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានកើតឡើងអាចមានមូលហេតុផ្សេងៗជាច្រើនដែលបានជំរុញឱ្យមានអំពើរំលោភបំពានសិទ្ធិអ្នកនិពន្ធ។ ខាងក្រោមនេះ គឺជាមូលហេតុមួយចំនួនដែលជំរុញឱ្យមានអំពើរំលោភសិទ្ធិអ្នកនិពន្ធកើតឡើង៖

- បញ្ហាសេដ្ឋកិច្ច

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានជីវភាពរបស់ប្រជាជនកម្ពុជានៅមានកម្រិតនៅឡើយ ដែលជាហេតុធ្វើឱ្យអំពើរំលោភសិទ្ធិអ្នកនិពន្ធមានចំនួនច្រើន ពីព្រោះទំនិញដែលលួចចម្លងតែងតែមានតម្លៃថោកជាងទំនិញដើម ហើយអ្នកប្រើប្រាស់មានការចូលចិត្តនឹងផលិតផលលួចចម្លងទាំងនេះណាស់ដោយសារវាមានតម្លៃថោក។ ប៉ុន្តែ ការចូលចិត្តទិញផលិតផលលួចចម្លងនេះមានផលប៉ះពាល់យូរអង្វែង ព្រោះដោយសារតែបរិមាណនៃពេលវេលាការប្រឹងប្រែង ទេពកោសល្យ ជំនាញ និងប្រភពធនធានទាំងឡាយដែលបានដាក់ទុននៅក្នុងការបង្កើតស្នាដៃថ្មីនោះ ដោយរំពឹងថានឹងទទួលបានការតបស្នងផ្នែកសេដ្ឋកិច្ចពីការងាររបស់ខ្លួន ប៉ុន្តែជាលទ្ធផល គឺអាចមានបញ្ហាដោយសារបុគ្គលរំលោភសិទ្ធិអ្នកនិពន្ធ។

- ការយល់ដឹង

ការយល់ដឹងពីការរំលោភបំពានសិទ្ធិអ្នកនិពន្ធ ក៏ជាមូលហេតុមួយនៃការរំលោភសិទ្ធិអ្នកនិពន្ធផងដែរ ដោយសារតែប្រជាជនមួយចំនួនមិនបានយល់ដឹងថាអ្វីទៅជាសិទ្ធិអ្នកនិពន្ធ? ហើយការរំលោភសិទ្ធិអ្នកនិពន្ធមានផលប៉ះពាល់អ្វីខ្លះ? ជាការពិតរាជរដ្ឋាភិបាលកម្ពុជាមានការខិតប្រឹងប្រែងយ៉ាងខ្លាំងក្នុងការអប់រំប្រជាពលរដ្ឋ អំពីបញ្ហាពាក់ព័ន្ធ ទៅនឹងសិទ្ធិអ្នកនិពន្ធ ដូចជាតាមរយៈសិក្ខាសាលា ការអនុម័តច្បាប់ និងលិខិតដ្ឋានគតិយុត្តិជាច្រើន។ល។ ប៉ុន្តែប្រជាជនមួយចំនួនមិនបាន

ចាប់អារម្មណ៍ និងខ្វាយខ្វល់អំពីបញ្ហានេះឡើយ ដោយពួកគេគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន (ជាពិសេសផលប្រយោជន៍ខាងសេដ្ឋកិច្ច) ដែលអាចធ្វើឱ្យមានផលប៉ះពាល់ប្រយោជន៍ធ្ងន់ធ្ងរទៅពេលអនាគត។ ការមិនយល់ដឹងផ្នែកសិទ្ធិអ្នកនិពន្ធនេះ បានធ្វើឱ្យមានអំពើរំលោភសិទ្ធិកើតមានឡើង ប្រសិនបើបុគ្គលគ្រប់រូបមិនបានយល់ដឹងថាអ្វីជាអំពើរំលោភសិទ្ធិអ្នកនិពន្ធផង តើបុគ្គលនោះអាចធ្វើការជៀសវាងពីអំពើរំលោភសិទ្ធិអ្នកនិពន្ធបានយ៉ាងដូចម្ដេច ?

- មនសិការ

ដោយឡែកចំពោះបុគ្គលខ្លះទៀតបានយល់ដឹងច្បាស់ថាអ្វីទៅជាសិទ្ធិអ្នកនិពន្ធ? ព្រមទាំងដឹងទៀតថា ការរំលោភសិទ្ធិអ្នកនិពន្ធមានប៉ះពាល់យ៉ាងដូចម្ដេចខ្លះ? ប៉ុន្តែពួកគេនៅតែប្រព្រឹត្តអំពើរំលោភសិទ្ធិអ្នកនិពន្ធដោយសារតែពួកគេមិនមានមនសិការ ឬសតិសម្បជញ្ញៈដើម្បីធ្វើការកែប្រែនូវកំហុសខុសឆ្គងរបស់ខ្លួនឡើងវិញ។ ការមិនមានមនសិការ ឬសតិសម្បជញ្ញៈក្នុងការគោរពសិទ្ធិអ្នកនិពន្ធជាបញ្ហាមួយយ៉ាងចម្បងដែលនាំឱ្យកើតមានអំពើរំលោភសិទ្ធិអ្នកនិពន្ធ។ មូលហេតុដែលធ្វើឱ្យពួកគេមិនមានមនសិការ ឬសតិសម្បជញ្ញៈក្នុងការគោរពសិទ្ធិអ្នកនិពន្ធ ដោយសារតែពួកគេមិនបានឱ្យតម្លៃទៅលើសិទ្ធិអ្នកនិពន្ធ ឬស្នាដៃរបស់អ្នកនិពន្ធដែលបានខិតខំបង្កើតឡើង។

- កង្វះខាតការអនុវត្តច្បាប់

នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានលិខិតបទដ្ឋានគតិយុត្តិជាច្រើនដែលពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធព្រមទាំងការពារមិនឱ្យមានការរំលោភសិទ្ធិអ្នកនិពន្ធ ប៉ុន្តែសិទ្ធិអ្នកនិពន្ធក្នុងផ្នែកកម្មសិទ្ធិបញ្ញាជាសិទ្ធិមួយដែលមានលក្ខណៈទូលំទូលាយ ដែលជាមូលហេតុធ្វើឱ្យមានកង្វះខាតលិខិតបទដ្ឋានគតិយុត្តិមួយចំនួនសម្រាប់ធ្វើការគ្រប់គ្រងទៅលើវិស័យអ្នកនិពន្ធផងដែរ។ ជាក់ស្ដែងប្រទេសកម្ពុជាគឺមិនទាន់មានលិខិតបទដ្ឋានគតិយុត្តិគ្រប់គ្រាន់ពាក់ព័ន្ធនឹងអ្នកប្រើប្រាស់ រោងពុម្ពបណ្ណាគារ វិធានការត្រួតពិនិត្យផ្សេងៗ។ ល ។ ដែលជាហេតុធ្វើឱ្យបុគ្គលមួយចំនួនឆ្លៀតឱកាសធ្វើការរំលោភបំពានសិទ្ធិអ្នកនិពន្ធ។

ទោះបីជាមានមូលហេតុជាច្រើន ដែលធ្វើឱ្យមានកើតឡើងនូវអំពើរំលោភបំពានសិទ្ធិអ្នកនិពន្ធនៅកម្ពុជាក៏ដោយ ក៏រាជរដ្ឋាភិបាលបានខិតខំព្យាយាមយ៉ាងខ្លាំងក្នុងការលុបបំបាត់អំពើរំលោភសិទ្ធិអ្នកនិពន្ធទាំងនោះ ហើយជាលទ្ធផល គឺបានធ្វើឱ្យអំពើរំលោភបំពានសិទ្ធិអ្នកនិពន្ធមួយចំនួនធំត្រូវបានកាត់បន្ថយ។

### ២. បុគ្គលពាក់ព័ន្ធនឹងអំពើរំលោភសិទ្ធិរបស់អ្នកនិពន្ធ

អនុលោមទៅតាមច្បាប់ដែលបានកំណត់ និយមន័យពាណិជ្ជករ គឺជាបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលធ្វើពាណិជ្ជកិច្ច ហើយដែលយកពាណិជ្ជកិច្ចនេះ ជាមុខរបររបស់ខ្លួនជាប្រចាំ

ដោយពាណិជ្ជកិច្ច គឺជាសកម្មភាពទិញ លក់ទំនិញ ឬសេវាដែលត្រូវអនុវត្តជាប្រចាំ ក្នុងគោលដៅធ្វើការដោះដូរ និងស្វែងរកប្រាក់ចំណេញ។ ចំពោះពាណិជ្ជករទាំងឡាយណា ដែលធ្វើអាជីវកម្មទៅលើស្នាដៃរបស់អ្នកនិពន្ធដែលមិនមានការអនុញ្ញាតពីអ្នកនិពន្ធ គឺជាការរំលោភបំពានសិទ្ធិអ្នកនិពន្ធ ដោយត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់ (បណ្តឹងរដ្ឋប្បវេណី ឬបណ្តឹងព្រហ្មទណ្ឌ)។

- ករណីការរំលោភបំពានសិទ្ធិអ្នកនិពន្ធដោយអ្នកប្រកបអាជីវកម្មសេវាថតចម្លង

អាជីវកម្មសេវាថតចម្លងឯកសារគ្រប់ប្រភេទ សេវាចម្លងបោះពុម្ពលើក្រដាស សាច់សំពត់ ជ័រប្លាស្ទិច និងលោហធាតុគ្រប់ប្រភេទ សេវាថតចម្លង បទចម្រៀង ឬរូបភាពបញ្ចូលក្នុងទូរស័ព្ទ ឬឧបករណ៍អេឡិចត្រូនិចដទៃទៀត។ អ្នកដែលប្រកបអាជីវកម្មរោងពុម្ព ឬអាជីវកម្មសេវាថតចម្លងផ្សេងៗអាចជាបុគ្គលដែលរួមចំណែក ក្នុងការរំលោភសិទ្ធិអ្នកនិពន្ធប្រសិនបើមិនមានលិខិតបទដ្ឋានគតិយុត្តិគ្រប់គ្រាន់សម្រាប់ការគ្រប់គ្រងរោងពុម្ព ឬដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិគ្រប់ពេលវេលា។ ការអនុញ្ញាតឱ្យប្រកបអាជីវកម្មរោងពុម្ព ឬសេវាថតចម្លង គឺជាការអនុញ្ញាតឱ្យធ្វើការថតចម្លង ឬផលិតឡើងវិញ ប៉ុន្តែការអនុញ្ញាតបែបនេះមិនមែនមានន័យថាអាចធ្វើការថតចម្លងគ្រប់ករណីនោះទេ គឺត្រូវគោរពសិទ្ធិអ្នកនិពន្ធផងដែរ។

ការបើកអាជីវកម្មសេវាថតចម្លងត្រូវសុំការអនុញ្ញាត ពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីខេត្ត ឬតាមការិយាល័យច្រកចេញចូលតែមួយនៃក្រុង ស្រុក ខណ្ឌ គោលដៅដែលបានទទួលការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ទោះបីជាទទួលបានការអនុញ្ញាត ក្នុងការបើកអាជីវកម្មសេវាថតចម្លងក៏ដោយ ក៏បុគ្គលនោះមិនត្រូវបានអនុញ្ញាតឱ្យលួចចម្លង និង បោះពុម្ពស្នាដៃគ្រប់ប្រភេទ (សៀវភៅ ឯកសារ គំនូរ រូបភាព។ ល ។) ឬស្នាដៃសោតទស្សន៍ ដើម្បីធ្វើអាជីវកម្មសម្រាប់ផ្សព្វផ្សាយ ឬចែកចាយឯកសារដែលមានគោលដៅធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សង្គមនោះទេ។ ផ្ទុយទៅវិញ ប្រសិនបើរោងពុម្ព ឬបុគ្គលដែលប្រកបអាជីវកម្មសេវាថតចម្លងបានធ្វើការថតចម្លង អាចជាបុគ្គលមួយដែលដើរតួយ៉ាងសំខាន់ក្នុងការរំលោភសិទ្ធិអ្នកនិពន្ធ ប្រសិនបើមិនមានការត្រួតពិនិត្យ ឬគ្រប់គ្រងបានត្រឹមត្រូវទៅលើរោងពុម្ព ឬអ្នកប្រកប អាជីវកម្មសេវាថតចម្លងទាំងនោះ។

- ករណីរំលោភសិទ្ធិអ្នកនិពន្ធដោយអ្នកប្រកបអាជីវកម្មសេវាកម្មសៀវភៅ

បណ្ណាគារ គឺជាទីកន្លែងលក់ទំនិញ ដែលភាគច្រើនទាក់ទងនឹងស្នាដៃអក្សរសាស្ត្រ និងសិល្បៈ (សៀវភៅ ឌីស។ ល ។) ប៉ុន្តែក៏អាចមានទំនិញផ្សេងៗដែលក្រៅពីស្នាដៃអក្សរសាស្ត្រ និងសិល្បៈ ផងដែរ។ ដោយមូលហេតុថាបណ្ណាគារ គឺជាទីកន្លែងលក់ទំនិញដែលភាគច្រើនទាក់ទងទៅនឹងស្នាដៃអក្សរសាស្ត្រ និងសិល្បៈ នោះអាចនាំឱ្យបណ្ណាគារ ក្លាយទៅជាកន្លែងដែលរំលោភសិទ្ធិ

អ្នកនិពន្ធ បើការដាក់លក់ស្នាដៃទាំងនោះមិនទាន់មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ឬមិនមានលិខិតបទដ្ឋានគតិយុត្តិគ្រប់គ្រាន់សម្រាប់ធ្វើការគ្រប់គ្រងអាជីវកម្មបណ្ណាគារ។ បណ្ណាគារ ជាទីតាំងអាជីវកម្មលក់សៀវភៅក្នុងទីផ្សារ ឬតាមទីសាធារណៈ ប៉ុន្តែក៏មិនត្រូវបានអនុញ្ញាតឱ្យយកសៀវភៅថតចម្លងមកដាក់លក់ក្នុងកន្លែងធ្វើអាជីវកម្មរបស់ខ្លួនឡើយ។ ការបើកជាបណ្ណាគារ ឬទីតាំង អាជីវកម្មលក់សៀវភៅវប្បធម៌ និងវិចិត្រសិល្បៈ ហើយការប្រកបអាជីវកម្មនាំចេញនាំចូល សៀវភៅគ្រប់ប្រភេទត្រូវមានការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

ការបកស្រាយខាងលើនេះ មិនមែនមានន័យថាឱ្យតែបុគ្គលដែលប្រកបអាជីវកម្មសេវាថតចម្លង និងបុគ្គលដែលប្រកបអាជីវកម្មលក់សៀវភៅធ្វើការរំលោភសិទ្ធិអ្នកនិពន្ធនោះទេ។ ផ្ទុយទៅវិញ ជាការបង្ហាញមួយដែលឱ្យដឹងថា ប្រភេទខាងលើនេះគឺជាបុគ្គលដែលពាក់ព័ន្ធជិតស្និទ្ធជាងគេក្នុងអំពើរំលោភសិទ្ធិអ្នកនិពន្ធ។ ដូចនេះ ដើម្បីជៀសវាងការរំលោភសិទ្ធិអ្នកនិពន្ធ ពីប្រភេទបុគ្គលទាំងនេះ គប្បីគួរតែមានវិធានគតិយុត្ត និងវិធានការសមរម្យក្នុងការត្រួតពិនិត្យ។ម្យ៉ាងវិញទៀត ពាណិជ្ជករដែលប្រកបប្រភេទអាជីវកម្មផ្សេងៗ ក៏អាចជាបុគ្គលដែលធ្វើការរំលោភសិទ្ធិអ្នកនិពន្ធ ហើយពាណិជ្ជករដែលប្រកបប្រភេទអាជីវកម្មផ្សេងៗ ក៏អាចជាបុគ្គលដែលធ្វើការរំលោភសិទ្ធិអ្នកនិពន្ធផងដែរ ប្រសិនបើបានប្រព្រឹត្តអំពើណាមួយដែលបញ្ញត្តិដោយច្បាប់ថាជាបទល្មើសនៃការរំលោភសិទ្ធិអ្នកនិពន្ធ ដោយត្រូវប្ដឹងពីបទល្មើសព្រហ្មទណ្ឌ ឬជាបណ្ដឹងរដ្ឋប្បវេណី។

**អ្នកប្រើប្រាស់**

អ្នកប្រើប្រាស់សំដៅទៅលើបុគ្គលសាមញ្ញដែលទិញស្នាដៃរបស់អ្នកនិពន្ធយកមកប្រើប្រាស់ដោយគ្មានបំណងធ្វើអាជីវកម្មស្វែងរកប្រាក់ចំណេញ។ ជាគោលការណ៍ទូទៅបុគ្គលដែលត្រូវបានឱ្យធ្វើការទទួលខុសត្រូវក្នុងការរំលោភសិទ្ធិអ្នកនិពន្ធឡើយ ព្រោះអ្នកប្រើប្រាស់ជាបុគ្គលដែលត្រូវបានសន្មតជាមុនថាជាបុគ្គលដែលគ្មានជំនាញ ( មិនដឹងថាស្នាដៃនោះ ជាទំនិញដែលរំលោភសិទ្ធិអ្នកនិពន្ធ )។ ម្យ៉ាងវិញទៀតអនុលោមតាមច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល គឺការផលិតឡើងវិញចំនួន ១ ច្បាប់ ជាលក្ខណៈឯកជននូវស្នាដៃដែលបានបោះពុម្ពផ្សាយ ហើយសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន មិនមែនជាការរំលោភសិទ្ធិអ្នកនិពន្ធឡើយ ទោះបីជាមិនមានការអនុញ្ញាតពីអ្នកនិពន្ធ ឬម្ចាស់ សិទ្ធិលើស្នាដៃក៏ដោយ។ ការលើកលែងមិនឱ្យអ្នកប្រើប្រាស់ធ្វើការទទួលខុសត្រូវចំពោះ ការរំលោភសិទ្ធិអ្នកនិពន្ធអនុញ្ញាតឱ្យតែចំពោះ សិទ្ធិបេតិកភណ្ឌប៉ុណ្ណោះ។ ចំពោះសិទ្ធិសីលធម៌របស់អ្នកនិពន្ធ គឺអ្នកប្រើប្រាស់ត្រូវទទួលខុសត្រូវ ប្រសិនបើអ្នកប្រើប្រាស់បានរំលោភសិទ្ធិអ្នកនិពន្ធ ដូចជាការដកស្រង់នូវអត្ថបទ ឬខ្លឹមសារខ្លីៗ ក្នុងក្របខណ្ឌធ្វើការសិក្សា គឺត្រូវមានបញ្ជាក់ពីប្រភពដូចជា ឈ្មោះរបស់អ្នកនិពន្ធជាដើម។ ផ្ទុយទៅវិញ បើការដកស្រង់នូវអត្ថបទ ឬខ្លឹមសារខ្លីៗ

នោះមិនមានបញ្ជាក់ពីប្រភពនោះ វាអាចជាការរំលោភសិទ្ធិអ្នកនិពន្ធ។

ខាងលើជាការបកស្រាយខ្លះៗ ចំពោះអ្នកប្រើប្រាស់ ក្នុងការរំលោភសិទ្ធិអ្នកនិពន្ធប៉ុណ្ណោះ ហើយក្នុងព្រះរាជាណាចក្រកម្ពុជា គឺមិនទាន់ឃើញមានលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងអ្នកប្រើប្រាស់ឡើយ។ អនុលោមតាមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល គឺអ្នកប្រើប្រាស់អាចរួចផុតពីការទទួលខុសត្រូវចំពោះការរំលោភសិទ្ធិអ្នក និពន្ធពាក់ព័ន្ធនឹងសិទ្ធិបេតិកភណ្ឌ ប៉ុន្តែមិនអាចរួចផុតពីការទទួលខុសត្រូវចំពោះការរំលោភសិទ្ធិអ្នកនិពន្ធ ដែលពាក់ព័ន្ធទៅនឹងសិទ្ធិសីលធម៌ឡើយ។

## កថាខណ្ឌទី២៖ បញ្ហាប្រឈម និងផលប៉ះពាល់ពីការរំលោភបំពានសិទ្ធិអ្នកនិពន្ធ

### ក. បញ្ហាប្រឈមនៃការរំលោភបំពានសិទ្ធិអ្នកនិពន្ធក្នុងគថភាពសង្គម

កម្មសិទ្ធិបញ្ញា សំដៅដល់ប្រភេទនៃទ្រព្យសម្បត្តិដែលផ្តើមចេញពីការបង្កើតដោយគំនិតរបស់មនុស្ស។ ការការពារស្នាដៃរបស់អ្នកសរសេរសៀវភៅត្រូវបានការពារ ដោយច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលជាផ្នែកមួយនៃកម្មសិទ្ធិបញ្ញា ត្រូវបានគេអនុវត្តយ៉ាងម៉ឺងម៉ាត់ក្នុងប្រទេសដែលអភិវឌ្ឍន៍។ ក៏ប៉ុន្តែការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញានេះ គឺជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាកម្ពុជា ដោយសារតែវាជាប្រធានបទថ្មីនៅឡើយសម្រាប់ប្រទេសកម្ពុជា ហើយអាជីវករ និងអ្នកអានមួយចំនួនធំនៅមិនទាន់យល់ច្បាស់ពីច្បាប់និងការគោរពកម្មសិទ្ធិបញ្ញារបស់អ្នកនិពន្ធនៅឡើយ។

ចំនួនគ្រឹះស្ថានបោះពុម្ពផ្សាយសៀវភៅ និងការអានសៀវភៅនៅក្នុងប្រទេសកម្ពុជាមានការកើនឡើងគួរឱ្យកត់សម្គាល់ ប៉ុន្តែការការពារកម្មសិទ្ធិបញ្ញាមានភាពធូរលុងនៅឡើយ។ ទន្ទឹមនឹងនេះដែរ ចំណុចដែលគួរឱ្យបារម្ភ គឺទាក់ទងនឹងការលួចចម្លង លក់នៅតាមទីផ្សារ និង បណ្ណាគារ។ ការលួចចម្លងនូវស្នាដៃអ្នកនិពន្ធ ឬអត្ថបទសរសេរអ្នកដទៃមកធ្វើជាកម្មសិទ្ធិ និងដាក់ឈ្មោះរបស់ខ្លួនជាទំនៀមទម្លាប់មួយដែលមិនចេះរីងស្ងួតហើយកើតឡើងជាយូរណាស់មក ហើយនិងបានបន្តរហូតដល់បច្ចុប្បន្ននេះសម្រាប់សង្គមកម្ពុជា។ នាពេលបច្ចុប្បន្ននេះ ការបោះពុម្ពសៀវភៅនៅកម្ពុជាមានការកើនឡើងដល់ទៅ ២ ម៉ឺនចំណងជើង សៀវភៅ និងមានស្ថាប័នបោះពុម្ពផ្សាយប្រមាណជិត ៦០០ ស្ថាប័ន។ ប៉ុន្តែទោះជាយ៉ាងនេះក្តី អ្នកសរសេរសៀវភៅបានរអ៊ូរទាំពីការលួចចម្លងស្នាដៃដាក់លក់តាមទីផ្សារភ្លាមៗបន្ទាប់ពីស្នាដៃដើមបានចេញផ្សាយ។

ជាក់ស្តែង ចំពោះការចម្លងអត្ថបទសរសេរតាមប្រព័ន្ធអ៊ីនធើណែតពីវេបសាយ (website) ទៅដាក់ក្នុងវេបសាយមួយផ្សេងទៀតមានច្រើន និងមានភាពអនាធិបតេយ្យបំផុត។ រាល់ការចម្លងទាំងនោះពេលខ្លះមិនមានការអនុញ្ញាតពីម្ចាស់ប្រភពឡើយ ហើយការចម្លងភាគច្រើនចម្លងទាំងស្រុងតែ

ម្តងពេលខ្លះក៏ប្រាប់ពីប្រភពតែមិនបានបង្ហាញនូវឈ្មោះរបស់ម្ចាស់ស្នាដៃនោះទេ ដែលជាហេតុនាំឱ្យបាត់បង់នូវស្នាដៃអ្នកនិពន្ធ ឈ្មោះអ្នកនិពន្ធ និងអាចបំបាក់ទឹកចិត្តរបស់ពួកគាត់ដែលខិតខំស្វែងរកនូវគំនិតនិងរបកគំហើញថ្មីជាក់ស្តែងពិតប្រាកដ។

**ខ. ផលប៉ះពាល់នៃការរំលោភចំពានលើសិទ្ធិអ្នកនិពន្ធ**

**១. ការប៉ះពាល់សិទ្ធិរបស់អ្នកនិពន្ធ**

ដើម្បីលើកទឹកចិត្តដល់អ្នកបង្កើតស្នាដៃទាំងឡាយ អ្នកនិពន្ធ ក្នុងន័យនៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល គឺត្រូវតែជាបុគ្គលដែលបានបង្កើតស្នាដៃនោះដោយផ្ទាល់ទើបអាចក្លាយជាម្ចាស់កម្មសិទ្ធិបញ្ញ លើស្នាដៃដែលសាមីអ្នកនិពន្ធបានបង្កើតនោះ។ ឋានៈជាអ្នកនិពន្ធ គឺជាឋានៈរបស់បុគ្គលម្នាក់ ឬច្រើននាក់ជាម្ចាស់កម្មសិទ្ធិលើស្នាដៃដែលសាមីខ្លួនបានបង្កើតឡើងហើយស្នាដៃនោះត្រូវបានផ្សព្វផ្សាយជាសាធារណៈលើកលែងតែមានភស្តុតាងផ្ទុយ។ បើយោងតាមមាត្រានេះ គោលការណ៍នៃការទទួលបានឋានៈ ឬគុណភាពជាអ្នកនិពន្ធស្នាដៃត្រូវបានដាក់ឱ្យចំណុះទៅនឹងលក្ខខណ្ឌគ្រឹះតែមួយគត់ ពោលគឺស្ថានភាពនៃការបង្កើតស្នាដៃដែលច្បាប់ទទួលស្គាល់មួយ។ ចំណែកឯការផ្សព្វផ្សាយស្នាដៃជាសាធារណៈ គឺគ្រាន់តែជាលក្ខខណ្ឌទម្រង់មួយដើម្បីអនុញ្ញាតឱ្យសាធារណៈជនដឹងឮអំពីគុណភាពជាអ្នកនិពន្ធស្នាដៃដែលត្រូវបានការពាររួចរាល់ប៉ុណ្ណោះ ( លក្ខខណ្ឌនៃភស្តុតាង )។

នៅក្នុងន័យនេះ បើស្នាដៃមួយត្រូវបានយកទៅផ្សព្វផ្សាយជាសាធារណៈ នៅក្រោមឈ្មោះរបស់បុគ្គលដែលពុំមែនជាអ្នកបង្កើតស្នាដៃនោះទេបុគ្គលរូបនោះ នឹងទទួលបាន ឋានៈជាអ្នកនិពន្ធជាគោលការណ៍ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា១១។ ក៏ប៉ុន្តែ បុគ្គល ដែលជាអ្នកបង្កើតស្នាដៃនោះដោយផ្ទាល់ នៅតែអាចប្រឆាំងជំទាស់ទៅនឹងឋានៈ ជាគោលការណ៍នេះបានដែលតាមរយៈការបង្ហាញភស្តុតាងផ្ទុយ ពោលគឺភស្តុតាងដែលថាគឺរូបខ្លួនទេ ដែលមានគុណភាពជាម្ចាស់ស្នាដៃនោះយ៉ាងពិតប្រាកដ។ ម៉្យាងទៀត ការទទួលស្គាល់ជាគោលការណ៍នេះក៏អាចត្រូវបានបកស្រាយថាប្រសិនបើគ្មានបណ្តឹងជំទាស់ណាមួយពីសំណាក់ អ្នកនិពន្ធពិតប្រាកដដែលបានបង្កើតស្នាដៃនោះទេ នឹងអាចបកស្រាយនៅក្នុងសម្មតិកម្មពីរយ៉ាង ទី១ គឺបុគ្គល ដែលបានប្រើប្រាស់ឈ្មោះលើស្នាដៃនោះហើយគឺជាអ្នកនិពន្ធស្នាដៃនោះយ៉ាងពិតប្រាកដ ឬមួយទី២ គាត់បានទទួលសិទ្ធិជាអ្នកតំណាងឱ្យអ្នកនិពន្ធដែលបាន បង្កើតស្នាដៃនោះទាំងសិទ្ធិបេតិកភណ្ឌនិង ទាំងសិទ្ធិសីលធម៌រហូតដល់គុណភាពជាអ្នកនិពន្ធពិតប្រាកដត្រូវបានអះអាង។ សម្រាប់ន័យចុងក្រោយនេះ គុណភាពជាអ្នកតំណាងគឺពុំមែនកើតចេញពីកិច្ចព្រមព្រៀងណាមួយនោះឡើយ ប៉ុន្តែវាបានកើតឡើងដោយការសន្មតរបស់ច្បាប់ ដែលគ្រាន់តែជាសច្ចាធារណ៍ធម្មតា ពោលគឺអាចនឹងបង្ហាញភស្តុតាងដែលផ្ទុយតាមគ្រប់

មធ្យោបាយបាន។

យោងតាមគោលការណ៍ខាងលើនេះដែរហាន: ឬគុណភាពជាអ្នកនិពន្ធស្នាដៃមួយ គឺពុំត្រូវចំណុះទៅនឹងលក្ខខណ្ឌផ្សេងទៀត ដូចជាការចុះបញ្ជី ឬការតម្កល់ទុកស្នាដៃណាមួយជាដើមនោះឡើយ ពីព្រោះតែការទទួលស្គាល់គុណភាព ឬហាន:នេះ នឹងត្រូវទទួលបានដោយស្វ័យប្រវត្តិដោយគ្រាន់តែចំណុះទៅនឹងស្ថានភាពនៃការណ៍ដែលបានបង្កើតស្នាដៃនិពន្ធមួយឡើងដោយស្របទៅតាមច្បាប់កំណត់ប៉ុណ្ណោះ។

**២. ផលអវិជ្ជមានក្នុងវិស័យវប្បធម៌**

ក្រោយពេលសង្គ្រាម ខ្មែរយើងមានឥរិយាបថផ្ទុយពីដូនតា ពោលគឺហាក់មិនសូវគោរពច្បាប់ រំលោភបំពានលួចចម្លងស្នាដៃអ្នកដទៃមកធ្វើអាជីវកម្ម ជាហេតុបង្កឱ្យមានការរាំងស្ទះការតាក់តែងនិពន្ធបង្កើតផលិតផលថ្មីខាងវប្បធម៌ និងការធ្វើវិនិយោគជាកត្តានាំឱ្យមានការរីកចម្រើនយឺត និងប៉ះពាល់ដល់ការពង្រឹងនីតិរដ្ឋ។ បើនៅមានបន្តបាតុភូតការដែលមិនគោរពច្បាប់នេះ នៅក្នុងសម័យដែលកម្ពុជា ជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកនោះ កម្ពុជាមិនត្រឹមតែគ្មានផលិតផលវប្បធម៌សម្រាប់ប្រកួតប្រជែងជាអន្តរជាតិប៉ុណ្ណោះទេ ថែមទាំងរក្សាការពារវប្បធម៌ជាតិខ្លួន មិនបានទៀតផង។

ទំនើបកម្មសង្គម សង្គម ដែលកើតឡើងដោយសារភាពរីកចម្រើន នៅវិស័យព័ត៌មាន (IT)ធ្វើឱ្យសិល្ប: ដែលជាទម្រង់មួយនៃវប្បធម៌ ដែលជាមធ្យោបាយទាញអារម្មណ៍មហាជនយ៉ាងសំខាន់ជាពិសេសអាចនាំទៅរកផ្លូវល្អ ឬអាក្រក់បាននោះ ជាក់ស្តែងវិស័យអក្សរសិល្ប៍ បានធ្លាក់ចុះថមថយឥទ្ធិពលខ្លួនយ៉ាងខ្លាំង និងប្រឈមមុខទៅរួមទាំងបញ្ហាជាច្រើន។ ពីមុនស្នាដៃអក្សរសិល្ប៍ផ្នែកប្រលោមលោកប៉ុណ្ណោះ ដែលមានអ្នកនិពន្ធដ៏តិចតួចប៉ុណ្ណោះ បាននិពន្ធឡើង និងមានអ្នកនិយមអានសៀវភៅប្រលោមលោកកាន់តែតិចទៅៗ ចំណែកទីផ្សារភាពយន្ត គឺស្ទើរតែគ្មានសោះតែម្តង និងមានក្នុងបរិមាណដ៏តិចតួចតែងនិពន្ធរឿងសម្រាប់យកទៅសម្តែងល្ខោនវិទ្យុនិងទូរទស្សន៍។

បើក្រឡេកមកមើលក្នុងទម្រង់វិស័យសិល្ប:វិញ ចម្រៀងគឺជាចំណែកសំខាន់មួយដែលឆ្លុះបញ្ចាំងពីអត្តសញ្ញាណនៃប្រទេសជាតិនីមួយៗ។ ចម្រៀងមានតួនាទីផ្សព្វផ្សាយវប្បធម៌ អរិយធម៌ និងបង្កើនសក្តានុពលសេដ្ឋកិច្ច និងកិត្យានុភាពល្អដល់ប្រទេសកម្ពុជា។ កវីនិពន្ធអាចប្រើប្រាស់បទចម្រៀងអោយអន្ទងយកភាពសោការបស់មនុស្សម្នាក់ៗបាន និងជាកញ្ចក់ដែលអាចឆ្លុះបញ្ចាំងពីទិដ្ឋភាពសង្គម។ ប្រជាពលរដ្ឋដែលនិយមស្តាប់ចម្រៀងលើកឡើងថា បទចម្រៀងភាគច្រើនចម្លងពីគេដោយគ្មានការនិពន្ធ និងច្នៃប្រឌិតស្នាដៃដោយខ្លួនឯង។ ការមិនបង្កើនគុណភាពសរសេរបទចម្រៀងនេះបានបណ្តាលឱ្យមហាជនរិះគន់ថា បទចម្រៀងសម័យថ្មីល្បីមិនយូរ ស៊ូនឹងបទចម្រៀង

ចាស់ៗមិនបាន។ បទចម្រៀងដែលខ្វះគុណភាពនេះហើយ ដែលជាហេតុបណ្តាលឱ្យបាត់បង់កិត្តិយស និងកិត្យានុភាពរបស់កម្ពុជា។ ដោយឡែកអំពីទំនុកច្រៀង ដែលជាផ្នែកមួយនៃស្នាដៃអក្សរសិល្ប៍ដែរនោះ ដោយសារការរីកចម្រើននៃប្រពន្ធបច្ចេកវិទ្យាព័ត៌មាន និងដើម្បីរត់ឱ្យទាន់ចរន្តទីផ្សារមានការលួចចម្លងយ៉ាងភ្លូកទឹកភ្លូកដី នូវទំនុកច្រៀង និងបទភ្លេង (បរទេស) យ៉ាងបំពានលើច្បាប់កម្មសិទ្ធិបញ្ញា។

ទាំងអស់នេះហើយជាហេតុធ្វើឱ្យស្ថានភាពវិជ្ជាជីវៈរបស់អ្នកនិពន្ធធ្លាក់ចុះ ធ្វើឱ្យអ្នកនិពន្ធមិនអាចបំពេញតួនាទីភារកិច្ចជាអ្នកអក្សរសិល្ប៍បានពិតប្រាកដ គាប់ជួនក្នុងកាលៈទេសៈខ្លះមិនបានចូលរួមប្រាស្រ័យជាមួយសហគមន៍បាន។

**គ. តម្លាភាពនៃការអនុវត្តច្បាប់**

ក្រោយពីឆ្នាំ ១៩៩៣ ចាប់ផ្តើមមានការបោះពុម្ពឡើងវិញនូវស្នាដៃចាស់ៗ និងមានសៀវភៅនិពន្ធថ្មីៗប្រសូតកាន់តែច្រើនវិញ។ ប៉ុន្តែដោយសារទម្លាប់ឱ្យតម្លៃទៅលើការអានត្រូវបានថយចុះនោះ គេមិនសូវជាមានការឱ្យតម្លៃទៅលើស្នាដៃនិពន្ធប៉ុន្មានទេ។ លើសពីនេះទៅទៀត យើងឃើញថា មានការលួចបោះពុម្ពចម្លង និងថតចម្លងស្នាដៃរបស់គេស្អេកស្កះយ៉ាងអានាធិបតេយ្យដែលធ្វើឱ្យអ្នកដែលអាចមានស្នាដៃនិពន្ធសៀវភៅផ្សេងៗមានការធ្លាក់ទឹកចិត្តកាន់តែខ្លាំង និងមិនមានទឹកចិត្តរក្សាមរតកចំពោះវិជ្ជាខ្លួនទៅក្នុងសៀវភៅទេ។

ដោយឃើញបែបនេះ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងបង្កើត និងអនុម័តច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣។ ច្បាប់នេះមានគោលបំណងការពារស្នាដៃសិទ្ធិរបស់អ្នកនិពន្ធផលិតករទាំងឡាយ និងដើម្បីជាការលើកទឹកចិត្តឱ្យកាន់តែមានការចូលរួម និងធ្វើឱ្យមានការរីកចម្រើនលើវិស័យនេះ។ ប៉ុន្តែមកទល់នឹងពេលនេះ តើការចម្លងស្នាដៃរបស់គេនៅតែមានដែរឬទេ? បើមានតើមនុស្សប៉ុន្មាននាក់ហើយ ដែលត្រូវផ្តន្ទាទោសដោយសារច្បាប់នេះ?

ពិតមែនតែមានការដោះស្រាយបញ្ហាការធ្វើច្បាប់នេះ គឺជាចំណុចអាទិភាពមួយ ហើយការគ្រាន់តែមានច្បាប់វាមិនគ្រប់គ្រាន់នោះទេ វាត្រូវការឱ្យមានការអនុវត្តច្បាប់នោះ ឱ្យមានប្រសិទ្ធិភាពថែមទៀត។ ប្រសិនបើមិនមានការអនុវត្តច្បាប់នាមួយនោះទេ គេត្រូវពិនិត្យមើលថា តើមកពីហេតុអ្វី? តើមកពីខ្វះយន្តការអនុវត្តន៍ដែលមានប្រសិទ្ធិភាព? ឬតើមកពីអ្នកអនុវត្តន៍ខ្វះសមត្ថភាព? និយាយរួម ភាពអប្រសិទ្ធិភាពក្នុងការអនុវត្តអាចមកពីកត្តាច្រើនយ៉ាង ដែលកត្តាសំខាន់គឺមានបីដែលបានរៀបរាប់ខាងលើ។ មានច្បាប់ល្អ វាហាក់ដូចជាផ្ទះរបស់អ្នកដែលមាន ម៉ាស៊ីនត្រជាក់ល្អ មានទូរទឹកកកល្អ និងសម្ភារៈអេឡិចត្រូនិចល្អដូច្នោះដែរ។ របស់ល្អៗទាំងនោះនឹងឥតប្រយោជន៍ ឬ

ទៅជាខូចវិញ ប្រសិនបើជាតខ្សែមិនប្រយ័ត្ន ឬមិនល្អ។ ពោល គឺយើងត្រូវការប្រព័ន្ធអគ្គិសនីល្អ។ នៅក្នុងប្រព័ន្ធច្បាប់ ដូចជា ច្បាប់ស្តីពីនីតិវិធី គឺជាប្រព័ន្ធ ដែលអាចនឹងអនុវត្តន៍ដោយមានប្រសិទ្ធិភាពបាន។ បច្ចុប្បន្ននេះ យើងមានតែច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌរដ្ឋកម្ពុជាឆ្នាំ១៩៩៣ យើងមាននីតិវិធីខ្លះចែងក្នុងច្បាប់អ៊ុនតាក់ដែរ តែច្បាប់នោះ មិនត្រូវបានតុលាការយកចិត្តទុកដាក់នោះទេ។ យើងមិនទាន់មានច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីនោះទេ ពោល គឺយើងយកផ្នែកខ្លះពីច្បាប់ព្រហ្មទណ្ឌមកប្រើដែលពេលខ្លះនាំឱ្យមានការរិះគន់ពីប្រជាពលរដ្ឋ។ ដោយឃើញថាមានការខ្វះខាត និងមានការរិះគន់យ៉ាងច្រើនបែបនេះ ហើយបានរាជរដ្ឋាភិបាលប្រឹងប្រែងធ្វើច្បាប់ទាំងពីរនេះ គឺនីតិវិធីព្រហ្មទណ្ឌ និងនីតិវិធីរដ្ឋប្បវេណី ដោយឱ្យជំនាញការបារាំងជួយខាងនីតិវិធីព្រហ្មទណ្ឌ ហើយជំនាញការជប៉ុនជួយខាងនីតិវិធីរដ្ឋប្បវេណី ដោយផ្អែកលើកត្តាសង្គម និងស្ថានភាពជាក់ស្តែងនៅប្រទេសកម្ពុជា មិនត្រូវចម្លងច្បាប់ខ្លួនទាំងស្រុងឡើយ។

ទោះបីជាមានច្បាប់និងនីតិវិធីល្អក៏ដោយ កាលបើមិនមានការប្រគល់តួនាទីច្បាស់លាស់ដល់ស្ថាប័នណាជាអ្នកអនុវត្តន៍នោះទេ និងមិនមានការផ្សព្វផ្សាយដល់មន្ត្រីអនុវត្តន៍ច្បាប់ នៅមានកត្តាជាច្រើនទៀត ដូចជាអំណាចចាប់ខ្លួន ភាពច្របូកច្របល់នៃអំណាចស៊ើបអង្កេតរបស់មន្ត្រីមានសមត្ថកិច្ច កង្វះខាតនៃភស្តុតាង។ ទម្លាប់នេះ អាចនឹងធ្វើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងប្រហាក់ប្រហែលមិនអាចអនុវត្តន៍បានដែរ។

**១. អានុភាពនៃច្បាប់សិទ្ធិអ្នកនិពន្ធ**

ដើម្បីអាចការពារមិនឱ្យមានអំពើរំលោភសិទ្ធិអ្នកនិពន្ធនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព និងជោគជ័យ គឺត្រូវពិនិត្យអំពីអានុភាពច្បាប់ដែលពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធ ថាតើវាមានអានុភាពកម្រិតណា? ហើយមានលក្ខណៈបែបណា? ដូចនេះក្នុងចំណុចនេះ នឹងធ្វើការសិក្សាលើអានុភាពមិនប្រតិសកម្មនៃច្បាប់ (ចំណុច ១.១) និង ឥទ្ធិពលនៃច្បាប់អន្តរជាតិ (ចំណុច ១.២)។

**១.១. អានុភាពមិនប្រតិសកម្មនៃច្បាប់**

ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ មានអានុភាពចាប់ពីពេលដែលច្បាប់នេះចូលជាធរមាន។ ច្បាប់នេះ មានគោលបំណងធានាឱ្យមានការគោរពសិទ្ធិអ្នកនិពន្ធ និងការពារផលិតវប្បធម៌ជាស្នាដៃ អ្នកនិពន្ធ អ្នកសម្តែង ផលិតករ ហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ដែលសំដៅធានាការធ្វើអាជីវកម្មមួយត្រឹមត្រូវស្របច្បាប់លើផលិតផលវប្បធម៌ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍវិស័យវប្បធម៌។ ពោលគឺ ការពារមិនឱ្យជនទុច្ចរិតធ្វើការរំលោភបំពានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។

ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនេះ មានអានុភាពចាប់បង្ខំឱ្យអនុវត្តន៍នៅក្នុងដែនដីព្រះរាជាណាចក្រកម្ពុជាទាំងមូល ដោយគ្មានបុគ្គលណាម្នាក់អាចធ្វើការប្រកែកថាមិនដឹង មិនយល់មិនចេះពីច្បាប់នេះឡើយ។ ម្យ៉ាងវិញទៀត បទបញ្ញត្តិទាំងឡាយណា ដែលមានលក្ខណៈផ្ទុយពីច្បាប់ស្តីពីសិទ្ធិនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ត្រូវចាត់ទុកជានិរាករណ៍ ហើយក្រោយពេលដែលច្បាប់ស្តីពីអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ចូលជាធរមាននៅក្នុងប្រទេសកម្ពុជា គឺក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវចេញសេចក្តីប្រកាសអំពីការបញ្ឈប់ជា បន្ទាន់នូវរាល់អាជីវកម្មដែលផ្ទុយនឹងច្បាប់នេះ។

ប្រទេសកម្ពុជា ជាប្រទេសមួយដែលអនុវត្តន៍ភាពមិនប្រតិសកម្មនៃច្បាប់ ដែលជាហេតុឱ្យច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មិនមានអានុភាពប្រតិសកម្មឡើយ មានន័យថារាល់អំពើទាំងឡាយដែលជាបទល្មើសរំលោភសិទ្ធិអ្នកនិពន្ធ ហើយបានប្រព្រឹត្តមុនពេលច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានចូលជាធរមាន គឺជនរងគ្រោះ ឬអ្នកសិទ្ធិ ឬម្ចាស់កម្មសិទ្ធិមិនអាចធ្វើការចោទប្រកាន់ ឬធ្វើពាក្យបណ្តឹង ឬផ្តន្ទាទោសតាមច្បាប់ទើបតែចូលជាធរមាននេះឡើយ។ ដូចនេះ ប្រទេសកម្ពុជា ទើបតែមានច្បាប់ដែលធ្វើការការពារសិទ្ធិអ្នកនិពន្ធបានគ្រប់គ្រាន់នៅក្នុងឆ្នាំ២០០៣ ប៉ុណ្ណោះ ដែលកាន់តែរឹតបន្តឹងឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសនីតិរដ្ឋ។

ជារួមមក ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល គឺជាច្បាប់ដែលមានអានុភាពទូទាំងប្រទេសកម្ពុជា ចាប់តាំងពីពេលដែលច្បាប់នេះបានចូលជាធរមាន និងមិនមានអានុភាពប្រតិសកម្មឡើយ។ ដោយសារតែព្រះរាជាណាចក្រកម្ពុជា ក៏ជាភាគីនៃសន្ធិសញ្ញាអន្តរជាតិផ្សេងៗដែលមានការពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធផងដែរ ទើបអាចមានសំនួរសួរថាតើច្បាប់អន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធមានអានុភាពបែបណា ចំពោះច្បាប់ព្រះរាជាណាចក្រកម្ពុជា ?

### ១.២. ឥទ្ធិពលច្បាប់អន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជា ក៏ជាភាគីមួយនៃសន្ធិសញ្ញាអន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងសិទ្ធិអ្នកនិពន្ធដែរ មានដូចជា អនុសញ្ញាទីក្រុង Rome ( Rome Convention) ដែលការពារទៅលើសិទ្ធិប្រហាក់ប្រហែល កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិបញ្ញា ( Agreement on Trade-Related Aspect of Intellectual Property Rights ) និង ( TRIPs Agreement )ជាដើម។

ចំពោះអនុសញ្ញាទីក្រុង Berne ( Berne Convention ) ដែលស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈ ក៏ប្រទេសកម្ពុជាមានកាតព្វកិច្ចអនុវត្តន៍ចាប់ពី មាត្រា ១ ដល់មាត្រា ២១ ដែរ ដោយសារតែប្រទេសកម្ពុជាជាភាគីនៃកិច្ចព្រមព្រៀង TRIPs ហើយបទបញ្ញត្តិក្នុងកិច្ចព្រមព្រៀងនេះតម្រូវឱ្យអនុវត្តន៍ ទោះបីជាប្រទេសកម្ពុជាមិនមែន ជាភាគីនៃអនុសញ្ញាទីក្រុង Berne ក៏ដោយ។

អនុលោមតាមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺបានបញ្ញត្តិយ៉ាងច្បាស់ថា បទប្បញ្ញត្តិទាំងឡាយនៃសិទ្ធិសញ្ញាអន្តរជាតិ ទាក់ទងនឹងច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលព្រះរាជាណាចក្រកម្ពុជា ជាភាគីត្រូវយកមកអនុវត្តន៍ជាមួយនឹងច្បាប់នេះបាន។ ក្នុងករណីមានទំនាស់ជាមួយនឹងបទបញ្ញត្តិទាំងឡាយនៃច្បាប់នេះ គឺបទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិទាំងនោះត្រូវចាត់ទុកជាបញ្ញាត្តិគោល។[៥៥] តាមមាត្រានេះបានបង្ហាញឱ្យឃើញចំណុចពីរយ៉ាងសំខាន់គឺទី១ សន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជា ជាភាគីគឺត្រូវយកមកអនុវត្តន៍ក្នុងបញ្ហាពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធ និងទី២ នៅពេលដែលមានលក្ខណៈផ្ទុយគ្នារវាងបទប្បបញ្ញត្តិច្បាប់ជាតិ ប្រសិនបើនិយាយឱ្យងាយយល់គឺសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធ មានអានុភាពលុបលើច្បាប់ជាតិ ពោលគឺសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធប្រទេសកម្ពុជាជាភាគី គឺមានឋានានុក្រមខ្ពស់ជាងច្បាប់ជាតិ។

ដូចនេះ តាមការបកស្រាយបានបញ្ជាក់ឱ្យឃើញថាឥទ្ធិពលនៃច្បាប់អន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធ មានឥទ្ធិពលទៅលើច្បាប់ជាតិដោយសន្ធិសញ្ញាអន្តរជាតិ ( ពាក់ព័ន្ធសិទ្ធិអ្នកនិពន្ធ ) មានឋានានុក្រមខ្ពស់ជាងច្បាប់ជាតិ។

### ២. ការមើលរំលងនៃការអនុវត្តរបស់បុគ្គល

ការមើលរំលងនៃការអនុវត្តរបស់បុគ្គលត្រូវបានសម្គាល់ទៅលើ ការយកចិត្តទុកដាក់របស់អ្នកនិពន្ធផ្ទាល់ទៅលើស្នាដៃរបស់ខ្លួនបានបង្កើតឡើង នៅពេលដែលជួបបញ្ហាការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធលើស្នាដៃរបស់គាត់។ ម្ចាស់សិទ្ធិ ឬម្ចាស់ស្នាដៃ គឺជាអ្នកចេញមុខប្ដឹងដោយផ្ទាល់ទៅតុលាការ ដោយផ្អែកលើច្បាប់ខាងលើ បើរកឃើញថា ស្នាដៃរបស់គាត់ត្រូវគេរំលោភ។ កន្លងមកអ្នកនិពន្ធដើរតួរជាអ្នកបង្កើតស្នាដៃផង និងជាអ្នកបង្ក្រាបផង។ ប៉ុន្តែ នៅក្នុងបរិបទសង្គមខ្មែរភាគច្រើន ម្ចាស់ស្នាដៃ ឬអ្នកនិពន្ធផ្ទាល់ យល់ឃើញថាការអនុវត្តសិទ្ធិនេះ ហាក់នៅមានកម្រិតស្រប ពេលម្ចាស់ស្នាដៃលើកឡើងថា កម្ពុជាគួរជំរុញដំណើរការនៃការអនុវត្តច្បាប់នេះ ឱ្យកាន់តែមានភាពឆាប់រហ័សជាងនេះ។ ដោយសារតែហេតុផលបែបនេះ នាំឱ្យអ្នកនិពន្ធមួយចំនួននៅក្នុងសង្គមខ្មែរព្រងើយកន្តើយទៅនឹងទិដ្ឋភាពជាក់ស្តែង ដែលការលួចចម្លងសព្វថ្ងៃកាន់តែមានឥទ្ធិពលខ្លាំងជាងមុន ព្រោះការរីករាលដាលនៃការលួចចម្លង បើសិនជាអ្នកនិពន្ធយកចិត្តទុកដាក់រាល់គ្រប់សកម្មភាពរំលោភបំពានសិទ្ធិអ្នកនិពន្ធ នោះព្យសនកម្មនឹងមានជាបន្តបន្ទាប់ ដែលអ្នកនិពន្ធគិតថាជាការខាតបង់និងខ្ជះខ្ជាយធនធានទ្រព្យសម្បត្តិរបស់ភាគីទាំងសងខាង។

[៥៥] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៦៧

**កថាខណ្ឌទី៣៖ វិធានការការពារសិទ្ធិអ្នកនិពន្ធ**

ជាគោលការណ៍ ម្ចាស់សិទ្ធិ មានសិទ្ធិរកដំណោះស្រាយតាមប្រព័ន្ធតុលាការ តាមរយៈការដាក់ពាក្យបណ្ដឹងអំពីអំពើរំលោភសិទ្ធិនេះ។ ប៉ុន្តែក្នុងវិស័យកម្មសិទ្ធិបញ្ញា ភាគីដើមចោទអាចបើកឱ្យមានឱកាសចរចាលើការបញ្ឈប់អំពើរំលោភរំលោភ តាមរយៈការជូនដំណឹងហៅថា "លិខិតព្រមាន" ទៅអ្នករំលោភសិទ្ធិ និង/ឬទាមទារសំណងព្យសនកម្មទទួលរងដោយអំពើល្មើសនោះ។

**ក. វិធានការជូនដំណឹង**

វិធានការនេះ អាចត្រូវបានចាត់ទុកថាជាវិធានការទន់ភ្លន់របស់ម្ចាស់សិទ្ធិ នៅក្នុងការជូនដំណឹងដល់អ្នករំលោភសិទ្ធិបញ្ឈប់អំពើរំលោភនេះ និងទាមទារនូវសំណងសមរម្យ។ តាមរយៈវិធានការនេះ ម្ចាស់សិទ្ធិអាចធ្វើជាលិខិតព្រមាន ឬជូនដំណឹងអំពីការរំលោភសិទ្ធិ អ្នកនិពន្ធរបស់គាត់ទៅតតីយជន (រំលោភបំពាន) ឱ្យធ្វើការបញ្ឈប់នូវអំពើរំលោភបំពាននោះ។ វិធានការនេះ គ្រាន់តែជាការរំលឹកដាស់តឿនទៅដល់ជនរំលោភបំពាន អំពីអំពើរំលោភសិទ្ធិរបស់ម្ចាស់សិទ្ធិ និងចរចាក្នុងការបញ្ឈប់អំពើរំលោភសិទ្ធិអ្នកនិពន្ធតែប៉ុណ្ណោះ។ វិធានការណ៍ស្របបន្តបន្ទាប់មកទៀតនឹងត្រូវបានអនុវត្តន៍ដោយម្ចាស់សិទ្ធិ ប្រសិនបើមានភស្តុតាងច្បាស់លាស់បញ្ជាក់ថាអ្នករំលោភសិទ្ធិនោះពុំបានបញ្ឈប់អំពើរំលោភបំពានសិទ្ធិអ្នកនិពន្ធនោះទេ។

**ខ. វិធានការបណ្ដោះអាសន្ន**

វិធានការបណ្ដោះអាសន្ន មានគោលដៅទប់ស្កាត់អំពើរំលោភបំពានដែលកំពុងតែកើតមាន និងរក្សាភស្តុតាងដែលទាក់ទងទៅនឹងបទល្មើសរំលោភសិទ្ធិអ្នកនិពន្ធ។ នីតិវិធីវិធានការបណ្ដោះអាសន្ននេះ ពុំត្រូវបានចែងក្នុងច្បាប់សិទ្ធិអ្នកនិពន្ធឡើយ មានន័យថា វិធានការបណ្ដោះអាសន្នត្រូវអនុវត្តន៍តាមក្រមនីតិវិធីរដ្ឋប្បវេណីទាំងស្រុង។ ក្នុងករណីនេះ តុលាការអាចចេញវិធានការបណ្ដោះអាសន្ន ដើម្បីទប់ស្កាត់អំពើរំលោភសិទ្ធិ និងរឹបអូសនូវផលិតផលដែលផលិតចេញពីការចម្លងខុសច្បាប់នូវស្នាដៃដើម្បីរក្សាទុកជាវត្ថុតាង។[៥៥] ការរឹបអូសវត្ថុតាងនេះត្រូវធ្វើឡើងតាមរយៈដីការក្សាការពាររបស់តុលាការមានសមត្ថកិច្ច។

នៅក្នុងវិស័យកម្មសិទ្ធិបញ្ញា ការរឹបអូសវត្ថុតាង ដែលផលិតចេញពីការរំលោភសិទ្ធិអ្នកនិពន្ធនេះ អាចត្រូវបានធ្វើឡើងតាមរយៈការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថាម្ចាស់សិទ្ធិ នឹងមិនអាចអនុវត្តន៍សិទ្ធិ ឬនឹងមានការលំបាកនៅក្នុងការអនុវត្តសិទ្ធិ ដោយសារតែមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។[៥៦] ដើមបណ្ដឹងត្រូវ

[៥៥] ច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៥៩ (វាក្យខ័ណ្ឌទី១)
[៥៦] ក្រមនីតិវិធីរដ្ឋប្បវេណី, មាត្រា ៥៣១ (ចំណុច ខ)

បញ្ជាក់ភស្តុតាងអំពីអត្ថិភាពនៃសិទ្ធិលើស្លាកដៃនៅក្នុងពាក្យបណ្តឹងរបស់ខ្លួន។ នៅក្នុងនីតិវិធីនេះ អ្នកប្រព្រឹត្តិបទល្មើសអាចត្រូវបានហាមឃាត់នូវការនាំចូល ការនាំចេញ ការចែកចាយ ការលក់ផលិតនៃវិវាទ និងការប្រើប្រាស់ឧបករណ៍ទាំងឡាយ ដែលពាក់ព័ន្ធនឹងកម្មវត្ថុនៃវិវាទនោះ។ បន្ទាប់ពីការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា ឬអាជ្ញាធរមានសមត្ថកិច្ច ប្រសិនបើបទល្មើសពុំត្រូវបានរកឃើញ ឬពុំមានភស្តុតាងច្បាស់លាស់ ដែលអាចចោទប្រកាន់បានព្រះរាជអាជ្ញានឹងលើកលែងការចោទប្រកាន់ និងដោះលែងវត្ថុតាងដែលត្រូវបានរឹបអូសទាំងនោះ ឱ្យទៅជនសង្ស័យវិញ។ ក្នុងករណីនេះ ដើមបណ្តឹងត្រូវទទួលខុសត្រូវលើការខូចខាតរបស់ជនសង្ស័យដែលកើតមានឡើងតាមរយៈបណ្តឹងរបស់ដើមបណ្តឹងនេះ។[៩៧]

**គ. វិធានការតាមមាត់ច្រកព្រំដែន**

វិធានការតាមមាត់ច្រកព្រំដែនទាក់ទងនឹងសមត្ថកិច្ចគយ និងតុលាការ។ ច្បាប់សិទ្ធិអ្នកនិពន្ធពុំកំណត់លម្អិត អំពីវិធានការតាមមាត់ច្រកព្រំដែនទេ ដោយបានចែកយោងទៅលើការអនុវត្តបទប្បញ្ញត្តិស្តីពីវិធានការតាមមាត់ច្រកព្រំដែនដែលមានចែងនៅក្នុងច្បាប់ម៉ាក។[៩៨] ម្ចាស់សិទ្ធិអាចស្នើសុំជាលាយល័ក្ខអក្សរទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីទប់ស្កាត់ការនាំចេញនាំចូលនៃទំនិញដែលម្ចាស់សិទ្ធិអះអាងថាជាទំនិញក្លែងក្លាយ ឬផលិតផលដែលរំលោភលើសិទ្ធិរបស់គាត់។ ក្នុងករណីនេះ រដ្ឋបាលគយត្រូវជូនដំណឹងជាបន្ទាន់ដល់តុលាការមានសមត្ថកិច្ច ឬអាជ្ញាធរមានសមត្ថកិច្ចដើមបណ្តឹង ឬម្ចាស់ទំនិញអំពីការឃាត់ទុកនេះ។

**ឃ. ទណ្ឌកម្មនៃអំពើរំលោភសិទ្ធិអ្នកនិពន្ធ**

ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលបានអនុម័តកាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ គឺបានចែងកំណត់អំពីសំណងផ្នែករដ្ឋប្បវេណី ទោសព្រហ្មទណ្ឌ វិធានការរដ្ឋបាល ក្នុងករណីមានការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។

**១. សំណងរដ្ឋប្បវេណី**

យោងតាមមាត្រា៥៧ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ គឺអ្នកនិពន្ធដែលត្រូវបានរំលោភបំពានសិទ្ធិរបស់គាត់អាចប្តឹងទៅតុលាការ ដើម្បីបញ្ឈប់ការរំលោភបំពានសិទ្ធិរបស់ខ្លួន ក្នុងបំណងទប់ស្កាត់នូវការខូចខាត។ ក្នុងករណីអំពើរំលោភបំពាននោះបម្រុងនឹងកើតមានឡើងម្ចាស់សិទ្ធិអាចស្នើសុំឱ្យមានឃាត់ចុងចោទពីការរំលោភបំពានសិទ្ធិរបស់គាត់។ ក្រៅពីការទូទាត់សងសំណង ម្ចាស់សិទ្ធិអាចពិនិត្យពីផលប្រយោជន៍ដែលបានមកពីអំពើល្មើសនោះ ព្រមទាំង

---

[៩៧] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៦៣ (វាក្យខណ្ឌទី៣)

[៩៨] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៦៣ (វាក្យខណ្ឌទី៤)

រឹបអូសយកនូវឧបករណ៍ និងសម្ភារៈក្នុងអំពើនោះ។

ការទាមទារសំណងព្យសនកម្ម ដែលកើតចេញមកពីអំពើរំលោភបំពានសិទ្ធិអ្នកនិពន្ធ ជាសិទ្ធិរបស់ម្ចាស់សិទ្ធិអ្នកនិពន្ធ ដែលអាចដាក់ពាក្យបណ្តឹងទៅតុលាការ។ បែបបទ ឬរបៀបគិតសំណងនោះពុំត្រូវបានកំណត់ច្បាស់លាស់ឡើយ។ ប៉ុន្តែ ច្បាប់បានព្យាយាមកំណត់ចំនុចមួយចំនួនដែលម្ចាស់សិទ្ធិអាចទាមទារឱ្យជនល្មើសសងមកខ្លួនវិញបាន ដូចជាសំណងជម្ងឺចិត្ត សងការខូចខាត និងប្រគល់មកវិញនូវវត្ថុតាង មានឧបករណ៍ ឬសម្ភារៈ ដែលជាប់ពាក់ព័ន្ធ ព្រមទាំងប្រគល់ប្រាក់ចំណេញដែលកើតចេញមកពីអំពើរំលោភសិទ្ធិនោះ។

**២. ទោសព្រហ្មទណ្ឌ**

នៅក្នុងសិទ្ធិអ្នកនិពន្ធ ការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធដូចមានកំណត់ក្នុងច្បាប់នេះ តាមរយៈការផលិត ការផលិតឡើងវិញ ឬការសម្តែង ឬការផ្សព្វផ្សាយនូវស្នាដៃ ដោយប្រើមធ្យោបាយបែបណាក៏ដោយ គឺជាបទល្មើសដែលត្រូវទទួលទោសតាមច្បាប់។ ទណ្ឌកម្ម ចំពោះបទល្មើសរំលោភសិទ្ធិអ្នកនិពន្ធមានចែងដូចខាងក្រោមនេះ៖[៩៩]

- បទល្មើសនៃការលិត ឬការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យ ជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល និង/ឬត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ១២ (ដប់ពីរ) ខែ។ ក្នុងករណីមិនរាងចាល ត្រូវទទួលស្ថានទម្ងន់ទោសទ្វេរដង។
- បទល្មើសនាំចូល ឬនាំចេញផលិតផលរំលោភបំពានសិទ្ធិអ្នកនិពន្ធ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល និង/ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ១២ (ដប់ពីរ) ខែ។ ក្នុងករណីមិនរាងចាល ត្រូវទទួលស្ថានទម្ងន់ទោសទ្វេរដង។
- បទល្មើសនៃការសម្តែង ឬការផ្សព្វផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន) រៀល ដល់ ៥.០០០.០០០ (ប្រាំលាន) រៀល និង/ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ៣ (បី) ខែ។ ក្នុងករណីដែលបទល្មើសត្រូវបានប្រព្រឹត្តច្រើនជាង ការផ្តន្ទាទោសត្រូវគុណានឹងចំនួនដងនៃការប្រព្រឹត្ត។ ក្នុងករណីដែលមិនរាងចាលត្រូវទទួលស្ថានទម្ងន់ទោសទ្វេរដង។

[៩៩] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, មាត្រា ៦៤

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ *"ការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញានៃម៉ាក និងសិទ្ធិអ្នកនិពន្ធនៅកម្ពុជា"* រួចមក អាចបញ្ជាក់ឱ្យឃើញថាប្រធានបទមួយនេះបានបង្ហាញពីតួនាទីសំខាន់ អត្ថប្រយោជន៍ និងបានឆ្លុះបញ្ចាំងមកវិញនូវផលប៉ះពាល់ដែលមានទៅលើសង្គមជាតិកម្ពុជាទាំងមូលតាមរយៈកិច្ចអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញាកម្ពុជា។

នៅក្នុងវិស័យម៉ាកទៅតាមប្រភេទ និងគោលការណ៍នៃការការពារម៉ាក ផលប្រយោជន៍ដែលទទួលបានតាមរយៈវិស័យមួយនេះ បានបង្ហាញឱ្យឃើញពីការជំរុញនូវការបង្កើតស្នាដៃថ្មីៗ ដែលបានទាក់ទាញអ្នកវិនិយោគឱ្យមកវិនិយោគក្នុងប្រទេសកម្ពុជានៅក្នុងករណីដ៏សមស្រប។ ចំពោះពាណិជ្ជកម្ម ការការពារម៉ាកនៅក្នុងកិច្ចដ៏ស្របច្បាប់មួយនាំឱ្យរោងចក្រសហគ្រាស ម្ចាស់ម៉ាក ឬម្ចាស់សិទ្ធិ និងអ្នកប្រើប្រាស់ទទួលបាននូវគុណតម្លៃប្រើប្រាស់របស់ស្នាដៃនោះ។ ដោយឡែក ផលប៉ះពាល់នៃការរំលោភបំពានម៉ាកដែលហុចឱ្យនៅក្នុងរូបភាពទាំងមូល គឺជាការខាតបង់មួយរបស់សហគ្រាសផលិតនៅលើទីផ្សារ កំសោយទំនាក់ទំនងពាណិជ្ជកម្មរបស់អ្នកវិនិយោគ នៅពេលម៉ាកមិនមានការការពារគ្រប់គ្រាន់ ជាពិសេសម្ចាស់សិទ្ធិ ឬម្ចាស់ម៉ាកជាអ្នកប្រឈមមុខផ្ទាល់ទៅនឹងការរំលោភបំពានសិទ្ធិតាមរយៈទិដ្ឋភាពសង្គមជាក់ស្តែង។ យ៉ាងណាក្តី វាក៏ជាការប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈផងដែរ ដូចជា ផលិតផលឱសថដែលប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋក្នុងសង្គមទាំងមូល។ បន្ថែមពីនេះទៅទៀត ច្បាប់នេះបានប្បញ្ញត្តិពីវិធានការសម្រាប់ទប់ស្កាត់ និងប្រឆាំងទៅនឹងអំពើរំលោភបំពានម៉ាក និងដំណោះស្រាយនៅពេលមានវិវាទនៃសិទ្ធិលើម៉ាកដែលកើតមានឡើង។

នៅក្នុងវិស័យសិទ្ធិអ្នកនិពន្ធ នៅក្នុងន័យវិស័យវប្បធម៌ ជាថាមពលជំរុញការលើកទឹកចិត្តដល់ការបង្កើតនូវស្នាដៃវប្បធម៌ក្នុងគោលបំណងដើម្បីអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ជាតិ សម្រាប់ការអប់រំ និងផ្ទេរចំណេះដឹងវប្បធម៌ដល់ខ្មែរជំនាន់ក្រោយ។ លើសពីនេះ ការតម្កល់ និងការចុះបញ្ជីស្នាដៃរបស់អ្នកនិពន្ធនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក៏បានហុចផលប្រយោជន៍ឱ្យសង្គមជាតិផងដែរ ព្រោះស្នាដៃដែលចុះបញ្ជីជាស្នាដៃដើមដែលបង្កើតឡើងនៅក្នុងប្រទេស។ មិនតែប៉ុណ្ណោះ ទាំងនេះជាការកសាងធនធានមនុស្សដែលពោរពេញទៅដោយគំនិត និងការយល់ដឹងខ្ពស់ក្នុងសិទ្ធិសិល្បៈនៃអក្សរសិល្ប៍ និងអក្សរសាស្ត្រ។ ផលិតផលវប្បធម៌ជាតិមានច្រើននៅលើទីផ្សារជាការផ្សព្វផ្សាយអត្តសញ្ញាណជាតិ ម្យ៉ាងវិញទៀត ផលប៉ះពាល់ពីការរំលោភបំពានសិទ្ធិអ្នកនិពន្ធ គឺការជះឥទ្ធិពលនៃការប៉ះពាល់ផលប្រយោជន៍សាធារណៈ សំដៅទៅលើធាតុនៃសង្គម តួយ៉ាងគឺ រដ្ឋ និងវប្បធម៌។

# អនុសាសន៍

បន្ទាប់ពីធ្វើការស្រាវជ្រាវ លើប្រធានបទ *"ការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញានៃម៉ាក និងសិទ្ធិអ្នកនិពន្ធនៅកម្ពុជា"* រួចមក ការផ្តល់អនុសាសន៍មួយចំនួនជាចក្ខុវិស័យ និងយុទ្ធសាស្ត្រទៅថ្ងៃអនាគតដែលជាលទ្ធផលនៃការស្រាវជ្រាវមួយនេះ។

យ៉ាងណាក៏ដោយ ទាំងកម្ពុជានិងក្នុងប្រទេសនៅលើពិភពលោកមិនមានប្រទេសណា អនុវត្តកម្មសិទ្ធិបញ្ញាបានមួយរយភាគរយពេញលេញនោះទេ។ យោងតាមការបកស្រាយទៅលើហេតុផល និងទិដ្ឋភាពជាក់ស្តែងនៃផលប្រយោជន៍ និងផលវិបាកតាមរយៈបញ្ហាប្រឈមដោយការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញា មិនមែនមានន័យថាកម្ពុជាត្រូវតែលុបបំបាត់ចោល ឬក៏ទប់ស្កាត់នូវឬសគល់បញ្ហាដែលកំពុងកើតមានឡើងទាំងស្រុងនោះទេ ដោយហេតុថា ប្រទេសកម្ពុជានៅដើរតួរជាប្រទេសកំពុងអភិវឌ្ឍន៍នៅឡើយ។ ដូចនេះ៖

- បើសិនជាច្បាប់ដែលការពារកម្មសិទ្ធិបញ្ញាត្រូវបានរឹតបន្តឹងខ្លាំងពេកនោះ ប្រជាពលរដ្ឋនឹងអាចប្រឈមនឹងភាពកង្វះការងារ ព្រោះកត្តាជីវភាពរបស់ប្រជាពលរដ្ឋមួយចំនួននៅមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការចំណាយទៅលើផលិតផល ដែលមានតម្លៃខ្ពស់នៅឡើយ។
- ប្រសិនបើមានការអនុវត្តលើកម្មសិទ្ធិបញ្ញាមួយរយភាគរយពេញលេញ វាអាចនឹងធ្វើឱ្យមានការរាំងស្ទះរវាងអ្នកប្រើប្រាស់ផ្ទាល់ និងផលប្រយោជន៍ដែលម្ចាស់សិទ្ធិបានរំពឹងពីស្នាដៃដែលខ្លួនបានបង្កើត។
- ក៏ប៉ុន្តែការរាំងស្ទះនេះ គឺជាការបែងចែង និងអាស្រ័យទៅលើមុខងារនៃផលិតផល ដោយហេតុថា ផលិតផល ឬស្នាដៃដែលបង្កើតឡើង ក្នុងគោលបំណងសម្រាប់តែប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃគួរតែមានភាពអនុគ្រោះទៅលើអ្នកប្រើប្រាស់ និងម្ចាស់សិទ្ធិ លើកលែងតែផលិតផលដែលប្រើសម្រាប់ទ្រទ្រង់សុខភាព និងអាចប៉ះពាល់ដល់សុខភាពរបស់មនុស្សដែលជាអ្នកប្រើប្រាស់ផ្ទាល់ បើមិនមានការរឹតបន្តឹង នៅពេលនាំចេញនាំចូលនៃលំហូរផលិតផលនោះ។
- ជាទូទៅ លទ្ធភាពរបស់ប្រជាពលរដ្ឋកម្ពុជាមួយចំនួននៅក្នុងការចំណាយលើផលិតផលដែលមានតម្លៃខ្ពស់ គឺមិនអាចធ្វើបាននៅក្នុងកម្រិតមួយរយភាគរយនោះទេ ព្រោះកម្ពុជានៅជាប្រទេសកំពុងអភិវឌ្ឍន៍នៅឡើយ។
- អាស្រ័យហេតុផលនេះហើយ កត្តាជីវភាពរបស់ប្រជាពលរដ្ឋខ្មែរទូទៅនៅមានកម្រិតដែលត្រូវយកចិត្តទុកដាក់ជាមុន ក្នុងការទទួលយកមកនូវស្នាដៃផលិតផលដើមក្នុងតម្លៃជាក់លាក់ណាមួយ ដើម្បីទាញផលប្រយោជន៍ពីការប្រើប្រាស់ផលិតផលនោះក្នុងលក្ខខណ្ឌសមស្រប។

- ក៏ប៉ុន្តែឆ្លើយតបទៅនឹងទិដ្ឋភាពជាក់ស្តែងបែបនេះ នៅក្នុងសង្គមកម្ពុជាគួរតែពង្រឹងនូវវិសាលភាពនៃការប្រើប្រាស់វិញ ដោយការការពារអ្នកប្រើប្រាស់ផ្ទាល់ពីហានិភ័យដែលអាចកើតមានឡើង។
- ម្យ៉ាងវិញទៀត គប្បីការពារម្ចាស់សិទ្ធិនៃស្នាដៃដើម គួរយ៉ាងសំដៅដល់ស្នាដៃរបស់អ្នកនិពន្ធដោយការលើកទឹកចិត្តក្នុងការផលិតក្នុងការជម្រុញឱ្យមានភាពចម្រើនខាងវប្បធម៌ជាដើម។

# ឯកសារយោង


## ក. អនុសញ្ញាអន្តរជាតិ

– កិច្ចព្រមព្រៀងស្តីពី ទិដ្ឋភាពពាណិជ្ជកម្មពាក់ព័ន្ធសិទ្ធិកម្មសិទ្ធិបញ្ញា (Trade-Related Aspects of Intellectual Property Rights – TRIPs Agreement)។

– អនុសញ្ញាទីក្រុងប៊ែន ឆ្នាំ១៨៨៦ ស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈ (Berne Convention for the Protection of Literary and Artistic Works 1886)។

## ខ. លិខិតបទដ្ឋានគតិយុត្ត

– ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

– ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

– ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ប្រកាសឱ្យប្រើដោយព្រះរាជ ក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២។

– ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣។

## គ. ប្រកាស

– ប្រកាសលេខ ៦០ ប្រ.ក វវស ស្តីពី ការបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាពដែលរំលោភបំពានលើសិទ្ធិ អ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៣។

– ប្រកាសលេខ ២២០ ប្រ.ក វវស ស្តីពី ការគ្រប់គ្រងអាជីវកម្ម និងសេវាកម្មលក់ ជួល ផលិតផល ភាពយន្ត និងវីដេអូ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១។

## ឃ. សៀវភៅ

– កាន់ សុទ្ធប៉ូលីន. *នីតិកម្មសិទ្ធិបញ្ញា៖ សិទ្ធិអ្នកនិពន្ធ / ម៉ាក / ប្រកាសនីយបត្រតក្កកម្ម.* ភ្នំពេញ, ២០១៣។

– ចាប សុថារិទ្ធ. *កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក.* ២០០៦។

– តាម៉ុតស៊ូ ហូហ្ស៊ុយមី. សៀវភៅសិទ្ធិអ្នកនិពន្ធអ្នកស្រុកអាស៊ី. បកប្រែដោយ ជៀង យ៉ារិន, គុបតែង លម្អដោយ តារ៉ូ ហ្គោមី. ឧបត្ថម្ភការបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលវប្បធម៌អាស៊ី

ប៉ាស៊ីហ្វិកនៃអង្គការ យូណេស្កូ (ACCU) បោះពុម្ពផ្សាយដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ២០០៩។
- នី វិចិត្រ. *នីតិកម្មសិទ្ធិបញ្ញាកម្ពុជា*. ២០១៣។
- លឹម យូសួ. *សេចក្ដីផ្ដើមនៃការសិក្សានីតិកម្មសិទ្ធិបញ្ញា*. ២០១៣។
- ឥន យឿន និងអ៊ុក វណ្ណារ័ត្ន. *នីតិកម្មសិទ្ធិបញ្ញា*. ២០១៣។

**ខ. ទិបសាយ** Website

- www.khmertimeskh.com/494663/protecting-intellectual-property-key-to-innovation-minister/
- kampucheathmey.com/2016/archives/ 824522
- kohsantepheapdaily.com.kh/article/ 599420.html
- www.interior.gov.kh/news/detail/615
- www.postkhmer.com/សេដ្ឋកិច្ច/ផលិតផលក្លែងក្លាយរារាំងការវិនិយោគ
- www.rfa.org/khmer/news/law/Intellectual-Property-and-ItsImportance03222017040733.html
- vayofm.com/news/detail/94120-784343379.html
- thmeythmey.com/?page= detail&id=76003
- thmeythmey.com/?page=detail&id= 59502
- khmer.voanews.com/a/cambodia-supports-asean-intellectual-propertyrights/1498270.html
- www.customs.gov.kh/ipr-seminar/
- www.rfa.org/khmer/news/social-economy/cam-writers-should-stop-copying-foreign songs05 152015044747.html
- norkorthom.com/2019/07/ទឹកក្រូចម៉ាកថ្មី-ច្រកផ្ទ/?fbclid=IwAR2Dxr5I3BqyJG0r5R632kVCf l8Q7Y1svD7KIUhTi4jVlOeJnvi5sH3LTsg
- www.cambodiaip.gov.kh/TemplateTwo.aspx?parentId=45&menuid=299&childMasterMenuId=299
- khmer.voanews.com/a/more-people-writing-still-failing-to-earn-income-as-cambodia copyright-not-protected/3104056.html
- www.rfa.org/khmer/news/culture/Initiative-in-Promoting-Intellectual-Property-Rights-In-Cam-12022016224935.html

- www.cen.com.kh/archives/49402.html/national/
- archive.monoroom.info/news/post/953

# ឧបសម្ព័ន្ធ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងធានាការគោរពសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងការពារនូវផលិតផលវប្បធម៌ជាស្នាដៃអ្នកនិពន្ធ អ្នកសម្តែង ផលិតករ ហ្វូណូក្រាមនិងអង្គភាពទូរផ្សាយ សំដៅធានាការធ្វើអាជីវកម្មមួយត្រឹមត្រូវ ស្របច្បាប់លើផលិតផលវប្បធម៌ទាំងនោះ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យវប្បធម៌ ។

**មាត្រា ២.-**

ក្នុងន័យនៃច្បាប់នេះ ពាក្យមួយចំនួនដូចខាងក្រោមមានអត្ថន័យដូចតទៅ :

**ក-ស្នាដៃ** ជាផលិតផលខាងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រី កើតចេញពីការច្នៃប្រឌិត បង្កើតឡើងដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនា ។

**ខ-អ្នកនិពន្ធ** ជាជនដែលបង្កើតបានស្នាដៃ ។

**គ-ការសម្តែង** ជាការបញ្ចោញស្នាដៃលើឆាកដូចជារាំ ប្រគំតន្ត្រី ច្រៀង ឬបង្ហាញតាមមធ្យោបាយនិងវិធីផ្សេងៗទៀតនូវស្នាដៃសិល្បៈប្រពៃណី ទំនៀមទម្លាប់ អក្សរសាស្ត្រ ការអប់រំ ឬវិទ្យាសាស្ត្រ ។

**ឃ-ការសូត្រ** ជាការបញ្ចោញសម្លេងដោយការនិយាយ ការអាននិងការស្មូតនូវស្នាដៃផ្សេងៗ ។

**ង-អ្នកសម្តែង** ជាសិល្បករ អ្នករបាំ តន្ត្រីករ អ្នកចម្រៀង ឬជនដែលធ្វើការសម្តែង ។

**ច-ប្រព័ន្ធទិន្នន័យ** ជាសំណុំព័ត៌មាន អត្ថបទ លេខ ឱីយ៉ាក្រាម ដែលបង្កើតនិងស្រាវជ្រាវដោយប្រព័ន្ធកុំព្យូទ័រ ។

**ឆ-ស្នាដៃសោតទស្សន៍** ជាស្នាដៃបង្កើតឡើងដោយមានរូបភាពតគ្នាជាឈុតៗភ្ជាប់គ្នា បង្កើតបានជាចលនាអាចឱ្យមើលឃើញបាន ទោះបីមានឬពុំមានបញ្ចូលសម្លេង ហើយបើមានបញ្ចូលសម្លេងគឺអាចស្តាប់ឮសូរសម្លេងបាន ។

**ជ-ទូរផ្សាយ** ជាការផ្សាយសម្លេង រូបភាព ឯកសារ ឬសារនានាគ្រប់ប្រ-

ភេទតាមវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាបឬផ្កាយរណប ។

**ឈ-ការផ្សព្វផ្សាយជាសាធារណៈ** ជាការផ្សាយតាមខ្សែ ឬគ្មានខ្សែក្រៅវង្វង់គ្រួសារនូវរូបភាព ឬសម្លេង ឬរូបភាពជាមួយសម្លេងនៃស្នាដៃណាមួយ ដែលអាចឱ្យសាធារណជនទទួលបាននៅទីកន្លែងដើម ឬទីកន្លែងដទៃទៀត ដោយមិនគិតថា ជននោះទទួលឬមិនទទួលនូវរូបភាព ឬសម្លេងនោះ ក្នុងពេលនិងទីកន្លែងជាមួយគ្នា ឬក្នុងពេលនិងទីកន្លែងខុសគ្នាតាមការជ្រើសរើសផ្ទាល់ខ្លួនរបស់គេ ។

**ញ-ហ្វូណូក្រាម** ជាវត្ថុដែលបានថតបញ្ចូលសម្លេងនៃការសម្តែង ឬសម្លេងផ្សេងៗទៀត ឬនិមិត្តសញ្ញានៃសម្លេង ក្រៅពីទម្រង់នៃការថតបញ្ចូលជាខ្សែភាពយន្ត ឬស្នាដៃសោតទស្សន៍ផ្សេងៗទៀត ។

**ដ-ផលិតករហ្វូណូក្រាម** ជាជនដែលផលិតហ្វូណូក្រាម ដូចមានចែងនៅក្នុងចំណុច ញ ។

**ឋ-កម្មវិធីកុំព្យូទ័រ** ជាសំណុំនៃសេចក្តីណែនាំដែលធ្វើឡើងតាមអក្សរ ឬលេខកូដ ឬគំនូសបំព្រួញ ឬតាមទម្រង់ណាមួយជាហេតុធ្វើឱ្យគេបំពេញបាន ឬទទួលបាននូវកិច្ចការ ឬលទ្ធផលពិសេសណាមួយតាមមធ្យោបាយកុំព្យូទ័រ ឬតាមវិធីសាស្ត្រអេឡិចត្រូនិច ដើម្បីបំពេញកិច្ចការព័ត៌មានបាន កាលណាកម្មវិធីនោះត្រូវបានបញ្ចូលក្នុងកុំព្យូទ័រ ។

**ឌ-ការផលិតឡើងវិញ** ជាការចម្លងទាំងស្រុង ឬភាគខ្លះនៃស្នាដៃ ឬហ្វូណូក្រាម បង្កើតជាផលិតផលចម្លងមួយច្បាប់ ឬច្រើនច្បាប់តាមមធ្យោបាយ ឬទម្រង់ណាមួយគិតបញ្ចូលទាំងស្នាដៃ ឬហ្វូណូក្រាមដែលរក្សាទុកជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នតាមទម្រង់អេឡិចត្រូនិច ។

**ឍ-អង្គភាពទូរផ្សាយ** គឺស្ថានីយវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប ឬផ្កាយរណប ។

**ណ-សិទ្ធិប្រហាក់ប្រហែល** ជាសិទ្ធិអ្នកសម្តែង សិទ្ធិផលិតករហ្វូណូក្រាម និងសិទ្ធិអង្គភាពទូរផ្សាយ ។

**មាត្រា ៣.–**

ស្នាដៃទាំងឡាយដែលត្រូវទទួលបានកិច្ចការពារពីច្បាប់នេះមានស្នាដៃអ្នកនិពន្ធ

ស្នាដៃអ្នកសម្តែង ហ្វូណូក្រាមនិងការផ្សាយតាមទូរផ្សាយ ។

**១-ស្នាដៃអ្នកនិពន្ធសំដៅ :**

**ក**-ស្នាដៃដែលបង្កើតឡើងដោយជនមានសញ្ជាតិខ្មែរ ឬជនដែលមានលំនៅក្នុងព្រះរាជាណាចក្រកម្ពុជារួមមាននីតិបុគ្គល ហើយត្រូវបានបង្កើតឡើងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ខ**-ស្នាដៃដែលបានបោះពុម្ពផ្សាយលើកដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬស្នាដៃដែលបានបោះពុម្ពផ្សាយលើកដំបូងនៅបរទេស ហើយដែលត្រូវបានយកមកបោះពុម្ពផ្សាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងអំឡុង ៣០(សាមសិប)ថ្ងៃ ។

**គ**-ស្នាដៃសោតទស្សន៍ដែលផលិតករមានទីស្នាក់ការ ឬមានទីលំនៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ឃ**-ស្នាដៃស្ថាបត្យកម្មដែលបានសាងសង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងស្នាដៃសិល្បៈផ្សេងៗទៀតដែលភ្ជាប់ទៅនឹងអាគារ ឬរចនាសម្ព័ន្ធផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ង**-ស្នាដៃដែលព្រះរាជាណាចក្រកម្ពុជាមានកាតព្វកិច្ចការពារក្រោមសន្ធិសញ្ញាអន្តរជាតិ ។

**២-ស្នាដៃអ្នកសម្តែងសំដៅ :**

**ក**-ស្នាដៃរបស់អ្នកសម្តែងដែលមានសញ្ជាតិខ្មែរ ។

**ខ**-ស្នាដៃរបស់អ្នកសម្តែងដែលពុំមានសញ្ជាតិខ្មែរ តែការសម្តែងនោះ :

- បានប្រព្រឹត្តឡើងនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬ
- បានថតបញ្ចូលជាហ្វូណូក្រាមដែលស្ថិតក្រោមកិច្ចការពារនៃច្បាប់នេះ ឬ
- ពុំទាន់បានថតបញ្ចូលជាហ្វូណូក្រាម ប៉ុន្តែបានផ្សព្វផ្សាយតាមទូរ-ផ្សាយដែលស្ថិតក្រោមកិច្ចការពារនៃច្បាប់នេះ ។

**៣-ហ្វូណូក្រាមសំដៅ :**

**ក**-ហ្វូណូក្រាមរបស់ផលិតករមានសញ្ជាតិខ្មែរ ។

**ខ**-ហ្វូណូក្រាម ដែលបានថតបញ្ចូលសូរសម្លេងជាលើកដំបូងនៅក្នុង

ព្រះរាជាណាចក្រកម្ពុជា ។

**គ**-ហ្វូណូក្រាម ដែលបានថតផ្សាយលើកដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**៤-ការផ្សាយតាមទូរផ្សាយសំដៅ :**

**ក**-ការផ្សាយនៃអង្គភាពទូរផ្សាយដែលមានទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ខ**-ការផ្សាយចេញពីឧបករណ៍ផ្សាយដែលមានទីតាំងនៅក្នុងព្រះរាជណាចក្រកម្ពុជា ។

បទប្បញ្ញត្តិនៃច្បាប់នេះក៏ត្រូវអនុវត្តផងដែរ ចំពោះអ្នកសម្តែង ផលិតករហ្វូណូក្រាមនិងអង្គភាពទូរផ្សាយដែលអាចទទួលនូវកិច្ចការពារតាមសន្ធិសញ្ញាអន្តរជាតិ ឬកិច្ចព្រមព្រៀងអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ។

## ជំពូកទី ២
## សិទ្ធិអ្នកនិពន្ធ
## ផ្នែកទី ១
## ស្នាដៃ

**មាត្រា ៤.–**

ត្រូវចាត់ទុកថាជាស្នាដៃដើមគឺស្នាដៃទាំងឡាយដែលបង្កើតឡើងតាមគំនិតប្រាជ្ញាផ្ទាល់របស់អ្នកនិពន្ធនៃស្នាដៃនោះ ។

**មាត្រា ៥.–**

ស្នាដៃមួយទោះបីពុំទាន់ចប់សព្វគ្រប់ក្តី ឬពុំទាន់បានផ្សព្វផ្សាយជាសាធារណៈក្តី ស្នាដៃនោះត្រូវចាត់ទុកថាបានបង្កើតឡើងដោយចំណេះដឹងពិតប្រាកដតែមួយគត់ពីគំនិតប្រាជ្ញាអ្នកនិពន្ធ ។

**មាត្រា ៦.–**

ស្នាដៃសហការជាស្នាដៃដែលមានរូបវន្តបុគ្គលច្រើននាក់ចូលរួមសហការដើម្បី

បង្កើតស្នាដៃនោះ ។

ស្នាដៃបន្តជាស្នាដៃបង្កើតឡើងផ្អែកតាមស្នាដៃដើម តាមរយៈការបកប្រែ ការយកលំនាំតាមឬការសម្រួល ។

ស្នាដៃសមូហភាពគឺជាស្នាដៃបង្កើតឡើងដោយរូបវន្តបុគ្គលច្រើននាក់ តាមគំនិតផ្តួចផ្តើមរបស់រូបវន្តបុគ្គលម្នាក់ដែលបានធ្វើការបោះពុម្ពផ្សាយក្រោមការដឹកនាំនិងក្នុងនាមរបស់បុគ្គលនោះ ។

**មាត្រា ៧.–**

ស្នាដៃទាំងឡាយ យោងតាមមាត្រា ៣ ដែលត្រូវទទួលបានការការពារក្រោមច្បាប់នេះមាន :

**ក**-សៀវភៅអានគ្រប់ប្រភេទ ឬឯកសារផ្សេងៗទៀតស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រនិងការអប់រំ ។

**ខ**-អត្ថបទបាឋកថា សង្កថា ធម្មទេសនា ការការពារខ្លួនដោយនិយាយ ឬដោយសរសេរនិងស្នាដៃផ្សេងៗទៀត ដែលមានប្រភេទដូចគ្នា ។

**គ**-ស្នាដៃនាដកម្ម ឬនាដកម្ម-តូរ្យតន្ត្រី ។

**ឃ**-ស្នាដៃរបាំសម័យ ឬយកលំនាំតាមស្នាដៃបុរាណ ឬប្រពៃណី ។

**ង**-ការសម្តែងសៀកនិងការសម្តែងកាយវិការ ។

**ច**-ការតែងបទភ្លេងដោយមាន ឬគ្មានទំនុកច្រៀង ។

**ឆ**-ស្នាដៃសោតទស្សន៍ ។

**ជ**-ស្នាដៃជាផ្ទាំងគំនូរ ផ្ទាំងចម្លាក់ រូបចម្លាក់ ឬស្នាដៃផ្សេងៗទៀតខាងសិល្បៈសូនរូបឬសិល្បៈអនុវត្ត ។

**ឈ**-ស្នាដៃថតរូបនិងស្នាដៃទាំងឡាយដែលសម្រេចបានដោយសារមានជំនួយបច្ចេកទេសដូចគ្នានឹងការថតរូប ។

**ញ**-ស្នាដៃស្ថាបត្យកម្ម ។

**ដ**-ផែនទី ប្លង់ គំនូសវាស ឬស្នាដៃស្តែងចេញជារូបដែលទាក់ទងនឹងភូមិសាស្ត្រ ឋានលេខា ឬវិទ្យាសាស្ត្រនានា ។

៦-កម្មវិធីកុំព្យូទ័រនិងគម្រោងឯកសារសមោធានដែលទាក់ទងទៅនឹងកម្ម-វិធីទាំងនោះ ។

៧-ផលិតផលផ្នែកសិប្បកម្ម តម្បាញ ឬម៉ូតសម្លៀកបំពាក់ផ្សេងៗ ។

**មាត្រា ៨.-**

ស្នាដៃបន្តដែលនៅក្នុងនោះមាន ការបកប្រែ ការយកលំនាំតាម ការសម្រួល ការកែច្នៃ ឬការកែលំអស្នាដៃផ្សេងទៀត ឬការចងក្រងជាប្រព័ន្ធទិន្នន័យ ទោះបីជាក្នុងម៉ាស៊ីនដែលអាចអានបាន ឬក៏ជាទម្រង់ផ្សេងទៀត ក៏ត្រូវទទួលបាននូវកិច្ចការពារពីច្បាប់នេះដែរ ។

កិច្ចការពារស្នាដៃណាមួយដែលមានចែងក្នុងវាក្យខ័ណ្ឌខាងលើ មិនធ្វើឱ្យបាត់បង់សិទ្ធិចំពោះកិច្ចការពារស្នាដៃដើមដែលត្រូវបានបញ្ចូល ឬប្រើប្រាស់សម្រាប់ការបង្កើតស្នាដៃថ្មី ។

**មាត្រា ៩.-**

ចំណងជើងនៃស្នាដៃណាមួយដែលបង្ហាញពីលក្ខណៈស្នូលនៃស្នាដៃដើម ចំណងជើងនោះត្រូវទទួលបាននូវកិច្ចការពារពីច្បាប់ដូចគ្នានឹងស្នាដៃនោះដែរ ។

ស្នាដៃមួយ ទោះបីលែងទទួលបាននូវកិច្ចការពារពីច្បាប់តាមមាត្រា ៣០ និងមាត្រា ៣១ នៃច្បាប់នេះក៏ដោយ ក៏គ្មានបុគ្គលណាម្នាក់មានសិទ្ធិប្រើប្រាស់ចំណងជើងនៃស្នាដៃនោះសម្រាប់ធ្វើជាចំណងជើងនៃស្នាដៃមួយផ្សេងទៀត ជាហេតុបង្កឱ្យមានការភ័ន្តច្រឡំ ។

**មាត្រា ១០.-**

ស្នាដៃដែលមិនស្ថិតនៅក្រោមការការពារនៃច្បាប់នេះមាន :

ក-រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យនិងលិខិតបទដ្ឋានផ្លូវការនានា ។

ខ-ប្រកាស សេចក្តីសម្រេច លិខិតបញ្ជាក់ សារាចរណែនាំផ្សេងៗដែលចេញដោយអង្គការរដ្ឋ ។

**គ**-សេចក្តីសម្រេច សាលក្រមឬសាលដីកាផ្សេងៗរបស់តុលាការ ។

**ឃ**-អត្ថបទបកប្រែជាភាសាបរទេសនៃអត្ថបទក្នុងចំណុច **ក** ចំណុច **ខ** និង ចំណុច **គ** ខាងលើក្នុងមាត្រានេះ ។

**ង**-គំនិត នីតិវិធី ប្រព័ន្ធ របៀបប្រតិបត្តិការ ទស្សនៈ គោលការណ៍ ការរុករកឃើញឬទិន្នន័យសាមញ្ញ ទោះបីត្រូវបានផ្សព្វផ្សាយ អត្ថាធិប្បាយ ពន្យល់ឬមានក្នុងស្នាដៃណាមួយក៏ដោយ ។

## ផ្នែកទី ២
## អ្នកនិពន្ធ

**មាត្រា ១១.–**

ឋានៈជាអ្នកនិពន្ធគឺជាឋានៈរបស់បុគ្គលម្នាក់ ឬច្រើននាក់ជាម្ចាស់កម្មសិទ្ធិលើស្នាដៃដែលសាមីខ្លួនបានបង្កើតឡើង ហើយស្នាដៃនោះត្រូវបានផ្សព្វផ្សាយជាសាធារណៈលើកលែងតែមានភស្តុតាងផ្ទុយ ។

**មាត្រា ១២.–**

សហអ្នកនិពន្ធគឺជាម្ចាស់កម្មសិទ្ធិលើស្នាដៃសហការ ។ សហអ្នកនិពន្ធត្រូវតែប្រើសិទ្ធិរបស់ខ្លួនយោងតាមការឯកភាពជាឯកច្ឆន្ទនិងជាលាយលក្ខណ៍អក្សរ ។ នៅពេលមិនឯកភាពគ្នាត្រូវធ្វើពាក្យប្តឹងទៅតុលាការ ។

**មាត្រា ១៣.–**

រូបវន្តបុគ្គលឬនីតិបុគ្គលជាម្ចាស់ស្នាដៃសមូហភាពដែលឈ្មោះបុគ្គលនោះត្រូវគេផ្សាយជាចំហក្នុងពេលធ្វើការផ្សព្វផ្សាយស្នាដៃ បុគ្គលនោះគឺជាអ្នកទទួលបាននូវសិទ្ធិអ្នកនិពន្ធ លើកលែងតែមានភស្តុតាងផ្ទុយ ។

**មាត្រា ១៤.–**

អ្នកនិពន្ធស្នាដៃ រហស្សនាម ឬអានាមិកជាអ្នកទទួលបានសិទ្ធិទាំងឡាយលើស្នាដៃនោះ ។

ដរាបណាអ្នកនិពន្ធនោះនៅតែពុំទាន់បង្ហាញឱ្យគេដឹងពីអត្តសញ្ញាណខ្លួន និងនៅពុំទាន់បង្ហាញភស្តុតាងដែលបញ្ជាក់ឱ្យដឹងពីឋានៈខ្លួន ដរាបនោះអ្នកនិពន្ធនៅតែត្រូវបានជំនួសមុខដោយអ្នកបោះពុម្ពឬអ្នកផ្សព្វផ្សាយលើកដំបូង ដែលនឹងត្រូវផ្តល់សិទ្ធិឱ្យអនុវត្តនិងការពារសិទ្ធិសីលធម៌និងសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ ។ អ្នកបោះពុម្ពផ្សាយ ឬអ្នកផ្សព្វផ្សាយលើកដំបូងត្រូវមានកិច្ចសន្យាបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកនិពន្ធ រហស្ស-នាម ឬអានាមិក ។

វាក្យខ័ណ្ឌទី ២ មិនអាចអនុវត្តបានឡើយ បើរហស្សនាមដែលអ្នកនិពន្ធបានជ្រើសរើសយកនោះត្រូវបានផ្សាយឈ្មោះអ្នកនិពន្ធពិតប្រាកដជាចំហ ។

## មាត្រា ១៥.-

រូបវន្តបុគ្គលម្នាក់ឬច្រើននាក់ដែលបានបង្កើតស្នាដៃសោតទស្សន៍តាមគំនិតប្រាជ្ញារបស់ខ្លួន រូបវន្តបុគ្គលនោះត្រូវបានទទួលឋានៈជាអ្នកនិពន្ធស្នាដៃសោតទស្សន៍ ។

លើកលែងតែមានភស្តុតាងផ្ទុយ សហអ្នកនិពន្ធនៃស្នាដៃសោតទស្សន៍មាន :

**ក**-សមិទ្ធិករ ។

**ខ**-អ្នកនិពន្ធសេណារីយ៉ូ ។

**គ**-អ្នកនិពន្ធដោយយកលំនាំតាម ។

**ឃ**-អ្នកនិពន្ធអត្ថបទនិយាយ ។

**ង**-អ្នកនិពន្ធបទភ្លេងមាន ឬគ្មានទំនុកច្រៀងដែលជាបទភ្លេងត្រូវបានបង្កើតឡើងជាពិសេសសម្រាប់តែជាប្រយោជន៍ស្នាដៃនោះ ។

**ច**-អ្នកនិពន្ធសិល្បៈគំនូរសម្រាប់ស្នាដៃគំនូរជីវចល ។

## មាត្រា ១៦.-

អ្នកនិពន្ធស្នាដៃគឺជាអ្នកមានសិទ្ធិធ្វើជាម្ចាស់លើសិទ្ធិសីលធម៌ និងសិទ្ធិបេតិកភណ្ឌ។ ក្នុងករណីដែលអ្នកនិពន្ធបានបង្កើតស្នាដៃដើម្បីជាប្រយោជន៍ឱ្យដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជានិយោជកក្នុងក្របខ័ណ្ឌនៃកិច្ចសន្យាការងារ និងកិច្ចសន្យាការប្រើប្រាស់ស្នាដៃ សិទ្ធិបេតិកភណ្ឌលើស្នាដៃនោះត្រូវបានចាត់ទុកថាបានផ្ទេរជូននិយោជក លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីកិច្ចសន្យាទាំងនោះ ។

**មាត្រា ១៧.–**

សមិទ្ធិករស្នាដៃសោតទស្សន៍មួយដែលមានការចូលរួមវិភាគទានពីសហអ្នកនិពន្ធបង្កើតស្នាដៃតាមកិច្ចសន្យាដោយមិនរាប់បញ្ចូលអ្នកនិពន្ធស្នាដៃតូរ្យតន្ត្រី សមិទ្ធិករនោះទទួលបាននូវសិទ្ធិបេតិកភណ្ឌរបស់សហអ្នកនិពន្ធ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីកិច្ចសន្យា ។ ប៉ុន្តែសហអ្នកនិពន្ធនោះ នៅតែរក្សាសិទ្ធិបេតិកភណ្ឌរបស់គេបានតាមទំហំនៃការប្រើប្រាស់វិភាគទាន ក្នុងករណីការរួមវិភាគទាននោះបានប្រព្រឹត្តឡើងដាច់ដោយឡែកពីការបង្កើតស្នាដៃសោតទស្សន៍ ។

## ផ្នែកទី ៣
## សិទ្ធិអ្នកនិពន្ធ

**មាត្រា ១៨.–**

អ្នកនិពន្ធស្នាដៃជាអ្នកទទួលបាននូវសិទ្ធិជាម្ចាស់កម្មសិទ្ធិផ្តាច់មុខលើស្នាដៃនោះហើយជាសិទ្ធិដែលជនគ្រប់រូបត្រូវតែទទួលស្គាល់ ។

សិទ្ធិនេះមានសិទ្ធិសីលធម៌និងសិទ្ធិបេតិកភណ្ឌ ។

**មាត្រា ១៩.–**

សិទ្ធិសីលធម៌របស់អ្នកនិពន្ធគឺជាសិទ្ធិអចិន្ត្រៃយ៍ មិនអាចលក់ដូរបាន មិនអាចរឹបអូសបាននិងមិនអាចផុតអាជ្ញាយុកាល ។ សិទ្ធិនេះអាចត្រូវបានផ្ទេរទៅឱ្យទាយាទរបស់អ្នកនិពន្ធ ដោយមូលហេតុអ្នកនិពន្ធបានទទួលមរណភាពឬប្រគល់ជូនតតីយជនបាន ដោយយោងតាមបទប្បញ្ញត្តិមរតកសាសន៍ ។

ក្នុងករណីគ្មានអ្នកទទួលមរតក រដ្ឋដែលតំណាងដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាអ្នកគ្រប់គ្រងសិទ្ធិនោះ ។

**មាត្រា ២០.–**

សិទ្ធិសីលធម៌របស់អ្នកនិពន្ធមានបីចំណុចដូចខាងក្រោម :

**ក**-អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខក្នុងការសម្រេចពីរបៀបនិងពេលវេលានៃ

ការផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈ ព្រមទាំងបែបបទគ្រប់គ្រងការផ្សព្វផ្សាយ ។

**ខ**-អ្នកនិពន្ធមានសិទ្ធិកំណត់ឱ្យគេទទួលស្គាល់ឈ្មោះ ឋានៈ និងស្នាដៃរបស់ខ្លួនសម្រាប់ទាក់ទងជាមួយសាធារណជន ។

**គ**-អ្នកនិពន្ធមានសិទ្ធិជំទាស់នូវគ្រប់រូបភាពនៃការបំផ្លើស ឬការកាត់ចោលខ្លឹមសារ ឬការកែប្រែខ្លឹមសារ ជាហេតុធ្វើឱ្យខូចកិត្តិយសឬកេរ្តិ៍ឈ្មោះខ្លួន ។

## មាត្រា ២១.-

សិទ្ធិបេតិកភណ្ឌជាសិទ្ធិប្រកបអាជីវកម្មរបស់អ្នកនិពន្ធលើទ្រព្យជាស្នាដៃរបស់ខ្លួនតាមរយៈការផលិតឡើងវិញ ការផ្សព្វផ្សាយជាសាធារណៈនិងការបង្កើតស្នាដៃបន្ត ។

លើកលែងតែក្នុងករណីនៃបទប្បញ្ញត្តិចែងក្នុងមាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៧ មាត្រា ២៨ និងមាត្រា ២៩ នៃច្បាប់នេះ អ្នកនិពន្ធមានសិទ្ធិផ្ដាច់មុខធ្វើដោយខ្លួនឯងឬអនុញ្ញាតឱ្យគេធ្វើកិច្ចការដូចតទៅ :

**ក**-ការបកប្រែជាភាសាបរទេសនូវស្នាដៃរបស់ខ្លួន ។

**ខ**-ការយកលំនាំតាមឬការកែសម្រួលផ្សេងៗទៀតនៃស្នាដៃ ។

**គ**-ការជួលស្នាដៃច្បាប់ដើម ឬច្បាប់ចម្លងស្នាដៃសោតទស្សន៍ ឬស្នាដៃថតបញ្ចូលជាហ្វូណូក្រាម កម្មវិធីកុំព្យូទ័រ ប្រព័ន្ធទិន្នន័យ ឬស្នាដៃតូរ្យតន្ត្រីជាអក្សរភ្លេង ។

**ឃ**-ការចែកចាយជាសាធារណៈតាមការលក់ ការជួល ឬតាមមធ្យោបាយផ្សេងទៀតនូវច្បាប់ដើម ឬច្បាប់ចម្លងដែលពុំទាន់បានលក់ ឬផ្ទេរកម្មសិទ្ធិ ។

**ង**-ការនាំចូលក្នុងប្រទេសនូវស្នាដៃចម្លងចេញពីស្នាដៃរបស់សាមីខ្លួនដែលជាអ្នកនិពន្ធ ។

**ច**-ការផលិតស្នាដៃឡើងវិញ ។

**ឆ**-ការសម្ដែងស្នាដៃជាសាធារណៈ ។

**ជ**-ការបង្ហាញស្នាដៃជាសាធារណៈ ។

**ឈ**-ការផ្សាយស្នាដៃតាមទូរផ្សាយ ។

**ញ**-ការផ្សព្វផ្សាយស្នាដៃជាសាធារណៈតាមវិធីផ្សេងៗទៀត ។

សិទ្ធិដាក់ជួលដូចមានចែងក្នុងចំណុច **គ** នៃមាត្រានេះ មិនត្រូវអនុវត្តចំពោះការ

ជួលកម្មវិធីកុំព្យូទ័រឡើយ ក្នុងករណីដែលកម្មវិធីកុំព្យូទ័រនោះមិនមែនជាកម្មវត្ថុដ៏សំខាន់សម្រាប់ការដាក់ជួល ។

**មាត្រា ២២.–**

សិទ្ធិបេតិកភណ្ឌចំពោះកម្មវិធីកុំព្យូទ័រនិងឯកសារសមោធានដែលបង្កើតឡើងដោយនិយោជិតម្នាក់ឬច្រើននាក់ ក្នុងពេលបំពេញមុខនាទីឬក្នុងពេលធ្វើតាមសេចក្តីបង្គាប់របស់និយោជក ជាកម្មសិទ្ធិរបស់និយោជក លើកលែងតែមានកិច្ចសន្យាចែងផ្ទុយពីនេះ ។

ចំពោះជនណាម្នាក់ដែលបានជួលបុគ្គលណាផ្សេងឱ្យបង្កើតកម្មវិធីកុំព្យូទ័រឱ្យខ្លួនដោយឆ្លងតាមកិច្ចសន្យាបញ្ជាទិញ ជននោះត្រូវបានទទួលសិទ្ធិបេតិកភណ្ឌ ។

## ផ្នែកទី ៤
## ការកម្រិតសិទ្ធិអ្នកនិពន្ធ

**មាត្រា ២៣.–**

រូបវន្តបុគ្គលណាម្នាក់នាំចូលនូវស្នាដៃមួយច្បាប់សម្រាប់សេចក្តីត្រូវការផ្ទាល់ខ្លួនអាចប្រព្រឹត្តទៅបានដោយពុំចាំបាច់តម្រូវឱ្យមានការអនុញ្ញាតពីអ្នកនិពន្ធ ឬពីម្ចាស់សិទ្ធិលើស្នាដៃនោះឡើយ ។

**មាត្រា ២៤.–**

ការផលិតឡើងវិញចំនួនមួយច្បាប់ជាលក្ខណៈឯកជននូវស្នាដៃដែលបានបោះផ្សាយហើយសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួននឹងត្រូវអនុវត្តបាន ដោយពុំចាំបាច់មានការអនុញ្ញាតពីអ្នកនិពន្ធ ឬម្ចាស់កម្មសិទ្ធិឡើយ ។

ការអនុញ្ញាតដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើនៃមាត្រានេះមិនត្រូវយកមកអនុ-វត្តចំពោះការផលិតឡើងវិញនូវ :

**ក**-ស្នាដៃស្ថាបត្យកម្ម មានទម្រង់ជាអាគារ ឬសំណង់ផ្សេងៗ ។

**ខ**-ការចម្លងទាំងស្រុង ឬភាគសំខាន់ខ្លះនូវសៀវភៅតាមវិធីបោះពុម្ពជាថ្មី និងការចម្លងស្នាដៃតូរ្យតន្ត្រីក្រោមរូបភាពជាអក្សរភ្លេង ។

**គ**-ការចម្លងទាំងស្រុងឬភាគសំខាន់ខ្លះនូវប្រព័ន្ធទិន្នន័យតាមទម្រង់ឌីជី-ថល ។

**ឃ**-កម្មវិធីកុំព្យូទ័រ លើកលែងតែច្បាប់ចម្លងកម្មវិធីដើម្បីរក្សាទុកសម្រាប់ការពារការបាត់បង់ ។

**ង**-ស្នាដៃណាមួយក្នុងលក្ខណៈដែលការផលិតឡើងវិញធ្វើឱ្យប៉ះពាល់ដល់អាជីវកម្មជាប្រក្រតីនៃស្នាដៃ ឬធ្វើឱ្យខូចខាតដោយមិនសមហេតុផលទៅលើផលប្រយោជន៍ស្របច្បាប់របស់អ្នកនិពន្ធឬម្ចាស់កម្មសិទ្ធិ ។

**មាត្រា ២៥.–**

អ្នកនិពន្ធមិនអាចធ្វើការហាមឃាត់បានចំពោះ :

**ក**-ការសម្តែងស្នាដៃជាឯកជនដោយមិនគិតកម្រៃ ជាការសម្តែងក្នុងរង្វង់គ្រួសារឬញាតិមិត្ត ។

**ខ**-ការរៀបចំទុកក្នុងបណ្ណាល័យនូវសំណៅស្នាដៃណាមួយ ដើម្បីរក្សាទុកឱ្យបានគង់វង្សឬដើម្បីទុកសម្រាប់ធ្វើការស្រាវជ្រាវ ។

**គ**-ការប្រើប្រាស់ស្នាដៃសម្រាប់ការសិក្សាដោយគ្មានរកប្រាក់កម្រៃ ។

**ឃ**-ការបកប្រែស្នាដៃពីភាសាខ្មែរទៅជាភាសាជនជាតិភាគតិច ឬបកប្រែពីភាសាជនជាតិភាគតិចមកជាភាសាខ្មែរ ។

ប្រសិនបើមានការបញ្ជាក់យ៉ាងច្បាស់លាស់នូវឈ្មោះរបស់អ្នកនិពន្ធនិងប្រភពនៃស្នាដៃ អ្នកនិពន្ធមិនអាចធ្វើការហាមឃាត់ចំពោះកិច្ចការទាំងឡាយដូចតទៅ :

-ការវិភាគ និងអាគតដ្ឋានខ្លីៗនៃស្នាដៃដែលបញ្ជាក់ពីការរិះគន់ សង្គ្រាមប៉ាកកាគរុកោសល្យ វិទ្យាសាស្ត្រឬព័ត៌មានស្តីពីស្នាដៃនោះ

-ការផ្សាយទស្សនៈសារព័ត៌មាន

-ការផ្សព្វផ្សាយទាំងស្រុងឬភាគខ្លះនៃសុន្ទរកថានានាដែលបានថ្លែងជាសា-ធារណៈក្នុងសារព័ត៌មានឬទូរផ្សាយ

-ការត្រាប់កំប្លែង ការត្រាប់តាមគំរូ ឬគំនូរត្លុកដោយផ្អែកតាមលំនាំដើមនៃស្នាដៃ

-ការចម្លងរូបភាពស្នាដៃសិល្បៈក្រាហ្វិកឬសិល្បៈសូនរូបដែលស្ថិតនៅទីកន្លែងសាធារណៈមួយ លើកលែងតែរូបភាពនោះត្រូវបានចាត់ទុកថាជាកម្មវត្ថុសំខាន់នៃការចម្លងបន្ត ។

**មាត្រា ២៦.–**

អ្នកនិពន្ធដែលបង្កើតស្នាដៃជាខ្សែភាពយន្ត វីដេអូ ល្ខោននិយាយ ប្រលោមលោកអំពីឆាកជីវិតនៃបុគ្គលឬគ្រួសារជាក់លាក់ណាមួយត្រូវមានការអនុញ្ញាតជាមុនពីបុគ្គលសាមីឬពីញាតិពន្ធដែលបានទទួលមរតកសាសន៍ ។

**មាត្រា ២៧.–**

ការផលិតឡើងវិញជាបណ្តោះអាសន្ននូវស្នាដៃមួយបាន លុះត្រាតែការផលិតឡើងវិញនោះធ្វើឡើងស្របពេលជាមួយនឹងការប្រើប្រាស់ស្នាដៃដែលបានទទួលការអនុញ្ញាតពីម្ចាស់សិទ្ធិ ។

**មាត្រា ២៨.–**

ដោយមិនគិតពីបទប្បញ្ញត្តិនៃមាត្រា ២១ ច្បាប់នេះអាចអនុញ្ញាតឱ្យស្រង់អាគតដ្ឋានពីស្នាដៃណាមួយជាស្នាដៃដែលបានផ្សព្វផ្សាយត្រឹមត្រូវតាមច្បាប់បញ្ចូលក្នុងស្នាដៃមួយផ្សេងទៀត ដោយពុំចាំបាច់សុំការអនុញ្ញាតពីអ្នកនិពន្ធនិងពុំចាំបាច់បង់ប្រាក់កម្រៃ ។

ការស្រង់អាគតដ្ឋានត្រូវបញ្ជាក់អំពីប្រភពនិងឈ្មោះអ្នកនិពន្ធ បើនៅក្នុងប្រភពនោះមានឈ្មោះអ្នកនិពន្ធច្បាស់លាស់ ។ ការស្រង់អាគតដ្ឋាននេះមិនត្រូវធ្វើឱ្យហួសពីគោលដៅដែលត្រូវបំពេញនោះឡើយ ។

**មាត្រា ២៩.–**

ដោយមិនគិតពីបទប្បញ្ញត្តិក្នុងមាត្រា ២១ ច្បាប់នេះអាចអនុញ្ញាត :

**ក**-ឱ្យប្រើប្រាស់ស្នាដៃណាមួយដែលបានផ្សព្វផ្សាយត្រឹមត្រូវតាមច្បាប់ដើម្បីបញ្ជាក់ឱ្យបានច្បាស់ក្នុងទំព័រសៀវភៅឬសារពត៌មាន ឬតាមរលកវិទ្យុ ឬក្នុងការចាក់ផ្សាយសម្លេង ឬបញ្ចាំងរូបភាពដើម្បីជាប្រយោជន៍ដល់ការសិក្សាដោយពុំចាំបាច់បង់

ប្រាក់កម្រៃ ប៉ុន្តែត្រូវបញ្ជាក់ពីប្រភពនិងឈ្មោះអ្នកនិពន្ធ បើនៅក្នុងប្រភពនោះមានឈ្មោះអ្នកនិពន្ធច្បាស់លាស់ ។

**២**-ឱ្យថតចម្លងបាននូវអត្ថបទដាច់ដោយឡែកនានា អត្ថបទផ្សាយនៅក្នុងទំព័រសារពត៌មាន ឬទស្សនាវដ្តី ឬថតចម្លងបាននូវខ្លឹមសារដកស្រង់ខ្លីៗចេញពីស្នាដៃណាមួយដែលត្រូវបានផ្សាយត្រឹមត្រូវតាមច្បាប់ ។ ការថតចម្លងនេះ ធ្វើឡើងតាមរយៈមធ្យោបាយ បច្ចេកទេសចម្លង ដោយមិនរកប្រាក់ចំណេញខាងពាណិជ្ជកម្មដើម្បីជាប្រយោជន៍ដល់ការបង្រៀនឬដល់ការប្រឡងដែលធ្វើឡើងនៅក្នុងគ្រឹះស្ថានសិក្សានានាសមស្របទៅតាមគោលដៅដែលត្រូវបំពេញ ។ ការថតចម្លងនូវអត្ថបទឬខ្លឹមសារខ្លីៗពុំចាំបាច់បង់ប្រាក់កម្រៃ ប៉ុន្តែត្រូវបញ្ជាក់ពីប្រភពនិងឈ្មោះអ្នកនិពន្ធ ប្រសិនបើនៅក្នុងប្រភពនោះមានឈ្មោះអ្នកនិពន្ធច្បាស់លាស់ ។

## ផ្នែកទី ៥
## រយៈពេលនៃកិច្ចការពារសិទ្ធិបេតិកភណ្ឌ

### មាត្រា ៣០.-

សិទ្ធិបេតិកភណ្ឌត្រូវបានការពារចាប់តាំងពីថ្ងៃដែលបានបង្កើតស្នាដៃ ។ រយៈពេលកិច្ចការពារសិទ្ធិនេះត្រូវប្រព្រឹត្តទៅអស់មួយជីវិតអ្នកនិពន្ធព្រមទាំងប្រព្រឹត្តទៅ ៥០(ហាសិប)ឆ្នាំ ក្រោយថ្ងៃទទួលមរណភាពរបស់អ្នកនិពន្ធ ។

កិច្ចការពារសិទ្ធិបេតិកភណ្ឌលើស្នាដៃសហការប្រព្រឹត្តទៅអស់មួយជីវិតអ្នកនិពន្ធដែលរស់នៅចុងក្រោយគេ ព្រមទាំងប្រព្រឹត្តទៅរយៈពេល ៥០(ហាសិប)ឆ្នាំ ក្រោយថ្ងៃទទួលមរណភាពរបស់អ្នកនិពន្ធចុងក្រោយនេះ ។

### មាត្រា ៣១.-

សិទ្ធិបេតិកភណ្ឌលើស្នាដៃមួយដែលត្រូវបានបោះពុម្ពផ្សាយជាអានាមិកក្តី ឬជារហស្សនាមក្តីត្រូវទទួលបាននូវកិច្ចការពារពីច្បាប់នេះ ក្នុងរយៈពេល ៧៥(ចិតសិបប្រាំ)ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃឆ្នាំដែលស្នាដៃនោះបានបោះពុម្ពផ្សាយជាលើកដំបូង ដោយមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ។

ប្រសិនបើពុំមានការបោះពុម្ពផ្សាយជាលើកដំបូងក្នុងរយៈពេល ៥០(ហាសិប)ឆ្នាំ បន្ទាប់ពីពេលបង្កើតស្នាដៃនោះ កិច្ចការពាររយៈពេល ១០០(មួយរយ)ឆ្នាំ នឹងត្រូវបាន គិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃឆ្នាំដែលស្នាដៃនោះបានបង្កើត ។

បើសិនជាមុនពេលកំណត់នៃកិច្ចការពារពីច្បាប់ អត្តសញ្ញាណអ្នកនិពន្ធត្រូវបាន បង្ហាញឱ្យស្គាល់ ឬត្រូវសាធារណជនបានស្គាល់ច្បាស់ឥតសង្ស័យ គឺបទប្បញ្ញត្តិនៃមាត្រា ៣០ ក្នុងច្បាប់នេះត្រូវយកមកអនុវត្ត ។

សិទ្ធិបេតិកភណ្ឌលើស្នាដៃសម្ភហភាព ឬស្នាដៃសោតទស្សន៍ ឬស្នាដៃបច្ឆាមរណៈ ត្រូវទទួលបាននូវកិច្ចការពារពីច្បាប់ក្នុងរយៈពេល ៧៥(ចិតសិបប្រាំ)ឆ្នាំ គិតចាប់ពីដំណាច់ ឆ្នាំប្រក្រតីទិននៃឆ្នាំដែលស្នាដៃនោះបានផ្សព្វផ្សាយជាលើកដំបូងត្រឹមត្រូវតាមច្បាប់ ។

ប្រសិនបើពុំមានការផ្សព្វផ្សាយក្នុងរយៈពេល ៥០(ហាសិប)ឆ្នាំ បន្ទាប់ពីពេល បង្កើតស្នាដៃនោះ កិច្ចការពាររយៈពេល ១០០(មួយរយ)ឆ្នាំ នឹងត្រូវបានគិតចាប់ពីដំ-ណាច់ឆ្នាំប្រក្រតីទិននៃឆ្នាំដែលស្នាដៃនោះបានបង្កើត ។

## ផ្នែកទី ៦
## ការផ្ទេរសិទ្ធិបេតិកភណ្ឌ

### មាត្រា ៣២.–

ការផ្ទេរសិទ្ធិលើចំណុចណាមួយដែលមានចែងក្នុងមាត្រា ២១ ក្នុងច្បាប់នេះ មិន មែនជាការផ្ទេរសិទ្ធិលើចំណុចដទៃទៀតឡើយ ។

ប្រសិនបើមានកិច្ចសន្យាចែងអំពីការផ្ទេរ ឬការផ្តល់អាជ្ញាប័ណ្ណលើសិទ្ធិណាមួយ ដូចមានចែងក្នុងមាត្រានេះ ប្រសិទ្ធិភាពនៃការផ្ទេរឬការផ្តល់នោះត្រូវគោរពតាមល័ក្ខ-ខ័ណ្ឌនៃរបៀបធ្វើអាជីវកម្មដូចមានចែងក្នុងកិច្ចសន្យា ។

### មាត្រា ៣៣.–

ការគ្រប់គ្រងសិទ្ធិបេតិកភណ្ឌអាចផ្ទេរឱ្យទាយាទរបស់អ្នកនិពន្ធបានដោយមូល-ហេតុមរណភាពរបស់អ្នកនិពន្ធ ឬអាចប្រគល់ជូនតតីយជនបានដោយយោងតាមបទ-ប្បញ្ញត្តិនៃមរតកសាសន៍ ។

ក្នុងករណីគ្មានអ្នកទទួលមរតកឬគ្មានមរតកសាសន៍ រដ្ឋដែលតំណាងដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាអ្នកគ្រប់គ្រងសិទ្ធិនោះ ។

## ផ្នែកទី ៧
## ការធ្វើអាជីវកម្មសិទ្ធិបេតិកភណ្ឌ

**មាត្រា ៣៤.–**

កិច្ចសន្យាទាំងឡាយស្តីពីការធ្វើអាជីវកម្មសិទ្ធិបេតិកភណ្ឌត្រូវធ្វើឡើងដោយលាយលក្ខណ៍អក្សរជាក់លាក់ បើមិនដូច្នោះទេ កិច្ចសន្យានេះនឹងត្រូវចាត់ទុកជាមោឃៈ ។ មានតែអ្នកនិពន្ធឬម្ចាស់សិទ្ធិប៉ុណ្ណោះដែលមានសិទ្ធិលើកនូវហេតុផលដើម្បីស្នើសុំមោឃ-ភាពនៃកិច្ចសន្យា ។

**មាត្រា ៣៥.–**

កិច្ចសន្យានៃការផ្ទេរសិទ្ធិធ្វើអាជីវកម្មរបស់អ្នកនិពន្ធត្រូវធ្វើជាលាយលក្ខ័អក្សរដោយបញ្ជាក់ដាច់ដោយឡែកពីគ្នាអំពីកម្រិត ទំហំ គោលដៅ ទីកន្លែងនិងរយៈពេលនៃការផ្ទេរសិទ្ធិនីមួយៗឱ្យបានច្បាស់លាស់ ។

**មាត្រា ៣៦.–**

ក្នុងក្របខ័ណ្ឌនៃការបង្កើតស្នាដៃសមូហភាព អ្នកនិពន្ធម្នាក់ៗអាចធ្វើអាជីវកម្មលើវិភាគទានរបស់ខ្លួនដាច់ដោយឡែកពីគ្នាបាន លើកលែងតែមានបទប្បញ្ញត្តិផ្ទុយ ប៉ុន្តែអ្នកនិពន្ធនោះមិនត្រូវបង្កឱ្យខូចខាតដល់អាជីវកម្មនៃស្នាដៃសមូហភាពនោះឡើយ ។

ចំពោះស្នាដៃសហការ ការធ្វើអាជីវកម្មអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការយល់ព្រមពីសហអ្នកនិពន្ធ ។ នៅពេលសហអ្នកនិពន្ធមិនឯកភាពគ្នា តុលាការជាអ្នកសម្រេច ។

**មាត្រា ៣៧.–**

ការផ្ទេរសិទ្ធិដើម្បីធ្វើអាជីវកម្មលើស្នាដៃរបស់អ្នកនិពន្ធអាចផ្ទេរទាំងស្រុង ឬផ្ទេរជាភាគខ្លះបាន ។ ម្ចាស់សិទ្ធិនឹងទទួលបានកម្រៃពីការផ្ទេរសិទ្ធិនេះ អនុលោមតាមប្រការ

ទាំងឡាយនៃកិច្ចសន្យាផ្ទេរសិទ្ធិនោះ ។

## ផ្នែកទី ៨
## ការតម្កល់ និង ការចុះបញ្ជីនៃស្នាដៃ

**មាត្រា ៣៨.–**

រាល់ស្នាដៃទាំងអស់ត្រូវទទួលបាននូវកិច្ចការពារពីច្បាប់នេះជាស្វ័យប្រវត្តិ ។ អ្នកនិពន្ធឬម្ចាស់សិទ្ធិអាចតម្កល់ទុកស្នាដៃនៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

**មាត្រា ៣៩.–**

ការចុះបញ្ជីអាចធ្វើឡើងបានដោយស្ម័គ្រចិត្តនៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។ ការចុះបញ្ជីត្រូវចុះឈ្មោះពិតប្រាកដរបស់អ្នកនិពន្ធ ចុះថ្ងៃ ខែ ឆ្នាំ នៃស្នាដៃដែលបានផ្សព្វផ្សាយជាលើកដំបូង និងចុះថ្ងៃ ខែ ឆ្នាំ នៃការបង្កើតស្នាដៃព្រមទាំងចុះពីសិទ្ធិរបស់អ្នកនិពន្ធ ។

**មាត្រា ៤០.–**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវចេញវិញ្ញាបនប័ត្រចំពោះស្នាដៃដែលបានចុះបញ្ជី ។ អ្នកស្នើសុំចុះបញ្ជីត្រូវបង់កម្រៃទៅតាមប្រកាសរួមរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៣
## សិទ្ធិប្រហាក់ប្រហែល
## ផ្នែកទី ១
## សិទ្ធិអ្នកសម្តែង

**មាត្រា ៤១.–**

អ្នកសម្តែងមានសិទ្ធិផ្តាច់មុខក្នុងការធ្វើដោយផ្ទាល់ឬអនុញ្ញាត :

**ក**-ការផ្សាយតាមទូរផ្សាយនិងការផ្សព្វផ្សាយជាសាធារណៈ នូវការសម្តែង

របស់ខ្លួន លើកលែងតែការផ្សាយទាំងនោះបានផ្សាយចេញពីហ្វូណូក្រាមស្តីពីការសម្តែង ដែលបានអនុញ្ញាតពីអ្នកសម្តែង ឬបានផ្សាយឡើងវិញតាមទូរផ្សាយ ឬបានការអនុញ្ញាត ពីអង្គភាពទូរផ្សាយដែលបានផ្សាយមុនគេនូវការសម្តែង ។

**ខ**-ការថតបញ្ចូលជាហ្វូណូក្រាមនូវការសម្តែងរបស់ខ្លួនដែលមិនទាន់បាន ថតបញ្ចូលហ្វូណូក្រាម ។

**គ**-ការផលិតឡើងវិញនូវការសម្តែងដែលបានថតបញ្ចូលជាហ្វូណូក្រាម ។

**ឃ**-ការចែកចាយជាសាធារណៈតាមការលក់ឬការផ្ទេរកម្មសិទ្ធិនូវហ្វូណូ-ក្រាមច្បាប់ដើមដែលអ្នកសម្តែងពុំទាន់បានអនុញ្ញាតឱ្យធ្វើការចែកចាយ ។

**ង**-ការដាក់ជួលឬការឱ្យខ្ចីជាសាធារណៈនូវហ្វូណូក្រាមច្បាប់ដើម ឬ ហ្វូណូក្រាមច្បាប់ចម្លងស្តីពីការសម្តែង ។

បើគ្មានកិច្ចព្រមព្រៀង ផ្ទុយពីនេះ អ្នកសម្តែងមានសិទ្ធិ :

-អនុញ្ញាតចាក់ផ្សាយតាមអង្គភាពទូរផ្សាយណាមួយ ប៉ុន្តែអង្គភាពទូរផ្សាយ ដទៃទៀតពុំមានសិទ្ធិធ្វើការចាក់ផ្សាយនូវការសម្តែងរបស់ខ្លួនបានទេ

-អនុញ្ញាតចាក់ផ្សាយតាមអង្គភាពទូរផ្សាយណាមួយ ប៉ុន្តែអង្គភាពទូរផ្សាយ នោះពុំមានសិទ្ធិថតបញ្ចូលជាហ្វូណូក្រាមនូវការសម្តែងរបស់ខ្លួនទេ ។

**មាត្រា ៤២.-**

ទោះបីមានការផ្ទេរសិទ្ធិបេតិកភណ្ឌរបស់ខ្លួនហើយក៏ដោយ អ្នកសម្តែងនៅមាន សិទ្ធិតម្រូវឱ្យគេសរសេរឈ្មោះខ្លួនលើការសម្តែងផ្ទាល់ ឬការសម្តែងដែលបានថតទុក លើកលែងតែក្នុងករណីដែលវិធីប្រើប្រាស់នៃការសម្តែងនោះពុំតម្រូវឱ្យមានការសរសេរ ឈ្មោះ ។ អ្នកសម្តែងនៅមានសិទ្ធិជំទាស់គ្រប់រូបភាពនៃការបំផ្លើស ការកាត់តខ្លឹមសារ ខ្លះឬកែប្រែខ្លឹមសារនៃការសម្តែងជាហេតុធ្វើឱ្យខូចកេរ្តិ៍ឈ្មោះអ្នកសម្តែង ។

**មាត្រា ៤៣.-**

អ្នកសម្តែងមិនអាចហាមឃាត់នូវការផលិតឡើងវិញនិងការផ្សព្វផ្សាយជាសាធា-រណៈស្តីពីការសម្តែងរបស់ខ្លួនបានឡើយ បើការសម្តែងនោះមានលក្ខណៈបន្ទាប់បន្សំនៅ ក្នុងសាច់រឿងស្នូលរបស់ឈុត ឬស្នាដៃ ឬឯកសារសោតទស្សន៍ ។

## ផ្នែកទី ២
## សិទ្ធិរបស់ផលិតករហ្វូណូក្រាម

**មាត្រា ៤៤.-**

ផលិតករហ្វូណូក្រាមមានសិទ្ធិផ្តាច់មុខក្នុងការថត ឬការផលិតឡើងវិញ ឬការផ្សព្វផ្សាយជាសាធារណៈនូវហ្វូណូក្រាមរបស់ខ្លួន ។

**មាត្រា ៤៥.-**

រាល់ការផលិតឡើងវិញ ការលក់ ការប្តូរ ការជួល ឬការផ្សព្វផ្សាយជាសាធារណៈនូវហ្វូណូក្រាមត្រូវមានការអនុញ្ញាតពីផលិតករហ្វូណូក្រាម ។

ផលិតករហ្វូណូក្រាមមានសិទ្ធិចែកចាយជាសាធារណៈតាមការលក់ ឬការផ្ទេរកម្មសិទ្ធិនូវច្បាប់ដើមឬច្បាប់ចម្លង ក្នុងករណីដែលផលិតករហ្វូណូក្រាមនោះពុំទាន់អនុ-ញ្ញាតឱ្យជនណាម្នាក់ធ្វើការចែកចាយ ។

ផលិតករហ្វូណូក្រាមមានសិទ្ធិនាំចូលនូវច្បាប់ចម្លងនៃហ្វូណូក្រាមរបស់ខ្លួនក្នុងទិសដៅធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

## ផ្នែកទី ៣
## សិទ្ធិផលិតករវីដេអូ

**មាត្រា ៤៦.-**

ផលិតករវីដេអូគឺជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានការផ្តួចផ្តើមគំនិតនិងការទទួលខុសត្រូវក្នុងការថតបញ្ចូលតាមបច្ចេកទេសផ្សាយនូវរូបភាពជាឈុតៗដែលមានឬគ្មានសម្លេងដើម្បីផលិតវីដេអូ ។

រាល់ការផលិតឡើងវិញនូវវីដេអូដើម្បីផ្សព្វផ្សាយជាសាធារណៈ លក់ ដូរ ឬជួលចាំបាច់ត្រូវតែមានការអនុញ្ញាតពីផលិតករវីដេអូ ។

ការផ្ទេរសិទ្ធិរបស់ផលិតករវីដេអូដូចមានចែងក្នុងមាត្រានេះ មិនអាចធ្វើឡើងដាច់ដោយឡែកពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិអ្នកសម្តែងដែលបានរួមសហការផលិតជាវីដេអូបានឡើយ ។

## ជំពូកទី ៤
## សិទ្ធិនៃអង្គភាពទូរផ្សាយ

**មាត្រា ៤៧.–**

អង្គភាពទូរផ្សាយមានស្ថានីយវិទ្យុ ស្ថានីយទូរទស្សន៍និងស្ថានីយទូរទស្សន៍ខ្សែកាប មានសិទ្ធិផ្តាច់មុខក្នុងការធ្វើ ឬអនុញ្ញាតការថតកម្មវិធីផ្សាយ ការផ្សព្វផ្សាយជាសាធារណៈ ការចាក់ផ្សាយឡើងវិញ ការផលិតឡើងវិញ ការចែកចាយ ឬការដាក់ជួលជាលើកដំបូងនូវច្បាប់ចម្លងនៃកម្មវិធីផ្សាយរបស់ស្ថានីយសាមី ។

**មាត្រា ៤៨.–**

ការថតចម្លងនូវកម្មវិធីរបស់អង្គភាពទូរផ្សាយដើម្បីលក់ ជួល ប្តូរ ចាក់ផ្សាយ ឬផ្សព្វផ្សាយជាសាធារណៈនៅទីកន្លែងណាមួយត្រូវមានការអនុញ្ញាតពីអង្គភាពទូរផ្សាយសាមី ។

## ជំពូកទី ៥
## លាភការ

**មាត្រា ៤៩.–**

ប្រសិនបើហ្វូណូក្រាមបានផលិតក្នុងគោលបំណងពាណិជ្ជកម្ម ឬជាការផលិតឡើងវិញត្រូវបានយកទៅផ្សព្វផ្សាយតាមទូរផ្សាយ ឬផ្សព្វផ្សាយផ្សេងទៀតជាសាធារណៈ ឬសម្តែងជាសាធារណៈ អ្នកសម្តែងនិងផលិតករហ្វូណូក្រាមត្រូវទទួលបាននូវលាភការគ្រប់គ្នាតែមួយលើកគត់ប្រកបដោយសមធម៌ ដែលអ្នកប្រើប្រាស់ត្រូវបង់លាភការនោះជូនអង្គភាពគ្រប់គ្រងសិទ្ធិរួម ។

អង្គភាពគ្រប់គ្រងសិទ្ធិរួមគឺជានីតិបុគ្គលមានភារកិច្ចចាត់ចែងការងារស្តីពីលាភការនេះដែលកំណត់ដោយអនុក្រឹត្យ ។

# ផ្នែកទី ៦
# ការកម្រិតសិទ្ធិ

## មាត្រា ៥០.-

ដោយមិនគិតដល់បទប្បញ្ញត្តិនៃមាត្រា ៤១ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ មាត្រា ៤៧ និងមាត្រា ៤៨ នៃច្បាប់នេះ សកម្មភាពទាំងឡាយដូចតទៅនេះ ត្រូវអនុញ្ញាតឱ្យអនុវត្តបានដោយពុំចាំបាច់ទទួលការយល់ព្រមពីសិទ្ធិវន្ត និងពុំចាំបាច់បង់ប្រាក់កម្រៃ :

**ក**-សេចក្តីរាយការណ៍ស្តីពីបច្ចុប្បន្នភាពក្នុងលក្ខខណ្ឌដែលសេចក្តីរាយការណ៍នោះបានដកស្រង់ជាផ្នែកខ្លីៗពីការសម្តែង ឬពីខ្សែមសារហ្វូណូក្រាម ឬពីក្នុងការផ្សាយតាមទូរផ្សាយ ។

**ខ**-ការថតចម្លងដែលធ្វើឡើងសម្រាប់តែប្រើប្រាស់ក្នុងផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ ។

**គ**-ការថតចម្លងសម្រាប់បម្រើក្នុងក្របខ័ណ្ឌនៃការសិក្សាលើកលែងតែការសម្តែង ឬហ្វូណូក្រាមដែលផលិតសម្រាប់តែគោលបំណងនៃការសិក្សា ។

**ឃ**-អាគតដ្ឋានជាសម្រង់ខ្លីៗពីការសម្តែង ឬហ្វូណូក្រាម ឬកម្មវិធីចាក់ផ្សាយតាមទូរផ្សាយសមស្របតាមទម្លាប់ល្អ ដើម្បីប្រើប្រាស់ក្នុងទិសដៅព័ត៌មាន ។

**ង**-ការប្រើប្រាស់ផ្សេងៗទៀតដែលជាករណីលើកលែង ពិសេសចំពោះស្នាដៃនានាដែលទទួលបាននូវកិច្ចការពារសិទ្ធិអ្នកនិពន្ធដោយអនុលោមតាមច្បាប់នេះ ។

**ច**-ការចាប់យករូបភាពនិងសម្លេងដើម្បីផ្សព្វផ្សាយបន្តទាំងស្រុង ឬភាគខ្លះដោយអង្គភាពទូរផ្សាយស្តីពីបច្ចុប្បន្នភាពនៃពិធីបុណ្យ អង្គប្រជុំ ឬព្រឹត្តការណ៍នានារបស់ជាតិពីស្ថានីយដើមក្នុងពេលតែមួយ ។

## មាត្រា ៥១.-

បទប្បញ្ញត្តិនៃមាត្រា ៤១ នៃច្បាប់នេះ មិនត្រូវអនុវត្តនៅពេលណាដែលអ្នកសម្តែងអនុញ្ញាតឱ្យគេថតបញ្ចូលការសម្តែងរបស់ខ្លួនទៅក្នុងហ្វូណូក្រាមមានរូបភាពឬសោតទស្សន៍ ។

**មាត្រា ៥២.—**

បទប្បញ្ញត្តិនៃមាត្រា ៤១ ក្នុងច្បាប់នេះ មិនត្រូវយកទៅអនុវត្តចំពោះអង្គភាពទូរផ្សាយណាមួយដែលធ្វើការថតចម្លងនិងផលិតឡើងវិញដោយមធ្យោបាយផ្ទាល់ខ្លួន ដើម្បីចាក់ផ្សាយក្នុងកម្មវិធីផ្សាយរបស់អង្គភាពទូរផ្សាយនោះ ក្នុងគោលបំណងផ្សាយពាណិជ្ជកម្ម ។

រាល់ការផលិតឡើងវិញនូវស្នាដៃ ឬច្បាប់ចម្លងដូចមានចែងនៅក្នុងកថាខ័ណ្ឌខាងលើនៃមាត្រានេះ ត្រូវបំផ្លាញចោលឱ្យអស់ក្នុងរយៈពេល ៦(ប្រាំមួយ)ខែ បន្ទាប់ពីការផលិត លើកលែងតែករណីត្រូវរក្សាទុកស្នាដៃចម្លងមួយច្បាប់គត់សម្រាប់ជាឯកសារ ។

## ផ្នែកទី ៧
## រយៈពេលនៃកិច្ចការពារ

**មាត្រា ៥៣.—**

១-រយៈពេលនៃកិច្ចការពារអ្នកសម្តែងគឺ ៥០(ហាសិប)ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃការថតបញ្ចូលក្នុងហ្វូណូក្រាម ឬក្នុងករណីដែលពុំបានថតការសម្តែងបញ្ចូលក្នុងហ្វូណូក្រាម គឺគិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិនដែលការសម្តែងបានប្រព្រឹត្តទៅ ។

២-រយៈពេលនៃកិច្ចការពារផលិតករហ្វូណូក្រាមគឺ ៥០(ហាសិប)ឆ្នាំ គិតពីចាប់ដំណាច់ឆ្នាំប្រក្រតីទិនដែលបានបោះផ្សាយហ្វូណូក្រាម ឬក្នុងករណីពុំបានបោះផ្សាយហ្វូណូក្រាម គឺគិតពីចាប់ដំណាច់ឆ្នាំប្រក្រតីទិន ដែលបានថតសម្លេងបញ្ចូលក្នុងហ្វូណូក្រាម ។

៣-រយៈពេលនៃកិច្ចការពារកម្មវិធីផ្សាយរបស់អង្គភាពទូរផ្សាយ គឺ ៥០(ហាសិប)ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិនដែលកម្មវិធីបានផ្សាយ ។

## ផ្នែកទី ៨
## ការផ្ទេរសិទ្ធិ

**មាត្រា ៥៤.-**

បទប្បញ្ញត្តិនៃមាត្រា ៣២ មាត្រា ៣៣ និងមាត្រា ៣៤ នៃច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះសិទ្ធិអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ។

## ផ្នែកទី ៩
## ការតម្កល់

**មាត្រា ៥៥.-**

បទប្បញ្ញត្តិនៃមាត្រា ៣៨ មាត្រា ៣៩ និងមាត្រា ៤០ នៃច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះសិទ្ធិអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ។

## ជំពូកទី ៤
## ការគ្រប់គ្រងរួមលើសិទ្ធិនានា

**មាត្រា ៥៦.-**

អ្នកនិពន្ធនិងម្ចាស់សិទ្ធិប្រហាក់ប្រហែលអាចបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួមដើម្បីការពារនិងគ្រប់គ្រងសិទ្ធិបេតិកភណ្ឌ ។

ការបង្កើតអង្គភាពគ្រប់គ្រងរួមលើសិទ្ធិអ្នកនិពន្ធ អ្នកសម្តែង ផលិតករហ្វូណូក្រាម ឬផលិតករវីដេអូ ត្រូវតែមានការទទួលស្គាល់ពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

អង្គភាពគ្រប់គ្រងរួមលើសិទ្ធិផ្សាយតាមវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាបនៃអង្គភាពទូរផ្សាយត្រូវមានការទទួលស្គាល់ពីក្រសួងពត៌មាន ។

## ជំពូកទី ៥
## ករណីវិវាទ និង ទោសប្បញ្ញត្តិ

**មាត្រា ៥៧.‒**

បុគ្គលណាដែលបានទទួលរង ឬអាចទទួលរងនូវការប៉ះពាល់ដល់សិទ្ធិរបស់ខ្លួនជាអ្នកនិពន្ធក្តី ឬសិទ្ធិប្រហាក់ប្រហែលក្តី បុគ្គលនោះមានសិទ្ធិប្តឹងទៅតុលាការដើម្បី :

**ក**-ធ្វើការហាមប៉ះពាល់ដល់សិទ្ធិខ្លួន ប្រសិនបើការប៉ះពាល់នោះអាចនឹងកើតមាននៅក្នុងពេលឆាប់ៗខាងមុខ ។

**ខ**-បង្គាប់ឱ្យចុងចម្លើយឈប់ធ្វើការប៉ះពាល់ដល់សិទ្ធិខ្លួន ប្រសិនបើការប៉ះពាល់បែបនេះនៅតែបន្តសកម្មភាព ។ ដើមចោទអាចទាមទារឱ្យចុងចម្លើយសងជម្ងឺចិត្ត សងការខូចខាតនិងប្រគល់មកវិញនូវវត្ថុតាងមានឧបករណ៍ ឬសម្ភារៈដែលជាប់រឿងហេតុព្រមទាំងប្រគល់នូវប្រាក់ចំណេញដែលបានមកពីអំពើខុសច្បាប់នោះ ។

**មាត្រា ៥៨.‒**

តុលាការមានសមត្ថកិច្ចរឹបអូសឬបំផ្លាញចោលនូវវត្ថុតាងមានឧបករណ៍ សម្ភារៈដែលត្រូវបានផលិត បានប្រើប្រាស់ ឬបានដាក់ឱ្យចរាចរដោយខុសច្បាប់ ឬឧបករណ៍សម្រាប់ធ្វើការបំពានដែលឧបករណ៍ឬសម្ភារៈទាំងនោះកំពុងស្ថិតក្នុងការកាន់កាប់របស់ចុងចម្លើយ ឬកំពុងត្រូវបានឃាត់ទុក ។

**មាត្រា ៥៩.‒**

តុលាការមានសមត្ថកិច្ចចាត់វិធានការចាំបាច់ជាបណ្តោះអាសន្ន សម្រាប់ធានានូវការរក្សាទុកវត្ថុតាង ដែលផលិតចេញពីការចម្លងខុសច្បាប់នូវស្នាដៃណាមួយ ។

ដើមចោទមានកាតព្វកិច្ចជួសជុលការខូចខាតដែលខ្លួនបានប្រព្រឹត្តទៅលើចុងចម្លើយ ក្នុងករណីបណ្តឹងនោះត្រូវបានតុលាការរកឃើញថាជាបណ្តឹងពុំមានមូលហេតុត្រឹមត្រូវ ។

### មាត្រា ៦០.–

ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃនៃការឃាត់ទុកនូវឧបករណ៍ ឬសម្ភារៈ បុគ្គលជាម្ចាស់ ឬតតិយជនជាអ្នកកាន់កាប់ឧបករណ៍ ឬសម្ភារៈដែលត្រូវបានឃាត់ទុក អាចស្នើសុំទៅតុលាការឱ្យលើកលែងការឃាត់ទុក ឬសម្រេចកម្រិតអនុភាពនៃការឃាត់ទុកនោះ ។

### មាត្រា ៦១.–

ការឃាត់ទុកនូវវត្ថុតាង មានឧបករណ៍ឬសម្ភារៈទាំងឡាយណាដោយពុំបានប្ដឹងទៅតុលាការក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃឃាត់ទុក ការលើកលែងការឃាត់ទុកតាមសំណើសុំរបស់បុគ្គលជាម្ចាស់ ឬតតិយជនជាអ្នកកាន់កាប់ ជាសមត្ថកិច្ចរបស់តុលាការ ។

### មាត្រា ៦២.–

យោងតាមមាត្រា ៦៤ និងមាត្រា ៦៥ នៃច្បាប់នេះ ត្រូវចាត់ទុកជាបទល្មើសដែរ អំពើទាំងឡាយដូចតទៅ :

១-ការផលិត ឬការនាំចូលដើម្បីដាក់លក់ ឬដាក់ជួលនូវឧបករណ៍ ឬគ្រឿងមធ្យោបាយណាមួយដែលធ្វើឡើង ឬយកលំនាំតាមក្នុងគោលបំណងធ្វើឱ្យរាំងស្ទះដំណើរការល្អនៃឧបករណ៍ ឬគ្រឿងមធ្យោបាយទូទៅ ឬកាត់បន្ថយចំនួនការផលិតឡើងវិញនៃស្នាដៃហ្វូណូក្រាម ឬការផ្សាយតាមទូរផ្សាយ ឬធ្វើឱ្យខូចគុណភាពនូវច្បាប់ចម្លង ។

២-ការផលិត ឬការនាំចូលដើម្បីដាក់លក់ ឬដាក់ជួលនូវឧបករណ៍ ឬគ្រឿងមធ្យោបាយណាមួយដែលនាំឱ្យបុគ្គលគ្មានសិទ្ធិទទួលបាននូវកម្មវិធីផ្សាយតាមសញ្ញាលេខកូដដែលផ្សាយតាមទូរផ្សាយ ឬផ្សាយជាសាធារណៈតាមវិធីផ្សេងរួមមានការផ្សាយតាមផ្កាយរណប ។

៣-ការលុបចោលឬការកែប្រែព័ត៌មានស្ដីពីរបបសិទ្ធិតាមទម្រង់អេឡិច-ត្រូនិច ដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ។

៤-ការចែកចាយ ឬការនាំចូលដើម្បីចែកចាយ ការផ្សាយតាមអង្គភាពទូរផ្សាយ ការផ្សាយជាសាធារណៈ ឬការដាក់ជូនសាធារណជននូវស្នាដៃ ឬការសម្ដែង

ឬហ្វូណូក្រាម ឬកម្មវិធីផ្សាយនៃអង្គភាពទូរផ្សាយដោយគ្មានការអនុញ្ញាត ហើយអ្នកប្រព្រឹត្តដឹងច្បាស់ថាព័ត៌មានស្តីពីរបបសិទ្ធិតាមទម្រង់អេឡិចត្រូនិចជាព័ត៌មានដែលត្រូវគេលុបចោលឬកែប្រែរួចហើយ ។

ពាក្យថា **"ព័ត៌មានស្តីពីរបបសិទ្ធិ"** មានន័យថា :

-ព័ត៌មានដែលធ្វើឱ្យគេស្គាល់ពីអត្តសញ្ញាណអ្នកនិពន្ធ ភិនភាគស្នាដៃ អត្តសញ្ញាណអ្នកសម្តែង ភិនភាគនៃអ្នកសម្តែង អត្តសញ្ញាណផលិតករហ្វូណូក្រាម ភិនភាគហ្វូណូក្រាម អត្តសញ្ញាណអង្គភាពទូរផ្សាយនិងភិនភាគកម្មវិធីអង្គភាពទូរផ្សាយ

-ព័ត៌មានដែលធ្វើឱ្យគេស្គាល់ពីអត្តសញ្ញាណម្ចាស់កម្មសិទ្ធិ ឬភិនភាគនៃព័ត៌មានស្តីពីលក្ខខណ្ឌនិងបែបបទនៃការប្រើប្រាស់ស្នាដៃនិងផលិតផលដទៃទៀត ដូចមានចែងនៅក្នុងច្បាប់នេះ និងស្គាល់ភិនភាគលេខកូដ ឬសញ្ញាលេខកូដ ដែលចែងឱ្យដឹងនូវព័ត៌មានទាំងនោះ ។

## មាត្រា ៦៣._

តាមការស្នើសុំជាលាយលក្ខណ៍អក្សរពីម្ចាស់សិទ្ធិអ្នកនិពន្ធ ឬម្ចាស់សិទ្ធិប្រហាក់ប្រហែល ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យ រដ្ឋបាលគយនិងរដ្ឋាករអាចឃាត់ទុកបាននូវទំនិញដែលម្ចាស់សិទ្ធិនោះសំអាងថាជាទំនិញក្លែងបន្លំ ។ រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនដំណឹងជាបន្ទាន់ដល់តុលាការមានសមត្ថកិច្ច អាជ្ញាធរមានសមត្ថកិច្ចដើមបណ្តឹង និងអ្នកកាន់កាប់ទំនិញអំពីការឃាត់ទុកនូវទំនិញទាំងនោះ ។

លើកលែងតែមានបទប្បញ្ញត្តិស្តីពីរដ្ឋបាលគយនិងរដ្ឋាករចែងផ្ទុយពីបទប្បញ្ញត្តិនេះ វិធានឃាត់ទុកទំនិញអាចលុបចេញដោយស្របច្បាប់បាន ប្រសិនបើក្នុងរយៈពេល ១០ (ដប់)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃជូនដំណឹងស្តីពីការឃាត់ទុកទំនិញនោះ អ្នកប្តឹងពុំបានបង្ហាញភស្តុតាងឱ្យបានត្រឹមត្រូវដើម្បីបញ្ជាក់ទៅរដ្ឋបាលគយនិងរដ្ឋាករឱ្យដឹងថាសាមីខ្លួនបាន :

-ស្នើសុំទៅតុលាការចាត់វិធានការរក្សាទុកទំនិញដូចមានចែងក្នុងមាត្រា ៥៩ នៃច្បាប់នេះ

-ប្តឹងទៅតុលាការមានសមត្ថកិច្ចដោយមានភ្ជាប់ជាមួយនូវការធានាគ្រប់គ្រាន់ដើម្បីការពារទុកជាមុននូវការទទួលខុសត្រូវរបស់ខ្លួនដែលអាចកើតមានជាយថា-

ហេតុបាន ។

អ្នកប្តឹងត្រូវតែជួសជុលការខូចខាតដែលបណ្តាលមកពីការឃាត់ទុកទំនិញនោះ ប្រសិនបើបណ្តឹងរបស់ខ្លួនត្រូវបានរកឃើញថាជាបណ្តឹងគ្មានមូលដ្ឋានត្រឹមត្រូវ ។

បទប្បញ្ញត្តិស្តីពីវិធានការតាមមាត់ច្រកព្រំដែននៃច្បាប់ស្តីពី “ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់” ត្រូវយកមកអនុវត្តបន្ថែមក្នុងមាត្រានេះ ។

## មាត្រា ៦៤._

ការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធដូចមានកំណត់ក្នុងច្បាប់នេះ តាមរយៈការផលិត ការផលិតឡើងវិញ ឬការសម្តែង ឬការផ្សព្វផ្សាយនូវស្នាដៃដោយប្រើមធ្យោបាយបែបណាក៏ដោយ គឺជាបទល្មើសដែលត្រូវទទួលទោសតាមច្បាប់ ។

បទល្មើសនៃការផលិតឬការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២៥.០០០.០០០(ម្ភៃប្រាំលាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ១២(ដប់ពីរ)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

ការនាំចូលឬនាំចេញនូវផលិតផលបានពីបទល្មើសដែលជាការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ១២(ដប់ពីរ)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

បទល្មើសនៃការសម្តែង ឬការផ្សព្វផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ ។ ករណីបទល្មើសបានប្រព្រឹត្តច្រើនដង ការផ្តន្ទាទោសត្រូវគុណនឹងចំនួននៃការប្រព្រឹត្ត ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដងនៃទោសពីមុន ។

## មាត្រា ៦៥._

ការផលិតឬការផលិតឡើងវិញដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬពីផលិតករហ្វូណូក្រាម ឬពីផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី

៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២៥.០០០.០០០(ម្ភៃប្រាំលាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ១២(ដប់ពីរ)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

ការនាំចូលឬនាំចេញនូវហ្វូណូក្រាម កាសែ្សត ឬកាសែ្សតវីដេអូដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬផលិតករហ្វូណូក្រាម ឬផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

ការចាក់ផ្សាយតាមទូរផ្សាយដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬពីផលិតករហ្វូណូក្រាម ឬពីផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ឬនិងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

**មាត្រា ៦៦.–**

គ្រប់ករណីដូចមានចែងក្នុងមាត្រា ៦៤ និងមាត្រា ៦៥ នៃច្បាប់នេះ តុលាការមានសមត្ថកិច្ចចេញសេចក្តីសម្រេចដូចតទៅ :

-រឹបអូសមួយភាគឬទាំងស្រុងនូវប្រាក់ចំណូលបានមកពីបទល្មើសនិងឧបករណ៍ដែលដាក់តាំងដោយឡែកសម្រាប់ការប្រព្រឹត្តទៅនូវបទល្មើសនោះ

-បង្គាប់ឱ្យយកឧបករណ៍ឬសម្ភារៈដែលរឹបអូសទៅប្រគល់ជូនម្ចាស់សិទ្ធិអ្នកនិពន្ធ ឬម្ចាស់សិទ្ធិប្រហាក់ប្រហែលដោយមិនទាន់គិតគូរដល់ការសងសោហ៊ុយជម្ងឺចិត្ត

-បង្គាប់ឱ្យបំផ្លាញចោលនូវសម្ភារៈនិងឧបករណ៍ដែលបានពីការរឹបអូស ។

## ជំពូកទី ៦

## ការអនុវត្តសន្ធិសញ្ញាអន្តរជាតិ

**មាត្រា ៦៧.–**

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិទាក់ទងនឹងច្បាប់សិទ្ធិអ្នកនិពន្ធនិង

សិទ្ធិប្រហាក់ប្រហែលដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ត្រូវយកមកអនុវត្តជាមួយនឹងច្បាប់នេះបាន ។

ក្នុងករណីមានទំនាស់ជាមួយនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិទាំងនោះ ត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៦៨.–**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវចេញសេចក្តីប្រកាសអំពីការបញ្ឈប់ជាបន្ទាន់នូវរាល់អាជីវកម្មដែលផ្ទុយនឹងច្បាប់នេះ ។

ក្រោយពីច្បាប់នេះចូលជាធរមាន ៦(ប្រាំមួយ)ខែ ទោសប្បញ្ញត្តិនៃមាត្រា ៦៤ និងមាត្រា ៦៥ ត្រូវយកមកអនុវត្តចំពោះអាជីវកម្មកំពុងមានសកម្មភាពផ្ទុយនឹងច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៦៩.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០០៣

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នរល-០៣.០៣.១១៣ **នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន** បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**ព្រះហស្តលេខា**

**នរោត្តម បុប្ផាទេវី**

# ប្រកាស

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

លេខ...២០ ប្រ.ក....វវស

# ប្រកាស

## ស្តីពី

## ការបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាព ដែលរំលោភបំពានលើសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម / ០១៩៦/ ០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស /រកម/០៣០៣/ ០០៨ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

**<u>សម្រេច</u>**

**<u>ប្រការ</u> ១.-**

**ស្នាដៃ** ជាផលិតផលខាងវិស័យ អក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រី កើតចេញពីការច្នៃប្រឌិតបង្កើតឡើងដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនា ។

**<u>ប្រការ</u> ២.-**

**អ្នកនិពន្ធ** ជាជនដែលបង្កើតបានស្នាដៃ ។

និងផ្សាយពាណិជ្ជកម្មតាមរយៈទូរទស្សន៍ ឬតាមរយៈកម្មវិធីផ្សព្វផ្សាយ និងសិទ្ធិអង្គភាពទូរស្សន៍ ។

**អង្គភាពផ្សព្វផ្សាយ** គឺស្ថានីយវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប ឬផ្កាយរណប ។

**ប្រការ ៣.-**

ស្នាដៃទាំងឡាយដែលត្រូវទទួលបានការការពារក្រោមច្បាប់នេះមាន :

ក-សៀវភៅអានគ្រប់ប្រភេទ ឬឯកសារផ្សេងៗទៀតស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ និងការអប់រំ ។

ខ-អត្ថបទបាឋកថា សង្កថា ធម្មទេសនា ការការពារខ្លួនដោយនិយាយ ឬដោយសរសេរ និងស្នាដៃផ្សេងៗទៀត ដែលមានប្រភេទដូចគ្នា ។

គ- ស្នាដៃនាដកម្ម ឬនាដកម្ម-តូរ្យតន្ត្រី ។

ឃ- ស្នាដៃរបាំសម័យ ឬយកលំនាំតាមស្នាដៃបុរាណ ឬប្រពៃណី ។

ង- ការសម្តែងសៀក និងការសម្តែងកាយវិការ ។

ច- ការតែងបទភ្លេងដោយមាន ឬគ្មានទំនុកច្រៀង ។

ឆ- ស្នាដៃសោតទស្សន៍ ។

ជ- ស្នាដៃជាផ្ទាំងគំនូរ ផ្ទាំងចម្លាក់ រូបចម្លាក់ ឬស្នាដៃផ្សេងៗទៀតខាងសិល្បៈសូនរូប ឬសិល្បៈអនុវត្ត ។

ឈ- ស្នាដៃថតរូប និងស្នាដៃទាំងឡាយដែលសម្រេចបានដោយសារមានជំនួយបច្ចេកទេសដូចគ្នា នឹងការថតរូប ។

ញ-ស្នាដៃស្ថាបត្យកម្ម ។

ដ-ផែនទី ប្លង់ គំនូសវាស ឬស្នាដៃស្តែងចេញជារូប ដែលទាក់ទងនឹងភូមិសាស្ត្រ ឋានលេខា ឬវិទ្យាសាស្ត្រនានា ។

ឋ-កម្មវិធីកុំព្យូទ័រ និងគម្រោងឯកសារសមោធាន ដែលទាក់ទងទៅនឹងកម្មវិធីទាំងនោះ ។

ឌ- ផលិតផលផ្នែកសិប្បកម្ម តម្បាញ ឬម៉ូតសម្លៀកបំពាក់ផ្សេងៗ ។

**ប្រការ ៤.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានបង្កើតស្នាដៃដូចមានចែងក្នុងប្រការ៣ខាងលើ មានឈ្មោះថាជាម្ចាស់កម្មសិទ្ធិ លើស្នាដៃ ហើយទទួលបាននូវសិទ្ធិធ្វើអាជីវកម្ម និងសិទ្ធិការពារលើស្នាដៃរបស់ខ្លួន ។

**ប្រការ ៥.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលនូវសិទ្ធិស្របច្បាប់លើស្នាដៃដូចមានចែងក្នុងប្រការ៣ខាងលើ មានឈ្មោះថាជាម្ចាស់កម្មសិទ្ធិលើស្នាដៃហើយទទួលបាននូវសិទ្ធិធ្វើអាជីវកម្ម និងសិទ្ធិការពារលើស្នាដៃនោះ ។

**ប្រការ ៦.-**

ត្រូវបញ្ជប់ជាបទធ្ងន់នូវសកម្មភាពដូចតទៅ ÷

ក-ការផលិត ឬការផលិតឡើងវិញ ឬការផ្សព្វផ្សាយជាសាធារណៈនូវស្នាដៃដោយគ្មានការអនុញ្ញាតពីម្ចាស់

ខ-ការក្លែងបន្លំ ក្នុងការផលិត ឬការផលិតឡើងវិញនូវស្នាដៃដែលរំលោភបំពានលើម្ចាស់កម្មសិទ្ធិ ។

គ-ការនាំចូលនូវផលិតផលនៃស្នាដៃពីបរទេសដើម្បីធ្វើអាជីវកម្ម ឬបង្កើតស្នាដៃបន្តដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ។

ឃ-ការនាំចេញនូវស្នាដៃ ដើម្បីធ្វើអាជីវកម្មដោយគ្មានការយល់ព្រមពីម្ចាស់កម្មសិទ្ធិ ។

**ប្រការ ៧.-**

ចាប់ពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៣ រាល់អំពើល្មើសដែលរំលោភបំពានលើសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ត្រូវផ្តន្ទាទោសតាមបទបញ្ញត្តិនៃច្បាប់ សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ។

**ប្រការ ៨.-**

ខុទ្ទកាល័យ អធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ គ្រប់អង្គភាពចំណុះក្រសួង មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈគ្រប់ខេត្តក្រុង ទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមិនា ឆ្នាំ ២០០៣

រដ្ឋមន្ត្រី

នរោត្តម - បុប្ផាទេវី

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទការល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងពត៌មាន
- ក្រសួងឧស្សាហកម្ម
- ក្រសួងយុត្តិធម៌
- គ្រប់ក្រសួង

"ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ៨ "ដើម្បីអនុវត្ត"
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខ : ៤២០ ប្រ.ក-វវក

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងអាជីវកម្មនិងសេវាកម្ម

## លក់ ជួល ផលិតផលភាពយន្តនិងវីដេអូ

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល
- បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បភាពយន្តនិងវីដេអូ
- យោងតាមការចាំបាច់របស់ក្រសួង។

## សម្រេច

**ប្រការ ១** : ប្រកាសនេះមានគោលបំណង គ្រប់គ្រងលើអាជីវកម្មនិងសេវាកម្ម លក់ ជួល ផលិតផលភាពយន្តនិងវីដេអូ ជាកាសែ្សត វីស៊ីឌីនិងឌីវីឌី ដែលកំពុងធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២** ៖ តែមប្រិ៍និងត្រាទិដ្ឋាការមានលក្ខណៈសម្គាល់ដូចខាងក្រោម៖

**តែមប្រិ៍ទិដ្ឋាការ** ៖ មានរាងបួនជ្រុងទ្រវែង បណ្តោយប្រវែង ៥០ (ហាសិប)ម.ម និង ទទឹង ប្រវែង ២០(ម្ភៃ)ម.ម មានរូបព្រហ្ម ពណ៌ក្រហមស្រអាប់ នៅចំកណ្តាលផ្ទៃ

-មានចារឹកអក្សរ **ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ** ពណ៌ខៀវនៅផ្នែកខាងលើ

-មាន**លេខទិដ្ឋាការ** នៅផ្នែកកណ្តាល និង

-មានចុះ **កាលបរិច្ឆេទ** ផ្តល់ទិដ្ឋាការនៅផ្នែកខាងក្រោម។

**ត្រាទិដ្ឋាការ** ៖ មានរាងមូលវិជ្ជមាត្រប្រវែង ១៩ (ដប់ប្រាំបួន) ម.ម

-មានរង្វង់មូល ចែកផ្ទៃជាពីរ

-ផ្ទៃខាងក្នុងមានចារឹកអក្សរ **ភវ** និង

-ផ្ទៃខាងក្រៅមានចារឹកអក្សរ គណៈកម្មការត្រួតពិនិត្យ។

គំរូ តែមប្រិ៍និងត្រាទិដ្ឋាការ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៣** ៖ តែមប្រិ៍និងត្រាទិដ្ឋាការ មិនត្រូវបានអនុញ្ញាតឲ្យយកទៅប្រើប្រាស់ខុសពីខ្លឹមសារ ដែលបានកំណត់ក្នុងប្រការ ១ នៃប្រកាសនេះ។

**ប្រការ ៤** ៖ ការក្លែងបន្លំតែមប្រិ៍និងត្រាទិដ្ឋាការ តាមរូបភាពណាមួយ ប្រើទៅលើផលិតផលភាពយន្តនិងវីដេអូ ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ ៥** ៖ នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ ប្រធាននាយកដ្ឋានសិល្បៈភាពយន្តនិងផ្សព្វផ្សាយវប្បធម៌ ប្រធាននាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល គ្រប់ប្រធានអង្គភាពពាក់ព័ន្ធនិងប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មីនា ឆ្នាំ ២០១១

**រដ្ឋមន្ត្រី**

ហ៊ឹម ឆែម

<u>កន្លែងទទួល៖</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលារាជធានី ខេត្ត
-ដូចប្រការ ៥
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ